ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- សិទ្ធិជាមូលដ្ឋានរបស់កុមារត្រូវបានបដិសេធក្នុងរបបខ្មែរក្រហម
- រូបថតមួយសន្លឹកបានធ្វើឲ្យខ្ញុំនឹកដល់អតីតកាល

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ២២២ ខែមិថុនា ឆ្នាំ២០១៨

# ស្វែងរកការពិត

**ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា**

*លេខ២២២ ខែមិថុនា ឆ្នាំ២០១៨*


## មាតិកា

### សំបុត្រ


◆ សិទ្ធិជាមូលដ្ឋានរបស់កុមារត្រូវបានបដិសេធ..........................១


### ផ្នែកឯកសារ


◆ វីរភាព និងអនាគតភ្លឺស្វាងរបស់កុមារកម្ពុជា..........................២


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ កុមារក្រោមភ្នែកអង្គការ.................................................. ៩

◆ កុមារក្នុងរបបខ្មែរក្រហម..............................................១២

◆ ម៉ឺន ញ៉ឹន ៖ អតីតប្រធានយោធាកងវរសេនាតូច ...................១៥

◆ សិស្សវិទ្យាល័យសម្ដេច ហ៊ុន សែន ភ្នំពេញថ្មី .......................១៨

◆ អ្នកចម្រៀង មាស ហុកសេង ........................................២២

◆ ខ្មែរក្រហមបានបង្ហាត់យុទ្ធសាស្ត្រកងទ័ព............................ ២៦

◆ និស្សិតមហាវិទ្យាល័យច្បាប់ និងរដ្ឋបាលសាធារណៈ ............. ២៨

◆ វគ្គបណ្ដុះបណ្ដាលស្ដីពីការរកត់ត្រាឯកសារស្ដីពីសិទ្ធិមនុស្ស ........៣០

◆ ពិធីបុណ្យដែលនាំមកនៅស្មារតីសាមគ្គីភាព.........................៣៣

◆ រូបថតមួយសន្លឹកបានធ្វើឲ្យខ្ញុំនឹកដល់អតីតកាល .................... ៣៦


### ផ្នែកច្បាប់


◆ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល.............................. ៣៩


### វេទិការពិភាក្សាសាធារណៈ


◆ ដំណើរទស្សនកិច្ចសិក្សាស្ដីពីសន្តិភាព និងសិទ្ធិមនុស្ស .............៤៨


### ទំព័រស្រាវជ្រាវរកគ្រួសារ


◆ បញ្ជីឈ្មោះសៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់..........៥៥

◆ ប៉ុន អារុណ ៖ ក្រឡាបញ្ជីសាលាដំបូង .............................៥៩




កងកុមារកំពុងសែងដី


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៧៩១៣ម៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ៖*** *ហូ ថុនា, សោម ប៊ុនថន, ទាវ សារៈមុនិន្ទ, អ៊ុន សុដាវី, ដាក់រដ្ឋ មេត្តា, អ៊ិន វណ្ណាក់, ស៊ាង ចិន្តា, អាលីសុន វេលខេល, វ៉ាន់ថាន់ ពៅដារ៉ា, ប៊ាង ពីរ័ន្ត និង វេនី ខកហ្គៀល* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ហូ ថុនា, អ៊ុន សុដាវី និង ដាក់រដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *ផាត បូរ៉ា* ***និពន្ធនាយកទូទៅ៖*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយក៖*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គីម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# សិទ្ធិជាមូលដ្ឋានរបស់កុមារត្រូវបានបដិសេធក្នុងរបបខ្មែរក្រហម

ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨ ជាខួបលើកទី៦៩ ដែលប្រទេសកម្ពុជាបានប្រារព្ធទិវាកុមារអន្តរជាតិស្របទៅតាមរដ្ឋធម្មនុញ្ញ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិលេខ១៨២ ស្តីពីសិទ្ធិជាមូលដ្ឋានកុមាររបស់កុមារ ដែលទិវានេះបានរំឭកទៅដល់សោកនាដកម្ម ដែលរបបណាស៊ី បានកាប់សម្លាប់កុមារយ៉ាងរង្គាលនៅប្រទេសឆេកនិងប្រទេសបារាំងក្នុងអំឡុងសង្គ្រាមលើកទី២។ នៅថ្ងៃទី១២ ខែមិថុនា នេះដែរ ប្រទេសកម្ពុជាក៏បានផ្តល់សច្ចាប័នបន្ថែមលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២ ស្តីពីការហាមប្រាម និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងអនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់កុមារចូលធ្វើការ ដោយមានប្រទេសជាច្រើននៅលើពិភពលោកបានចូលរួម សំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ ការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងស្ថានភាពងាយរងគ្រោះ។

ទោះបីប្រទេសកម្ពុជាបានចូលរួម និងផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ តាំងពីឆ្នាំ១៩៨៩ មកក៏ដោយ ក៏រយៈពេល២៦ ឆ្នាំក្រោយមក គឺនៅពេលដែលខ្មែរក្រហម បានឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អនុសញ្ញានេះត្រូវបានខ្មែរក្រហមបដិសេធចោល ហើយសិទ្ធិជាមូលរបស់កុមារទាំងអស់មិនត្រូវបានយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រនោះទេ។ ផ្ទុយទៅវិញខ្មែរក្រហម បានប្រើកុមារជាកម្មសិទ្ធិផ្ទាល់ខ្លួន និងបានដាក់ឲ្យកុមាររស់នៅក្នុងស្ថានភាពគ្រោះថ្នាក់ ដោយបំបែកកុមារចេញពីឪពុកម្តាយ បង្ខំកុមារឲ្យធ្វើការងារធ្ងន់ធ្ងរ ដូចមនុស្សពេញវ័យនៅក្នុងការដ្ឋាន ពលកម្ម និងមិនបានការផ្តល់របបអាហារឲ្យកុមារហូបចុកឲ្យបានគ្រប់គ្រាន់ឡើយ។

ជាញឹកញាប់ មេដឹកនាំខ្មែរក្រហមបានលើកឡើង និងបានចាត់ទុកកុមារជាមនុស្សស្អាតស្អំ និងស្មោះត្រង់ជាមួយនឹងចលនាបដិវត្តន៍។ ដូច្នេះហើយទើបខ្មែរក្រហមបានបញ្ចូលទ្រឹស្តី និងមនោគមន៍ជ្រុលហួសហេតុរបស់ខ្លួនទៅដល់កុមារឲ្យអនុវត្តយ៉ាងតឹងរឹង តាំងពីសម័យតស៊ូបដិវត្តន៍របស់ខ្លួនមកម៉្លេះ។ នៅអំឡុងពេលនោះដែរ ខ្មែរក្រហមបានចាត់តាំងកុមារឲ្យធ្វើជានីរសាររត់សំបុត្រពីកន្លែងមួយទៅកន្លែងមួយ ធ្វើកងឈ្លបការពារភូមិ និងតាមដានខ្មាំងដែលរួមទាំងសាច់ញាតិរបស់កុមារទាំងនោះផង។ ក្រៅពីលើកទឹកចិត្តកុមារឲ្យខិតខំធ្វើការងារប្រចាំថ្ងៃ ខ្មែរក្រហមក៏បានឲ្យកុមារសម្តែងភាពស្មោះភាពស្មោះត្រង់និងនិយាយការពិតពីសមាជិកក្រុមគ្រួសារ រួមទាំងឪពុកម្តាយរបស់ខ្លួនដែលជាប់សង្ស័យថាប្រឆាំងនឹងបដិវត្តន៍របស់ខ្មែរក្រហម។

នៅក្នុងសុន្ទរកថាមួយ ខៀវ សំផន បានលើកឡើងពីការងារប្រចាំថ្ងៃរបស់កុមារ ដើរដេញចាបកុំឲ្យស៊ីស្រូវ ឃ្វាលគោ និងលេងឡានធ្វើអំពីដីឥដ្ឋ ដែលជាការសន្សំសំចៃជាងក្មេងប្រទេសលោកខាងលិចដែលលេងឡានដែរ។ នួន ជា ក៏បានសរសេរអត្ថបទ និងរឿងទិនានផ្សេងៗ សរសើរពីវីរភាពកុមារ ដូចជា «វីរភាព និងអនាគតភ្លឺស្វាងរបស់កុមារកម្ពុជា» «កុមារកូនបក្ស» ក្នុងគោលបំណងទាក់ទាញចំណាប់អារម្មណ៍ពីកុមារ ហើយបានចុះផ្សាយនៅក្នុងទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ លេខ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ទៀតផង។ អត្ថបទ និងរឿងនិទានទាំងនេះ បានជំរុញឲ្យកុមារឲ្យទទួលស្គាល់«បក្ស»ជាឪពុកម្តាយ និងបានបណ្តុះគំនិតកុមារឲ្យឈឺចាប់ចងកំហឹងជាមួយខ្មាំងសត្រូវរបស់បក្ស។ នៅអំឡុងពេលគ្រប់គ្រងអំណាច ខ្មែរក្រហមក៏បានប្រើគ្រប់មធ្យោបាយដើម្បីលើកទឹកចិត្ត និងជ្រើសកុមារឲ្យចូលបម្រើយោធា រួចបញ្ជូនឲ្យទៅប្រយុទ្ធតទល់ជាមួយនឹងកងទ័ពវៀណាមនៅតាមព្រំដែន។ ជាលទ្ធផលកុមារក្មេងៗដែលមិនទាន់គ្រប់អាយុ និងគ្មានបទពិសោធន៍ជាច្រើនបានស្លាប់បាត់ជីវិតនៅលើសមរភូមិ។ ការអនុវត្តគោលនយោបាយដឹកនាំរបស់ខ្មែរក្រហម បានផ្ទុយទាំងស្រុង ទៅនឹងសិទ្ធិជាមូលដ្ឋានរបស់កុមារដែលមានចែង នៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកុមារ ដែលកុមារមានសិទ្ធិទទួលបានអាហារ ការថែទាំ ការសិក្សាអប់រំ និងការហាមឃាត់ការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ។

***សោម ប៊ុនថន***

# ជីវភាព និងអនាគតភ្លឺស្វាងរបស់កុមារកម្ពុជា

## (ដកស្រង់ចេញពីឯកសារលេខ D021382)

ក្នុងចលនាតស៊ូបដិវត្តន៍គ្រប់ជំនាន់ កុមារកម្ពុជា ក្រោមការឃោសនាប់រំ និងដឹកនាំរបស់អង្គការបដិវត្តន៍បានរួមវិភាគទានយ៉ាងសកម្ម និងសមរម្យថ្លៃថ្លាបំផុតក្នុងការវាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ ដើម្បីបុព្វហេតុរំដោះប្រទេសជាតិ និងរំដោះប្រជាជន។ កាលពីក្នុងសម័យតស៊ូនយោបាយសម្ងាត់ កុមារយើង ពិសេសកុមារដែលជាកូនកម្មករពលករនៅទីក្រុង និងជាកូនកសិករក្រីក្រនៅជនបទបានរួមប្រាស្រ័យធ្វើសកម្មភាពបដិវត្តន៍តាំងពីតូចៗម្ល៉េះ។ កុមារខ្លះធ្វើជានីរសាររត់សំបុត្រពីកន្លែងមួយទៅកន្លែងមួយនាំឯកសារពីតំបន់មួយទៅតំបន់មួយ ឬរហូតដល់ឆ្លងខេត្តខណ្ឌជាច្រើនទៀត នៅក្រោមការត្រួតពិនិត្យ ឆែកឆេរ តាមដានឃ្លាំមើល យ៉ាងតឹងរ៉ឹងបំផុតរបស់ខ្មាំងទាំងយប់ទាំងថ្ងៃ។ តែទោះជាសភាពការណ៍តឹងតែងយ៉ាងនេះក្តី ទោះជាខ្មាំងសម្លុតគម្រាមកំហែងឃោរឃៅ ហ្វាស៊ីសយ៉ាងណាក្តី ទោះខ្មាំងមានឧបាយកលបង្កប់តាមដានគ្រប់ជំនាន់យ៉ាងណាក្តី ក៏កុមារយើងចេះប្រើប្រាជ្ញាឈ្លាសវៃ ប៉ិនប្រសប់ គេចចុះគេចឡើង បង្វិលតែជុំវិញខ្មាំងសម្រេចភារកិច្ចនីរសារនេះប្រកបដោយជោគជ័យជានិច្ច។ កុមារខ្លះមានភារៈនាំផ្លូវកម្មាភិបាលដើរចុះឡើង ធ្វើការនៅតាមមូលដ្ឋាន ឬជួយពង្រត់បង្វេះកម្មាភិបាល យកទៅលាក់បំពួន ការពារសន្តិសុខ ពេលខ្មាំងវាតត្បាតមូលដ្ឋានម្តងៗ។ កុមារខ្លះទៀត មានភារៈចាំយាមផ្លូវ ឬយាមផ្ទះ ដើម្បីឲ្យសញ្ញាដល់ពួៗ កម្មាភិបាលដែលកំពុងធ្វើការ ឬប្រជុំសម្ងាត់នៅក្នុងបន្ទប់នៅពេលណា ដែលមានខ្មាំងមកដល់ជិតៗទីនោះ។ កុមារខ្លះទៀត មានភារៈដើររកម្ហូបចំណីបន្លែបង្ការ ត្រីសាច់ ផ្គត់ផ្គង់កម្មាភិបាលដែលរស់នៅក្នុងសម្ងាត់ពុំអាចចេញដើរហើយរកស៊ីបានដូចគេឯង។ កុមារយើងទទួល



កងកុមារកំពុងដុសសម្អាតបំពង់បូមទឹក

បំពេញភារកិច្ចនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងដោយមនោសញ្ចេតនាបដិវត្តន៍ជ្រាលជ្រៅបំផុត ចំពោះពូៗមីងៗ កម្មាភិបាលបដិវត្តន៍ៗ ក្នុងមួយថ្ងៃៗ កុមារយើងគ្មានឈប់ទំនេរដៃទេ កុមារដើររកជញ្ជាត់ត្រី ជញ្ជាត់កំពិស ជីកក្តាម ចាប់កង្កែប ឬធ្វើអន្ទាក់ធ្វើដង់ដាក់សត្វដើម្បីបានត្រីសាច់ខ្លះយកមកផ្សែផ្សំធ្វើម្ហូប ផ្គត់ផ្គង់ពូមីងកម្មាភិបាលៗ ព្រមជាមួយនេះ កុមារដើរបេះបន្លែបន្ការតាមស្រែ តាមត្រពាំង ឬបេះស្លឹកឈើស្លឹកព្រៃណាដែលអាចហូបបាន យកមកទុកធ្វើសម្លរជូនពូមីងកម្មាភិបាលហូប ដើម្បីមានកម្លាំងបម្រើការងារបដិវត្តន៍ឲ្យបានច្រើនៗ ពេលទំនេរថ្ងៃត្រង់ កុមារក៏មិនដែលបានសម្រាកដែរ កុមារតែងឆ្លៀតទៅរកជីកដំឡូងព្រៃ ដំឡូងទឹកទៀតៗ ពេលបានដំឡូងមកកុមារមិនហ៊ានហូបខ្លួនឯងទេ ឬហូបតែបន្តិចបន្តួចហើយសល់ប៉ុន្មានទុកយកទៅស្ងោរជូនពូមីង កម្មាភិបាលបដិវត្តន៍ដែលកំពុងធ្វើការនៅតែក្នុងបន្ទប់ៗលៗ

ក្នុងសម័យតស៊ូអាវុធរួមផ្សំនយោបាយ ដើម្បីទប់ទល់និងវាយកម្ចាត់សង្គ្រាមផ្ទៃក្នុង ដែលចក្រពត្តិអាមេរិក និងបរិវារបង្កឡើង កុមារកម្ពុជាយើង ក៏បានរួមចំណែកយ៉ាងសកម្ម និងស័ក្តសិទ្ធិបំផុតជាមួយនឹង ពុកម៉ែ ប្រជាជនកម្ពុជាទាំងមូលព្រមទាំងពូៗកងទ័ពបដិវត្តន៍យើងផងៗ កុមារបានធ្វើជានីរសាររត់សំបុត្រកាត់តំបន់ខ្មាំងឬពីស្រុកភូមិដែលខ្មាំងកាន់កាប់ ទៅមូលដ្ឋានព្រៃភ្នំមកតំបន់ខ្មាំងវិញ យ៉ាងអង់អាចក្លៀវក្លានឹងឈ្លាសវៃប៉ិនប្រសប់បំផុតៗ កុមារខ្លះ ចូលក្នុងក្រុមផលិត រួមប្រយុទ្ធបង្កបង្កើនផលជាមួយពុកម៉ែ បងប្អូនមីងមាផ្សេងទៀត ដើម្បីប្រមូលស្បៀងខបត្ថម្ភបដិវត្តន៍ៗ កុមារខ្លះទៀត ប្រើកលល្បិចយ៉ាងប៉ិនប្រសប់បោកបញ្ឆោតបង្វែរពន្យាងខ្មាំងជួយដឹកជញ្ជូនស្បៀងអាហារ ថ្នាំពេទ្យ និងសម្ភារផ្សេងៗយកទៅផ្តល់ជូនពូៗកងទ័ពនៅក្នុងព្រៃៗ កុមារខ្លះទៀត ដូចនៅខាងរតនៈគិរី មណ្ឌលគិរី ស្ទឹងត្រែង បានចូលធ្វើកងឈ្លបជួយយាមកាមការពារភូមិឃុំ និងជួយពិនិត្យតាមដានចលនានឹងសកម្មភាពខ្មាំងៗ នៅរដូវប្រាំងម្តងៗដែលខ្មាំងតែងចុះវាតត្បាតតាមមូលដ្ឋានបង្អែកបដិវត្តន៍នានា កុមារយើងបានរួមជាមួយពុកម៉ែ ពូមីង យាយតា ជួយធ្វើចម្រូងផ្គូ ស្នា ខ្លា យ៉ាងញាប់ដៃញាប់ ជើង និងប៉ិនប្រសប់ទាំងយប់ទាំងថ្ងៃដើម្បីប្រដាប់អាវុធឲ្យភូមិឃុំខ្លួនអាចប្រឈមមុខទប់ទល់ការពារការវាតត្បាតរបស់ខ្មាំង និងដើម្បីរក្សាការពារមូលដ្ឋាន បដិវត្តន៍ការពារប្រជាជន និងទ្រព្យសម្បត្តិរបស់ប្រជាជនឲ្យបានដាច់ខាតៗ ក្រៅពីសកម្មភាពខាងលើនេះ កុមារនៅបានរួមចំណែកក្នុងសកម្មភាពវប្បធម៌សិល្បៈសង្គមកិច្ច និងសុខាភិបាលនៅតាមមូលដ្ឋានបង្អែកបដិវត្តន៍នានាទៀតផងៗ

សរុបមក ក្នុងសម័យតស៊ូអាវុធរួមផ្សំនយោបាយកន្លងទៅនេះ កុមារកម្ពុជា ពិសេសកុមារដែលជាកូនចៅកម្មករពលករ និងកសិករក្រីក្របានបង្ហាញនូវវីរភាពបដិវត្តន៍យ៉ាងខ្ពង់ខ្ពស់បំផុត បញ្ចេញនូវស្មារតីអង់អាចក្លាហាន ស្មារតីឈ្លាសវៃប៉ិនប្រសប់និងស្នាដៃច្នៃប្រឌិតគ្រប់បែបយ៉ាងយ៉ាងរស់រវើក ដើម្បីសម្រេចភារកិច្ចបដិវត្តន៍ដែលអង្គការប្រគល់ឲ្យប្រកបដោយជោគជ័យជានិច្ចៗ ក្នុងការសម្រេចភារកិច្ចបដិវត្តន៍ដ៏មានគ្រោះថ្នាក់ខាងលើនេះ កុមារយើងបានពុះពារគ្រប់ឧបសគ្គ ឆ្លងកាត់ការលំបាកវេទនា អត់ឃ្លាន ឈឺថ្កាត់គ្មានថ្នាំសង្កូវ ហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាងបង្ហូរញើសឈាមជាមួយពុកម៉ែ ប្រជាជនទូទៅរហូតដល់ហ៊ានបូជាអាយុជីវិតដ៏ក្មេងខ្ចីរបស់ខ្លួន យ៉ាងអង់អាចក្លាហានដើម្បីបុព្វហេតុបដិវត្តន៍ គឺរំដោះប្រទេសជាតិ និងរំដោះប្រជាជនកម្ពុជាៗ

កាលពីសម័យសង្គ្រាមផ្ទៃក្នុង កុមារយើងមួយចំនួនត្រូវបានខ្មាំងចាប់យកទៅឃុំឃាំង ដាក់គុកច្រវាក់ធ្វើទារុណកម្មលើរូបរាងកាយយ៉ាងឃោរឃៅព្រៃផ្សៃបំផុត រហូតដល់កុមារខ្លះត្រូវពលីនៅក្នុងគុក ឬក្នុងកន្លែងឃុំឃាំងៗ កុមារខ្លះ ត្រូវពិការអស់មួយជីវិតកុមារខ្លះទៀត មានសុខភាពខ្សោយរហូតពុំអាចធ្វើការងារបានដូចគេឯងឡើយ ពេលចេញពីគុកមកវិញៗ កុមារខ្លះទៀត ត្រូវខ្មាំងចាប់វះពោះ កាត់ក្បាល កាត់ដៃកាត់ជើង ខ្វេះគ្រាប់ភ្នែក ចាក់សម្លាប់នឹងចំពុះទុង ដើម្បីធ្វើការ

កៀបសង្កត់លើឪពុកម្តាយជីវិតស្លូវបម្រើយ យ៉ាងព្រៃផ្សៃហ្វាស៊ីសបំផុត។ នៅចំពោះមុខអំពើឃោរឃៅហ្វាស៊ីសទាំងនេះរបស់ខ្មាំង កុមារកម្ពុជា មិនត្រឹមតែមិនបាក់បបខ្លបខ្លាចបុះញ៉ើមសារភាពខ្មាំងប៉ុណ្ណោះទេ តែផ្ទុយទៅវិញកុមារយើងកាន់តែមានកំហឹងឆាបឆេះសន្ធោរសន្ធៅចំពោះខ្មាំង ហើយចងគំនុំជាមួយខ្មាំងជារៀងរហូតអស់មួយជីវិត។ ដូច្នេះ កុមារកម្ពុជាបានរួមសកម្មភាពយ៉ាងជិតស្និទ្ធជាមួយពុកម៉ែ មាមីងបងប្អូន ប្រជាជនទូទៅលើកជ្រោងគ្រវីទង់ប្រយុទ្ធវាយកម្ទេចខ្មាំងយ៉ាងអង់អាចក្លាហានបំផុតជាប់រៀងរហូតមក។

ក្នុងសម័យសង្គ្រាម ឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបរិវារជាង៥ឆ្នាំកន្លងទៅនេះ កុមារកម្ពុជា ដែលមានប្រពៃណីបដិវត្តន៍អង់អាចក្លាហាន និងឈ្លាសវៃក្នុងការសម្រេចភារកិច្ចបដិវត្តន៍ ក៏បានរួមវិភាគទានក្នុងការប្រយុទ្ធកម្ទេចខ្មាំង កាន់តែសកម្មកាន់តែសស្រាក់សស្រាំថែមទៀតទាំងនៅសមរភូមិ មុខទាំងនៅសមរភូមិក្រោយ។

នៅសមរភូមិក្រោយ កុមារយើងបានចូលក្នុងក្រុមកុមារស្នេហាជាតិ ប្រយុទ្ធបង្កបង្កើនផលជាសមូហភាព ដើម្បីប្រមូលស្បៀងឧបត្ថម្ភទៅពួកកងទ័ព នៅសមរភូមិមុខផងខំហាត់ហ្វឹកហ្វឺនវិជ្ជាយោធាវាយខ្មាំងផង ត្រៀមបម្រុងខ្លួនជាស្រេច ចូលបម្រើកងទ័ពបដិវត្តន៍នៅពេលណាដែលអង្គការត្រូវការភ្លាម។ ព្រមជាមួយនេះ កុមារយើងនៅបានឆ្លៀតពេលទំនេរខិតខំរៀនសូត្រអក្សរ និងលេខដើម្បីកសាងនិងបង្កើនសមត្ថភាពខ្លួន។

កុមារក្នុងក្រុមសហករណ៍ ក៏បានរៀនវប្បធម៌ផង ធ្វើពលកម្មបង្កបង្កើនផលផង។ កុមារបានចុះប្រឡូក ធ្វើស្រែចម្ការ ជាមួយសមាជិកសហករណ៍ផ្សេងទៀត ជួយឃ្វាលគោក្របីរបស់ឪពុកម្តាយខ្លួនដែរ។ កុមារជួយចញ្ចឹមថែទាំឲ្យបាយទឹកចំណីដល់ ជ្រូក មាន់ ទា ក្នុងក្រុមសហករណ៍ដោយអស់ពីចិត្តពីថ្លើម។ ក្រៅពីនេះកុមារនៅបានចូលរួមប្រាស្រ័យកាប់ដី លើកដី ដញ្ជូនដី ធ្វើទំនប់ជីកប្រឡាយ ជីកស្រះ ធ្វើអាងទឹក ដោះស្រាយរកទឹកបង្កបង្កើនផលយ៉ាងសស្រាក់សស្រាំទាំងយប់ទាំងថ្ងៃដូចតែមនុស្សចាស់ដែរ។ សកម្មភាពទាំងនេះរបស់កុមារ ក្នុងក្រុមសហករណ៍សុទ្ធតែជាវិភាគទានយ៉ាងសំខាន់មួយ ដែលបម្រើនឹងជំរុញចលនាបង្កបង្កើនផលឧបត្ថម្ភសង្គ្រាមបដិវត្តន៍ឲ្យផុសផុលខ្លាំងក្លាជានិច្ច។

កុមារខ្លះទៀត បានធ្វើជានីរសាររត់សំបុត្រចុះឡើង ឬជានីរសារនាំផ្លូវកម្មាភិបាល ដែលចេញដើរធ្វើការងារពីកន្លែងមួយទៅកន្លែងមួយ ពីមន្ទីរមួយទៅមន្ទីរមួយ ពីមូលដ្ឋានមួយទៅមូលដ្ឋានមួយទៀត។ កុមារខ្លះទៀត បានធ្វើជាកងឈ្លបជួយយាមកាមតាមផ្លូវការពារសន្តិសុខភូមិឃុំ ដោយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុត។ ហេតុនេះហើយបានជាកុមារឈ្លបយើងតែចាប់បានគិញ ភ្នាក់ងារចារកម្ម ឬសន្តិសុខសម្ព័ន្ធរបស់ខ្មាំង ដែលបន្លំខ្លួនចូលមកក្នុងភូមិឃុំបង្កប់ខ្លួននៅតាមព្រៃ ដើម្បីធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍ និងប្រជាជនយើងជាញឹកញាប់។



នៅសមរភូមិមុខ កុមារយើងបានចូលក្នុងជួរកងទ័ពរួមប្រយុទ្ធវាយកម្ទេចខ្មាំងជាមួយពូៗបងៗឯទៀតយ៉ាងអង់អាចក្លាហានបំផុត ពុះពារខបសគ្គឆ្លងកាត់គ្រោះថ្នាក់នឹងការលំបាកវេទនាអត់ឃ្លាន ឈឺថ្កាត់ គ្មានថ្នាំសង្កូវ ខ្វះសព្វខ្វះគ្រប់ បានដោយជោគជ័យ ដូចតែពូៗបងៗកងទ័ពឯទៀតដែរ។ កុមារនីសារ បានរត់សំបុត្រនាំបញ្ជាពីក្រោយទៅមុខ ពីបញ្ជាការដ្ឋានទៅខ្សែប្រយុទ្ធជួរមុខបំផុត ដោយរត់ផងលូនផងក្រាបផង ឆ្លងកាត់សមរភូមិក្រោមគ្រាប់រំសេវ និងគ្រោះថ្នាក់ច្រើនឥតគណនា។ កុមារដឹកជញ្ជូនដែលពុំទាន់មានកម្លាំងកាយគ្រប់គ្រាន់ ដើម្បីដឹកជញ្ជូនសម្ភារធ្ងន់ៗ ក៏បានបររទេះគោរទេះក្របី ធាក់កង់ អូសរ៉ឺម៉ក បើកឡាន បើកកាណូតចែវទូក ក្រោមគ្រាប់រំសេវប្រសាច បីដូចគ្រាប់ភ្លៀងឆ្លងកាត់គ្រោះថ្នាក់ច្រើនរាប់មិនអស់ ដើម្បីដឹកជញ្ជូនស្បៀងអាហារបាយទឹក គ្រាប់រំសេវ និងសម្ភារជាចាំបាច់ផ្សេងៗទៅផ្តល់ជូនកងទ័ពនៅសមរភូមិមុខ បានយ៉ាងទៀងទាត់ ពុំដែលអាក់ខានឡើយ ទោះបីជាខ្មាំងបាញ់រះ ទម្លាក់គ្រាប់បែក ឬបាញ់ផ្លោង បាញ់ផ្តក់កាត់ផ្លូវគោកផ្លូវទឹក ទាំងយប់ទាំងថ្ងៃយ៉ាងណាក្តី។ល។

ទាំងអស់នេះសុទ្ធសឹងជាសកម្មភាពប្រកបដោយវីរភាពបដិវត្តន៍ខ្ពង់ខ្ពស់បំផុតរបស់កុមារកម្ពុជាយើង ក្នុងសម័យធ្វើសង្គ្រាមបដិវត្តន៍ប្រឆាំង និងវាយកម្ទេចនូវសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារ។

ឥឡូវមាតុភូមិកម្ពុជាជាទីស្នេហា ត្រូវបានរំដោះ ទាំងស្រុង និងជាស្ថាពរហើយ។ សន្តិភាពក៏ត្រូវបានកើតមានឡើងវិញនៅលើទឹកដីកម្ពុជាយើង។ កុមារបដិវត្តន៍យើងដែលទើបចេញផុតពីភ្នក់ភ្លើងសង្គ្រាម ក៏បានរួមចំណែកយ៉ាងសកម្មមមាញឹក ជាមួយពុកម៉ែ ប្រជាជនទូទាំងប្រទេស ព្រមទាំងពូៗកងទ័ពគ្រប់អង្គភាពក្នុងកិច្ចការប្រទេស និងកសាង



កុមារ និងយុវជន ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីមាគ៌ាដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា

កម្ពុជាថ្មីឲ្យខ្លាំងក្លាសម្បូរសប្បាយ ថ្កុំថ្កើង រុងរឿង យ៉ាងសស្រាក់សស្រាំទាំងយប់ទាំងថ្ងៃ និងដោយគោលជំហរឯករាជ្យម្ចាស់ការខ្លួន ខបត្តម្ភខ្លួនយ៉ាងរឹងប៉ឹងជាបន្តទៀត។

នៅតាមគ្រប់មូលដ្ឋានគ្រប់កសិដ្ឋាន និងគ្រប់ការដ្ឋាន គេឃើញកុមារទាំងក្រុមៗ ចុះប្រឡូករួមធ្វើគ្រប់ភារកិច្ចជាមួយនឹងមនុស្សវ័យចាស់យ៉ាងសកម្មប្រយុទ្ធមមាញឹកជារៀងរាល់ថ្ងៃ។ នៅជនបទស្រែចម្ការកុមារជួយកាប់រានដីថ្មីៗ កុមារហាត់រៀនភ្ជួររាស់ កុមារខ្លះជួយដកស្ទូង កុមារខ្លះជួយរែក ឬដឹកសំណាប និងកុមារខ្លះទៀតឃ្វាលគោក្របី។ ក្រៅពីនេះទៀត កុមារយើង នៅបានរួមប្រាស្រ័យយ៉ាងសកម្មក្នុងចលនាលើកទំនប់ជីកប្រឡាយ លើកភ្លឺស្រែ ដើម្បីដោះស្រាយបញ្ហាទឹក រក្សាទឹក និងសន្សំទឹកទុកធ្វើស្រែ។ កុមារខ្លះកាប់ដី កុមារខ្លះទៀតជួយជញ្ជូនដី កុមារខ្លះទៀតជួយពូនដី បុកបង្ហាប់ដីយ៉ាងស្វាហាប់។

នៅតាមកសិដ្ឋាន កុមារជួយថែសួនបន្លែដោយ រែកទឹកស្រោច ដាក់ដី បោចស្មៅ បេះសត្វល្អិត ឬដង្កូវដែលស៊ីបំផ្លាញផលដំណាំ។ ក្រៅពីនេះ កុមារ បានចញ្ចឹមជ្រូកមាន់ទាថែទាំឲ្យចំណី ទឹកយ៉ាងទៀង ទាត់ ធ្វើទ្រុងមាន់ ទ្រុងទា ហើយថែទាំបោសសម្អាត យកលាមកសត្វធ្វើជីដាក់បន្លែផង និងរក្សាអនាម័យជានិច្ចកុំឲ្យសត្វឈឺផង។

នៅតាមការដ្ឋាននានា ដូចជាការដ្ឋានធ្វើផ្លូវ សង់ ស្ពានធ្វើផ្លូវរទេះភ្លើង និងសំណង់ផ្សេងៗ ក៏គេឃើញមានកុមារចូលរួមធ្វើសកម្មភាពទៅតាមលទ្ធភាព និងកម្លាំងកាយរបស់ខ្លួនដែរ។ នៅតាមរោងចក្រ និងរោងជាងនានា គេឃើញមានកុមារធ្វើជាកម្មករបញ្ឆោម៉ាស៊ីនតូចធំយ៉ាងស្ទាត់ជំនាញ ឬជួយខ្ចប់ជួយប្រមូលផលិតផលក្នុងរោងចក្រ ឬមួយទៀតជួយយាមការពារសន្តិសុខរោងចក្រ ដោយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុត មិនឲ្យខ្មាំងសត្រូវណាចូលមកយាយី ឬ



កងកុមារកំពុងសែងដីចាក់ទំនប់

ធ្វើវិច្ឆេទកម្មបំផ្លិចបំផ្លាញបានឡើយ។

នៅក្នុងទីក្រុងក៏គេសង្កេតឃើញកុមារជួយបោសសម្អាតផ្លូវថ្នល់ ជួយរៀបចំផ្ទះសម្បែង ថែទាំសម្អាត ទីក្រុង និងជួយយាមកាមការពារសន្តិទីក្រុងដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតដែរ។

ទន្ទឹមនឹងសកម្មភាពធ្វើការងារពលកម្មបង្កបង្កើនផលការពារប្រទេស និងកសាងប្រទេសខាងលើនេះ កុមារយើងបានរៀនសូត្រវប្បធម៌ដើម្បីកសាង និងបង្កើនសមត្ថភាពវប្បធម៌ខ្លួនផងដែរ។ ការណ៍នេះធ្វើទៅបាន គឺអាស្រ័យមានការចាត់តាំងផ្លាស់វេនគ្នាធ្វើការ និងរៀនសូត្រជាបន្តបន្ទាប់។ ពេលយប់ទំនេរ កុមារនៅបានទទួលការអប់រំរៀនសូត្រនយោបាយ សតិអារម្មណ៍ចាត់តាំងបដិវត្តន៍ មានប្រជុំជីវភាពត្រួតពិនិត្យ ជួយកសាងគោលជំហរបដិវត្តន៍គ្នា និងដកពិសោធន៍ខុសត្រូវលើការងារដែលបានធ្វើក្នុងមួយថ្ងៃៗកន្លងមក។

អាស្រ័យហេតុនេះហើយ បានជាគេសង្កេតឃើញកុមារក្នុងសម័យកម្ពុជាថ្មីយើងនេះ ពិតមែនតែនៅតូចទេតែមានរបៀបរៀបរយ ចេះស្រឡាញ់ការងារពលកម្ម ចេះគោរពអង្គការវិន័យ ដោយភ្ញាក់រឭក ចេះស្រឡាញ់រាប់អានគ្នាសាមគ្គីគ្នារវៀងកុមារនឹងកុមារ ទាំងក្នុងការរស់នៅក៏ដូចក្នុងការងារប្រចាំថ្ងៃ ពុំដែលមានទើសទែងឈ្លោះប្រកែកគ្នាជេរប្រទេចគ្នា ឬវាយតប់គ្នាដូចកុមារក្នុងសង្គមចាស់ឡើយ។ ក្នុងគ្រប់កិច្ចការដែលជាភារកិច្ចរបស់ខ្លួន កុមារតែងយកចិត្តទុកដាក់ខិតខំធ្វើ ខិតខំបំពេញដោយស្មារតីទទួលខុសត្រូវខ្ពស់និងគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនខបត្តម្ភខ្លួនគ្មានពឹងផ្អែកឬទម្រន់ចាំម៉ែឪ មីងមា យាយតាណាមកជួយឡើយ។ ព្រមជាមួយនេះ កុមារយើងក៏មានស្មារតីច្នៃប្រឌិតកសាងរស់រវើក ក្នុងការសម្រេចភារកិច្ចរបស់ខ្លួនទៀតផង។

បច្ចុប្បន្ននេះ ពិតមែនតែជីវភាពក្មួយទាំងឡាយមិនទាន់បានសម្បូរសប្បាយនៅឡើយទេ តែជីវភាពក្មួយៗមានការធានាមួយរយភាគរយហើយ ព្រោះក្មួយៗរស់នៅក្នុងសង្គមកម្ពុជាថ្មីដែលស្អាតស្អំយុត្តិធម៌គ្មានមនុស្សជិះជាន់មនុស្សគ្មានអំពើពុករលួយពាលាអាវ៉ាសែ និងអំពើអបាយមុខផ្សេងៗទៀតឡើយ។ ជាសង្គមដែលមនុស្សទាំងអស់ ទាំងនារី ទាំងបុរស ទាំងមនុស្សវ័យចាស់ ទាំងកុមាររស់នៅស្មើភាពគ្នា ហើយទាំងអស់គ្នា ចុះប្រឡូកធ្វើពលកម្មបង្កបង្កើនផលកសាងប្រទេស និងការពារប្រទេសក្នុងសេចក្តីថ្លៃថ្នូរ និងកិត្តិយសថ្លៃថ្លារុងរឿងបំផុត។ អនាគតភ្លឺស្វាង រះចាំងចែងនៅពីមុខក្មួយទាំងឡាយ។ ក្មួយទាំងឡាយអស់ភ័យគិត ឬព្រួយបារម្ភពីរឿងកំព្រាឯកោអនាថា អស់ភ័យគិតពីរឿងធំឡើងអត់ការធ្វើ អស់ភ័យគិតពីរឿងអត់ឃ្លានដាច់ពោះស្លាប់ អស់ភ័យគិតពីរឿងមិនចេះអក្សរ ឬធ្លាក់ខ្លួនទៅក្នុងអំពើអបាយមុខទៀតឡើយ។ ក្នុងសង្គមកម្ពុជាថ្មីនេះ ក្មួយៗកុមារពិតជា នឹងបានរស់នៅរីកធំធាត់ ចម្រើនលូតលាស់ក្នុងសុភមង្គលថ្លៃថ្លាបរិសុទ្ធ និងមានកិត្តិនាម កិត្តិសព្ទល្អ ជាអ្នកស្នេហាជាតិស្នេហាប្រជាជន ជាអ្នកបម្រើប្រទេសជាតិ បម្រើប្រជាជនយ៉ាងស្មោះសរបំផុត និងជាអ្នកកសាងស្ថាបនាកម្ពុជាថ្មី ឲ្យបានកាន់តែខ្លាំងក្លា និងសម្បូរសប្បាយថ្កុំថ្កើងរុងរឿង ថែមទៀតជាលំដាប់។

ការអប់រំរៀនសូត្រដោយជាប់នឹងការងារពលកម្មផលិតយ៉ាងដូច្នេះ ធ្វើឲ្យកុមារយើងមានការរីកចម្រើនព្រមជាមួយទាំងរូបរាងកាយ ទាំងស្មារតី ទាំងគំនិតបញ្ញា ទាំងគោលជំហរបដិវត្តន៍ គឺគោលជំហរស្នេហាជាតិ ស្នេហាបដិវត្តន៍ ស្នេហាប្រជាជន ស្រឡាញ់ពលកម្ម គោរពអង្គការវិន័យ ស្រឡាញ់និងគោរពសមូហភាព។ល។ ទាំងសមត្ថភាពការងារបម្រើប្រទេស ជាតិ កសាងប្រទេសជាតិ និងការពារប្រទេសជាតិជាលំដាប់ផង។ ការអប់រំកសាងកុមារបែបនេះ វាធានាឲ្យកុមារកម្ពុជាយើងរីកចម្រើនលូតលាស់ ហើយធ្វើដំណើរយ៉ាងត្រឹមត្រូវតាមមាគ៌ាបដិវត្តន៍ដ៏ត្រឹមត្រូវ និងភ្លឺស្វាង វាធានាឲ្យកុមារកម្ពុជា យើងបន្តវេនបដិវត្តន៍ ការពារប្រទេស និងកសាងប្រទេសតទៅអនាគតទៀត ឲ្យបានគង់វង្សស្ថិតស្ថេរ ខ្លាំងក្លា និងសម្បូរសប្បាយថ្កុំថ្កើងរុងរឿងតរៀងទៅដោយជោគជ័យទាំងស្រុង។

# ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ
# របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅអគារ H
នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។


សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរស័ព្ទលេខ៖ ០២៣ ២១១ ៨៧៥
អ៊ីម៉ែល៖ truthchenda.s@dccam.org

# កុមារក្រោមភ្នែកអង្គការ

«ក្រោក! ក្រោក! ងើបឡើង! ងើបឡើង! ដល់ម៉ោងទៅធ្វើការហើយ» គឺជាការដាស់ឲ្យក្រោកពីដំណេកយ៉ាងរន្ថើនពីសំណាក់មេកងខ្មែរក្រហម ដើម្បីឲ្យកុមារទាំងអស់ ដែលកំពុងលង់លក់ក្នុងដំណេកយ៉ាងស្កប់ស្កល់ក្រោកឡើងដើម្បីទៅធ្វើការងារៗ ក្នុងចំណោមកុមារអភ័ព្វទាំងអស់នោះ ក៏មានម្តាយខ្ញុំម្នាក់ដែរៗ ទាំងអស់នេះវាផ្ទុយពីអ្វីដែលខ្ញុំធ្លាប់ឆ្លងកាត់ នៅពេលដែលខ្ញុំស្ថិតក្នុងវ័យកុមារ ដែលមានអាយុស្របាលនឹងម្តាយរបស់ខ្ញុំនាពេលនោះៗ សំឡេងដែលដាស់ខ្ញុំមិនមែនជាសំឡេងដែលបង្ខំខ្ញុំឲ្យក្រោកឡើងទៅធ្វើការងារនោះទេ ប៉ុន្តែវាគឺការដាស់ថ្នមៗ ជាមួយនឹងសំឡេងស្រទន់ឲ្យខ្ញុំក្រោកឡើង ស្រូតងូតទឹកស្លៀកពាក់ និងញ៉ាំអាហារពេលព្រឹកមុនទៅសាលារៀនៗ

មុនរបបខ្មែរក្រហម ម្តាយខ្ញុំ និងគ្រួសាររបស់គាត់រស់នៅឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាលៗ ក្រោយថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារម្តាយខ្ញុំ ត្រូវបានខ្មែរក្រហមជម្លៀសទៅរស់នៅ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ដែលជាទីដែលគាត់ត្រូវរៀនរស់នៅឆ្ងាយពីឪពុកម្តាយៗ អង្គការខ្មែរក្រហមបានចាត់គាត់ឲ្យចូល និងរស់នៅក្នុងមន្ទីរកុមារវត្តក្វានៗ អ្វីដែលគាត់ចាំមិនភ្លេចពេលដែលគាត់ទៅដល់ស្រុកកណ្តៀងដំបូងនោះ គឺនៅពេលហូបអាហារៗ ខ្មែរក្រហមបានស្ងូសម្លតៅ្នត ដែលទឹកសម្លមានពណ៌ខ្មៅវាល់ចែកអ្នកជម្លៀសទាំងអស់ហូបៗ ម្តាយរបស់ខ្ញុំ និងបងប្អូនប្រុសស្រីដទៃទៀតនាំគ្នាយំយ៉ាងខ្លាំង ព្រោះមិនចេះហូបសម្លបែបនេះទេៗ ប៉ុន្តែមួយសប្តាហ៍ក្រោយមក ទោះបីចេះ ឬមិនចេះហូបសម្លត្នោតនេះ ក៏ត្រូវតែបង្ខំចិត្តហូបដែរ ព្រោះមិនមានអ្វីហូបក្រៅពីសម្លដែលអង្គការស្ងូឲ្យនេះទេៗ ដោយមានការដកពិសោធន៍នេះហើយ ទើបម្តាយខ្ញុំតែងតែបន្ទោសខ្ញុំ និងកូនក្មួយថា «កុំហូបរើសម្ហូបពេក មានម្ហូបគ្រប់មុខយ៉ាងនេះ សំណាងណាស់



ម្តាយរបស់ខ្ញុំ (រាប់ពីឆ្វេងរូបទី២) ថតនៅវត្តក្វាន នាទិវាសថ្ងៃដាក់បិណ្ឌឆ្នាំ២០១៧
គាត់តែងតែទៅធ្វើបុណ្យឧទ្ទិសកុសលដល់បុព្វការីជនដែលបានចែកឋានទៅក្នុងអំឡុងរបបខ្មែរក្រហម នៅវត្តក្វាននេះជារៀងរាល់ឆ្នាំ

មិនដូចគាត់ពេលដែលនៅក្នុងរបប ខ្មែរក្រហមទេ រកតែបាយក្តាំង ឬកម្ទេចសាច់ហូបមិន បានផង។ មិនមែនដូចកូនៗឥឡូវទាល់តែបង្ខំផង បញ្ចុកផង ទើបហូបនោះទេ។»

ម្តាយខ្ញុំ តែងតែរំឭកអំពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមប្រាប់ដល់កូនចៅជានិច្ច បើទោះជាក្មេងៗទាំងនេះមិនដឹងថាអ្វីទៅជារបបខ្មែរក្រហម ម្តាយខ្ញុំបានប្រាប់ថា នៅក្នុងរបបខ្មែរក្រហមបើទោះបីជាយើងជាកុមារក៏ដោយ ក៏ត្រូវធ្វើកិច្ចការដូចមនុស្សពេញវ័យដែរ។ កុមារតូចៗត្រូវដើររើសអាចម៍គោ ឬកាប់ដើមទន្ទ្រានខែត្រ ហើយចំពោះកុមារដែលមានមាឌធំ ត្រូវអង្គការចាត់តាំងឲ្យទៅលើកភ្លឺស្រែ ឃ្វាលគោ ឬរែកដី ដូចមនុស្សពេញវ័យដែរ។ នៅពេលនោះគ្មានសាលារៀនសម្រាប់កុមាររៀនសូត្រនោះទេ ហើយអង្គការក៏បានប្រាប់ដែរថា សាលារៀន គឺមានតែនៅស្រែ ប្រឡាយទំនប់ និងការដ្ឋានការងារតែប៉ុណ្ណោះ។

មន្ទីរកុមារវត្តក្វាន បានចែកកុមារជាពីរប្រភេទគឺ កុមារដែលមានអាយុក្រោម៩ឆ្នាំ ត្រូវធ្វើការងារដូចជា រើសអាចម៍គោ និងកាប់ទន្ទ្រានខែត្រជាដើម ចំណែកកុមារដែលមានអាយុជាង៩ឆ្នាំ ត្រូវបានអង្គការចាត់ ទុកជាកុមារឈានមុខដែលអាចធ្វើការងារមួយចំនួនដូចមនុស្សធំបាន។ ម្តាយខ្ញុំនៅពេលនោះមានវ័យជាង១០ឆ្នាំ ត្រូវបានអង្គការចាត់ចូលជាកុមារឈានមុខ។ ដំបូងអង្គការបានចាត់គាត់ឲ្យកាត់ដើមទន្ទ្រាន ខែត្រធ្វើជី។ កន្លះឆ្នាំក្រោយមក គាត់ត្រូវអង្គការផ្លាស់ឲ្យមកធ្វើនៅខាងសេដ្ឋកិច្ចប្រចាំមន្ទីរកុមារ ដោយមាននាទីជាអ្នកដាំបាយ និងធ្វើម្ហូប។ មួយរយៈក្រោយ អង្គការបានផ្លាស់ម្តាយខ្ញុំមកឲ្យមើលជ្រូក (ថែ និងដាក់បាយជ្រូក) និងដាំដំណាំ។ ចុងឆ្នាំ១៩៧៨ អង្គការបានផ្លាស់ឲ្យទៅស្ទូងដកនៅទួលម្កាក់។ គាត់បានរស់នៅ និងធ្វើការងារដកស្ទូងនៅទួលម្កាក់ រហូតដល់របបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩។

ម្តាយខ្ញុំបន្តទៀតថា រៀងរាល់ព្រឹកព្រលឹម គាត់ក៏ដូចជាកុមារឯទៀត ត្រូវមេកងកុមារដាស់ឲ្យក្រោកទៅធ្វើការទាំងម្នាក់ៗមិនទាន់អស់ងងុយ។ អ្នកដែលក្រោកមិនទាន់ ឬយឺតយ៉ាវ ត្រូវមេកងយករំពាត់ផ្តៅវាយ ឬយកភ្លើងអុជជើងជាដើម។ កុមារទាំងអស់មិនទទួលបានអាហារពេលព្រឹកនោះទេ គឺធ្វើការរហូតដល់ពេលថ្ងៃត្រង់ទើបបានហូប។

ម្តាយខ្ញុំបានរំឭកទៀតថា កុមារទាំងអស់ត្រូវអង្គការដាក់ឲ្យរស់នៅក្នុងមន្ទីរកុមារ ហើយកុមារទាំងនេះ មិនដែលទទួលបានការមើលថែពីឪពុកម្តាយនោះទេ។ ពេលព្រឹកកុមារទាំងអស់ត្រូវងើបទៅធ្វើការ និងល្ងាចត្រឡប់មកសម្រាកនៅកងកុមារវិញ។ កុមារណាដែលលួចរត់ទៅជួបឪពុកម្តាយដោយគ្មានការអនុញ្ញាត ត្រូវតែទទួលពិន័យដាក់ជាពុំខាន។ អង្គការក៏បានប្រាប់ទៀតថា «មានតែអង្គការមួយគត់ ដែលជាឪពុកម្តាយរបស់កុមារទាំងអស់គ្នា។ ហេតុនេះ យើងជាកុមារត្រូវតែស្រឡាញ់ និងស្មោះត្រង់ចំពោះអង្គការតែមួយគត់»។ ម្តាយខ្ញុំនៅចាំទៀតថា អង្គការបានបញ្ចុះបញ្ចូលកុមារឲ្យនិយាយរឿងឪពុកម្តាយរបស់ខ្លួនប្រាប់អង្គការ។ ដោយស្ថិតក្នុងវ័យជាកុមារមិនយល់រាក់ជ្រៅ កុមារខ្លះបានប្រាប់ដល់អង្គការគ្រប់រឿងដែលខ្លួនបានដឹងពីអតីតភាពរបស់ឪពុកម្តាយ។ គ្រួសារមួយចំនួន ត្រូវខ្មែរក្រហមយកទៅកម្ទេចបន្ទាប់ពីកូនៗរបស់ខ្លួនបានរាយការណ៍ឲ្យអង្គការ។ ចំណែកម្តាយរបស់ខ្ញុំ ក៏ដូចជាបងប្អូនឯទៀត មិនដែលហ៊ាននិយាយអំពីការងាររបស់ឪពុកម្តាយគាត់ កាលពីសង្គមមុននោះទេ។

គាត់បន្តថា នៅពេលមកដល់ស្រុកកណ្តៀងដំបូង ជីតារបស់ខ្ញុំបានប្រាប់គាត់ថា បើមានអ្នកណាសួរថា ឪពុកធ្វើការងារអ្វីពីមុនមកឲ្យប្រាប់គេថា «គាត់ជាជាងប៉ះកង់ទៅបានហើយ»។ ជីតាខ្ញុំជាមន្ត្រីរាជការមួយរូបក្នុងរបបសាធារណរដ្ឋខ្មែរ។ គាត់មានការយល់ដឹងច្រើនពីមនោគមន៍វិជ្ជា និងនយោបាយរបស់ខ្មែរក្រហម។ ហេតុនេះជីតារបស់ខ្ញុំតែងតែប្រយ័ត្នប្រយែង ជានិច្ចចំពោះខ្មែរក្រហមទើបគាត់ និងគ្រួសារអាចរក្សាជីវិតរហូតរបបយង់ឃ្នងនេះដួលរលំ។

អ្វីដែលគាត់រៀបរាប់ប្រាប់ខ្ញុំនាពេលនេះ គ្រាន់តែជាផ្នែកតូចមួយនៃជីវិតដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ។ នៅទិដ្ឋភាពជាច្រើនទៀត ដែលគាត់រៀប

រាប់មិនអស់ចំពោះសកម្មភាព និងអំពើដែលខ្មែរក្រហម បាន ប្រព្រឹត្តមកលើគ្រួសារម្តាយខ្ញុំផ្ទាល់ និងប្រជាជនដទៃទៀតៗ

កុមារភាពរបស់ម្តាយខ្ញុំ នៅក្នុងរបបខ្មែរក្រហមដែល បានលើកឡើងខាងលើ បានបញ្ជាក់ឲ្យឃើញថា ក្នុងរបប កម្ពុជាប្រជាធិបតេយ្យ ឬហៅថា របបខ្មែរក្រហម សិទ្ធិជា មូលដ្ឋានរបស់កុមារមិនត្រូវបានអនុវត្ត ហើយថែមទាំងបាន លុបបំបាត់ទាំងស្រុងៗ នៅក្រោមភ្នែកអង្គការ កុមារទាំង អស់ គឺជាកម្មករ និងជាភ្នាក់ងារសម្ងាត់របស់ខ្លួន និងត្រូវតែ បញ្ចេញកម្លាំងពលកម្មធ្វើការងារដូចមនុស្សពេញវ័យទូទៅ ដើម្បីប្តូរនឹងរបបអាហារដែលមានតែបបររាវៗ ស្ទើររក គ្រាប់អង្ករមិនឃើញ និងត្រូវបានបំបែកចេញពីគ្រួសារៗ

**ទាវ សារៈមុនិន្ទ**



ព្រះវិហារវត្តក្ងាន ឆ្នាំ២០១៧

# កុមារក្នុងរបបខ្មែរក្រហម

បន្ទាប់ពីរបបណាស៊ីសបានដួលរលំ នៅឆ្នាំ១៩៤៥ ប្រទេសភាគច្រើននៅលើពិភពលោក តែងតែប្រារព្ធទិវាកុមារអន្តរជាតិ ក្នុងថ្ងៃទី១ ខែមិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំឭកទៅដល់ព្រឹត្តិការណ៍វិនាសកម្ម ដែលរបបណាស៊ីសបានកាប់សម្លាប់ស្ត្រី និងកុមារ អស់ជាច្រើននៅក្នុងភូមិលីឌីសៃប្រទេសឆែក និងភូមិអូរាឌូ ប្រទេសបារាំងនៅអំឡុងសង្គ្រាមលោកលើទី២។ ខណៈពេលដែលកុមារទូទាំងពិភពលោកកំពុងតែទទួលបានការយកចិត្តទុកដាក់ និងបានឈប់សម្រាកក្នុងថ្ងៃទី១ មិថុនា នោះ កុមារនៅក្នុងប្រទេសកម្ពុជាត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ នៅក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩។

របបខ្មែរក្រហមបានធ្វើឲ្យប្រជាជនប្រមាណ២លាននាក់ បានបាត់បង់ជីវិត ក្នុងនោះកុមារជាច្រើនបានស្លាប់។ កុមារត្រូវបង្ខំឲ្យរស់នៅក្នុងកងកុមារ ដែលស្ថិតនៅឆ្ងាយពីឪពុកម្តាយ និងធ្វើការងារផ្សេងៗដូចជា រើសអាចម៍គោកាត់ទន្ទ្រានខែត្រ ប្រមូលលាមកមនុស្សដើម្បីធ្វើជីដាក់ស្រែ។ រីឯកុមារក្នុងវ័យជំទង់ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការធ្ងន់ហួសកម្លាំង ដូចជា ជីកប្រឡាយ លើកទំនប់ កាប់ឈើ ធ្វើផ្ទះ ធ្វើស្រែចម្ការ និងដឹកជញ្ជូនអាវុធទៅសមរភូមិជាដើម។

នៅក្នុងរបបខ្មែរក្រហម មិនមានសាលាបង្រៀនក្មេងទេ គឺកុមារទទួលបានការបណ្តុះមនោគមវិជ្ជាពី១ទៅ២ម៉ោងក្នុងមួយថ្ងៃ នៅក្រោមដើមឈើ ឬក្រោមផ្ទះប្រជាជន ហើយការអប់រំផ្តោតសំខាន់ទៅលើចលនាបដិវត្តន៍។ កុមារត្រូវខ្មែរក្រហមចាត់តាំងឲ្យចូលបម្រើការងារជាកងឈ្លប និងកងទ័ព។ នៅខណៈពេលដែលខ្មែរក្រហម ធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៧ និងរយៈពេលពេញមួយឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើននាក់បានស្លាប់ និងរបួស ហើយខ្មែរក្រហមបានបញ្ជូនកុមារដែលមិនទាន់គ្រប់អាយុជាច្រើនទៅសមរភូមិ ដើម្បីធ្វើសង្គ្រាមទប់ទល់ជាមួយនឹងកងទ័ពវៀតណាម ជាលទ្ធផលកុមារមិនទាន់គ្រប់អាយុរាប់ពាន់នាក់ បានស្លាប់ និងរងរបួស។

រ៉ាំង សុផៃ ភេទប្រុស អាយុ៥៦ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានរៀបរាប់ថា ខ្មែរក្រហមបានជ្រើសរើសគាត់ឲ្យចូលបម្រើការងារជាកងទ័ព ក្នុងឆ្នាំ១៩៧៣ ខណៈដែលគាត់មានអាយុ១២ឆ្នាំ។ ក្នុងរបបខ្មែរក្រហម សុផៃ ជាកងទ័ពប្រចាំស្រុកកំរៀងក្នុងកងលេខ១៧៣ ហើយគាត់ត្រូវបានចាត់តាំង



ឲ្យទៅការពារព្រំដែនខ្មែរ ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ ក្នុងខេត្តប៉ៃលិន។ ក្រៅពីការងារជាកងទ័ព សុផៃ បានធ្វើស្រែ ដើម្បីផ្គត់ផ្គង់ជីវភាពកងទ័ព និងប្រជាជន ប៉ុន្តែរបបអាហារ នៅតែមានការខ្វះខាត។ សុផៃ បន្តថា នៅពេលដែលគាត់មាន អាយុ១៦ឆ្នាំ(ចុងឆ្នាំ១៩៧៧) ខ្មែរក្រហមបានផ្លាស់គាត់ឲ្យទៅ ទប់ទល់ជាមួយកង ទ័ពវៀតណាមនៅស្រុកស្នួលខេត្តក្រចេះ តែក្នុងពេលនោះគាត់និងក្មេងៗដ៏ទៃទៀតមានតួនាទីរែកបាយ ឲ្យកងទ័ពខ្មែរក្រហម ដែលប្រយុទ្ធនៅលើសមរភូមិមុខ។

ស្រីសូលភេទប្រុសជាកុមារម្នាក់នៅក្នុងរបបខ្មែរក្រហម ដែលក្នុងពេលនោះ សូល មានអាយុត្រឹមតែ ១២ឆ្នាំ នៅពេល ខ្មែរក្រហមចូលមកដល់។ ដំបូង សូល រស់នៅជាមួយឪពុក ម្តាយនៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ និងធ្វើការក្នុង កងកុមារ ដូចជា ឃ្វាលក្របី សែងដី ដឹកដំបូក លើកភ្លឺស្រែហើយទទួលបានរបបអាហារគ្រប់គ្រាន់។ ក្រោយ មក ខ្មែរក្រហមចាប់ផ្តើមបំបែកសមាជិកគ្រួសារមួយៗ ឲ្យ រស់នៅកន្លែងផ្សេងៗគ្នា ហើយ សូល ត្រូវបំបែកចេញពី គ្រួសារឲ្យទៅរស់នៅក្នុងការដ្ឋានត្រពាំងចែង និងចូលធ្វើការ ក្នុងកងចល័តក្រោមការគ្រប់គ្រងរបស់ តា នឿម ដែលជា ប្រធានសហករណ៍។ ស្ថានភាពរស់នៅកាន់តែលំបាកក្នុង ពេលនោះ តា នឿម បានឲ្យ សូល ធ្វើការងារដូចកងយុវជន ដូចជា ភ្ជួរស្រែ ស្ទូង ឃ្វាលក្របី និងបានទទួលរបបអាហារ តែបបរប៉ុណ្ណោះ។ សូល ប្រាប់ថា ដោយសារតែការងារលើស កម្លាំងនិងអាហារមិនគ្រប់គ្រាន់បានធ្វើឲ្យមនុស្សស្លាប់ហើយ ភាគច្រើនគឺកុមារ ដែលមិនអាចគាំទ្រការលំបាកដូចមនុស្ស


កងកុមារ និងកងយុវជន ចូលរួមប្រជុំស្ម័យទិតៀន

ជំទង់ និងមនុស្សចាស់។ សួល បានបញ្ជាក់ថា ខ្លួនមិនបានរៀនសូត្រឡើយក្នុងរបបខ្មែរក្រហម១៩៧៥-១៩៧៩។

រីឯ មាស អេន ភេទស្រី មានអាយុត្រឹមតែ១០ឆ្នាំប៉ុណ្ណោះក្នុងរបបខ្មែរក្រហម។ អេន មានស្រុកកំណើតនៅភូមិរ៉ូង ឃុំល្វែងឫស្សី ស្រុកជីក្រែង ខេត្តសៀមរាប ហើយបច្ចុប្បន្នរស់នៅភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អេន ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការក្នុងកងកុមារស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ ហាប់ ដែលមានវ័យស្រករគាត់ដែរ។ អេន និងក្មេងៗដ៏ទៃទៀត តម្រូវឲ្យចូលរៀនជារៀងរាល់ថ្ងៃជាមួយគ្រូឈ្មោះ លៀម រយៈពេល១ម៉ោង បន្ទាប់ពីពេលបាយថ្ងៃត្រង់ នៅតាមម្លប់ឈើដោយរៀនសរសេរតែលេខសូន្យ ឬលេខ១តែប៉ុណ្ណោះក្នុងមួយថ្ងៃៗ មុនពេលចេញទៅរែកអាចម៍គោ។

ចំពោះ ឡាច ថៃ ភេទស្រី សព្វថ្ងៃមានអាយុ៥៣ ឆ្នាំ រស់នៅភូមិថ្មល់ទទឹង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានប្រាប់ថា នៅក្នុងសម័យខ្មែរក្រហម គាត់រស់នៅក្នុងកងចល័តកុមារ ហើយបានរៀនសូត្រតែ១ម៉ោងប៉ុណ្ណោះក្នុង១ថ្ងៃ ហើយរៀននៅតាមម្លប់ឈើ ក្រោមផ្ទះ ដោយគ្មានប៊ិចនិងសៀវភៅសម្រាប់សរសេរទេ។ ក្រៅពីរៀនគាត់ត្រូវទៅរែកដីក្នុងមួយថ្ងៃឲ្យបាន៥០អម្រែកតាមការកំណត់ ក្រៅពីការងាររែកដីគឺត្រូវធ្វើបន្លែថែមទៀត។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ប្រជាជនដែលនៅរស់រានមានជីវិតប្រហែលជា៧០ភាគរយ គឺជាស្ត្រីមេម៉ាយ និងបានបន្សល់ទុកកុមារកំព្រាប្រហែល ២០០.០០០ នាក់ ដកស្រង់ចេញពីសៀវភៅ «ឧក្រិដ្ឋកម្មបនវាតទីអនុត្តរភាពនិយមចិនប៉េកាំង និងបរិវារ» ពីព្រោះនៅក្នុងរបបខ្មែរក្រហម បុរសភាគច្រើនត្រូវបានស្លាប់ដោយសារ ការសម្លាប់ ការធ្វើទារុណកម្ម ជំងឺ អត់អាហារ និងស្លាប់ក្នុងសមរភូមិ។ កុមារបានជួបនឹងឧបសគ្គជាច្រើនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ កុមារមួយចំនួនត្រូវជួយម្តាយមេម៉ាយក្នុងការប្រកបរបរចិញ្ចឹមគ្រួសារ និងមិនមានឱកាស ក្នុងកាបន្តការសិក្សារៀនសូត្រឡើងវិញឡើយ។

**អ៊ុន សុដាវី**



សិស្សានុសិស្ស និងគ្រូបង្រៀននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

# ម៉ន ញ៉ន ៖ អតីតប្រធានយោធាកងវរសេនាតូច ក្លាយជាជាងកាត់សក់របស់ កែ ពក

ម៉ន ញ៉ន មានស្រុកកំណើតនៅភូមិស្ពឺ(ក) ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម។ ឪពុកឈ្មោះ ម៉ន (ស្លាប់ក្នុងរបប ប៉ុល ពត) និងម្តាយឈ្មោះ វី (ស្លាប់ក្រោយរបប ប៉ុល ពត ដួលរលំ) ព្រមទាំងមានប្រពន្ធឈ្មោះ វ៉ាត ថេង និងមានកូនប្រាំនាក់។ កាលពីសង្គមចាស់ ញ៉ន រៀនបានត្រឹមថ្នាក់ទី៨ នៅសាលាថ្មូ ក្នុងភូមិស្ពឺ ប្រហែលបួនឆ្នាំ ក៏ឈប់រៀនដោយសារមានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីតំណែងដោយសេនាប្រមុខ លន់ នល់ ក្នុងឆ្នាំ១៩៧០។ បន្ទាប់ពី ញ៉ន ឈប់រៀនគាត់ក៏បានជួយឃ្វាលគោក្របី និងធ្វើស្រែចម្ការជំនួសឪពុកម្តាយ។

រហូតដល់ឆ្នាំ១៩៧៣ ញ៉ន ត្រូវបានខ្មែរក្រហមកេណ្ឌឲ្យចូលបម្រើកងទ័ពរំដោះ (យោធាខ្មែរក្រហម) ប្រសិនបើគាត់មិនយល់ព្រមទេ ច្បាស់ជាខ្មែរក្រហមចាប់គាត់ដាក់គុកជាមិនខាន។ ញ៉ន បានចាញ់ការឃោសនារបស់ខ្មែរក្រហមថានឹងផ្តួលរំលំរដ្ឋាភិបាល លន់ នល់ ហើយនាំសម្តេច នរោត្តម សីហនុ មកកាន់អំណាចវិញ។ កាលណោះ ក៏មានប្អូនប្រុសរបស់គាត់ ឈ្មោះ ញ៉ាន និងប្រជាជន២០នាក់ផ្សេងទៀត បានចូលបម្រើជាកងទ័ពខ្មែរក្រហមដូច ញ៉ន ដែរ។

មួយរយៈក្រោយមក ញ៉ន ត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅវាយជាមួយកងទ័ពរដ្ឋាភិបាល លន់ នល់ ក្នុងខេត្តកំពង់ចាម ដោយមិនមានការបង្ហាត់បង្រៀន ឬហ្វឹកហាត់ពីយុទ្ធសាស្ត្រកងទ័ពពីមុនមកទេ។ ដល់ឆ្នាំ១៩៧៤ ញ៉ន បានក្លាយជាប្រធានយោធានៃកងវរសេនាតូចលេខ៧១២ វរសេនាធំលេខ៥៥ កងពលទី១ ហើយក៏ចូលជាបក្សជនពេញសិទ្ធិនៅភូមិចុង (ថ្នល់កែង) ក្នុងស្រុកបាធាយ តាមរយៈ អឿន ជាប្រធានកងពល។ ញ៉ន បានបញ្ជាក់ថា អ្នកដែលអាចចូលជាបក្សជនពេញសិទ្ធិបានលុះត្រាតែអ្នកទាំងនោះមានឋានៈ តួនាទីចាប់ពីប្រធានអនុសេនាធំឡើងទៅ។ ក្រោយមក ញ៉ន បានធ្វើសកម្មភាពប្រយុទ្ធជាមួយ កងទ័ពរដ្ឋាភិបាល លន់ នល់ ដោយវាយសម្រុកចូល តាមស្រុកខងុត្ត ត្រពាំងពាយ ភូមិធំពាមតាម៉ោក រហូតដល់ទីក្រុងភ្នំពេញ ដោយដឹកនាំកងទ័ព១៥០០នាក់។ ញ៉ន បានធ្វើសកម្មទាំងនេះរហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ញ៉ន និងអង្គភាពត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើស្រែនៅ តំបន់កប់ស្រូវ ជាយក្រុងភ្នំពេញ។ ប្រហែលជានៅចុងឆ្នាំ១៩៧៦ ញ៉ន និងមេបញ្ជាការកងអនុសេនាធំ វរសេនាតូច វរសេនាធំ ទាំងអស់នៅក្នុងកងពលទី១ ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា ជាខ្សែក្បត់របស់ កុយ ធួន, អឿន, ហ៊ូ នឹម និង ហ៊ូ យន់។ ភ្លាមនោះ ខ្មែរក្រហមបានចាប់ ញ៉ន ដាក់គុក របស់កងពល៣១០ នៅក្បែរវត្តភ្នំ។ ពេលនោះ ខ្មែរក្រហមបានធ្វើទារុណកម្មដោយវាយដំទាត់ធាក់ និងយករំពាត់ខ្សែតីវាយ ដើម្បីសួរចម្លើយរកខ្សែរយៈបក្ខពួកក្បត់របស់ ញ៉ន ផ្សេងទៀត។

ញ៉ន បានបន្តថា កាលនោះ មានអ្នកជាប់គុកជាច្រើនដែលត្រូវបានខ្មែរក្រហមចោទថា ជាខ្សែក្បត់បដិវត្តន៍ ត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាទៅតាមឋានន្តរស័ក្តិខុសៗគ្នា។ មួយខែក្រោយមក ខ្មែរក្រហមបានឲ្យអ្នកទោសទាំងអស់ងូតទឹកសម្អាតខ្លួននៅមាត់ទន្លេក្បែរដើមពោធិ៍ជិតវត្តភ្នំ ហើយវាក៏ជាឱកាសដ៏ល្អមួយសម្រាប់ញ៉នក៏ដូចជាអ្នកទោសផ្សេងទៀតក្នុងការរត់គេចខ្លួនដែរ។ ភ្លាមៗនោះ ញ៉ន និងអ្នកទោសដទៃទៀត ក៏បាននាំគ្នាហែលទឹកគេចពីខ្មែរក្រហមពីត្រើយមុខព្រះបរមរាជវាំង ហើយបណ្តែតខ្លួនទៅតាមទឹក ឆ្ពោះទៅ

ត្រើយខាងកំពង់អុស ក្នុងស្រុកពញាឮ ខេត្តកណ្តាល។ ប៉ុន្តែជាកុសលការរត់គេចខ្លួននេះមានតែពីរនាក់ប៉ុណ្ណោះ ដែលគេចផុតពីខ្មែរក្រហមតាមចាប់ គឺមាន ញ៉ឹន និង ក្តី ហើយក្រោពីនេះ អ្នកទាំងនោះត្រូវបានខ្មែរក្រហមនាំយកទៅវិញ។ ញ៉ឹន បានបន្តថា នៅពេលដែលគាត់បានទៅដល់លើគោកភ្លាមគាត់ក៏បានដោះដូរនាឡិការបស់គាត់ជាមួយនឹងកង់របស់ប្រជាជនដែលរស់នៅក្នុងភូមិកំពង់អុស ដើម្បីធ្វើជាមធ្យោបាយបន្តដំណើរតទៅមុខទៀត។

ក្រោយមក ញ៉ឹន និង ក្តី បានបន្តដំណើរដោយជិះកង់ឌុបគ្នាឆ្ពោះទៅស្រុកកំណើតរបស់ ញ៉ឹន ស្រាប់តែពេលនោះអ្នកទាំងពីរក៏ប្រទះឃើញកងទ័ពទៅពីភ្នំពេញមកតាមចាប់ទៀត។ ញ៉ឹន និង ក្តី ក៏បានជិះកង់គេចខ្លួនបន្តទៀតរហូតដល់តាំងគោក ក្នុងខេត្តកំពង់ធំ (តំបន់៤៣) ក៏បានបែកគ្នា។ ញ៉ឹន បានស្នាក់ នៅបន្ទំជួយធ្វើស្រែប្រជាជន នៅតាំងគោកមួយរយៈក្រោយមកក៏មានឱកាសរត់គេចខ្លួនម្តងទៀត រួចបានភៀសខ្លួនទៅផ្ទះជីតា ដែលជាភូមិកំណើតរបស់គាត់ដើម្បីសុំស្នាក់អាស្រ័យមួយរយៈពេលខ្លី។ ប៉ុន្មានថ្ងៃក្រោយមក ខ្មែរក្រហមបានស៊ើបដឹងថា ញ៉ឹន កំពុងរស់នៅក្នុងភូមិរបស់ខ្លួនក៏បានចាត់តាំងកងកម្លាំងជាចុរិននាក់ដឹម្បីទាសាកសួរកឈ្មោះ ញ៉ឹន ដើម្បីចាប់ខ្លួន។ ពេលនោះ ជីតារបស់ ញ៉ឹន



ម៉ឹន ញ៉ឹន

បានឮដំណឹង ថា ខ្មែរក្រហមកំពុងតាមរកចៅរបស់គាត់ ទើបគាត់ បានឲ្យ ញ៉ិន ទៅពួននៅលើដំបូលផ្ទះរបស់គាត់អស់រយៈពេលប្រហែលមួយសប្តាហ៍ ទើបខ្មែរក្រហមវិលត្រឡប់ទៅវិញ។ តមកទៀត ញ៉ិន បានសម្រេចចិត្តរត់គេចខ្លួនទៅស្រុកបារាយណ៍ ក្នុងខេត្តកំពង់ធំ ដើម្បីលាក់ប្រវត្តិរបស់ខ្លួន និងក្លែងបន្លំធ្វើជាប្រជាជនធម្មតារស់នៅទីនោះ។ ប៉ុន្តែ មិនយូរប៉ុន្មាន ក៏ត្រូវបានខ្មែរក្រហមស៊ើបដឹងពីជីវប្រវត្តិរបស់ ញ៉ិន ហើយបានតាមចាប់គាត់បន្តទៀត។

រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់ ញ៉ិន ឃុំឃាំង និងយកទៅដាក់គុកនៅតាំងគោក។ ញ៉ិន បន្ថែមថា ពេលនោះមានអ្នកទោសជាច្រើន ដែលត្រូវបានខ្មែរក្រហមចាប់ដាក់គុក ហើយបានសួរចម្លើយទាក់ទងនឹងតួនាទីរបស់អ្នកទោសទាំងនេះ ដោយខ្មែរក្រហមបានតម្រៀបអ្នកទោសជាជួរៗ ដើម្បីងាយស្រួលក្នុងការសួរចម្លើយរកអ្នកដែលមានជាប់និន្នាការក្នុងរបបលន់នល់ ឬអ្នកក្បត់បដិវត្តន៍ខ្មែរក្រហម។ ប្រសិនបើមានអ្នកជាប់និន្នាការ គឺត្រូវយកទៅសម្លាប់ចោលភ្លាមៗតែម្តង។ ក្នុងនោះដែរ ខ្មែរក្រហមក៏បានសួរចម្លើយ ញ៉ិន អំពីឋានៈ តួនាទីរបស់គាត់ ប៉ុន្តែ ញ៉ិន បានឆ្លើយកុហកថា គាត់គឺជាយុទ្ធជនធម្មតាម្នាក់ គ្មានមុខតំណែង ឬឋានៈតួនាទីអ្វីទេ។ ញ៉ិន បានបញ្ជាក់ថា គាត់ជាប់គុកនៅទីនោះអស់រយៈពេលបីខែ ហើយក្នុងរយៈពេលនោះ គាត់បានស្ថិតនៅក្រោមការ ស៊ើបអង្កេតរបស់ខ្មែរក្រហមរហូតដល់ខ្មែរក្រហមជឿជាក់ថាគាត់គ្មានជាប់និន្នាការក្នុងរបបណាមួយ ឬគ្មានជាប់ពាក់ព័ន្ធខ្សែក្បត់បដិវត្តន៍ ទើបគណៈស្រុកតាំងគោកបានសម្រេចចិត្តបញ្ជូន ញ៉ិន ឲ្យទៅស្រុកកំណើតវិញ ក្នុងស្រុកចំការលើ ខេត្តកំពង់ចាម។

ញ៉ិន បានមករស់នៅក្នុងស្រុកកំណើតរបស់គាត់វិញ និងធ្វើការដូចជាប្រជាជនដទៃទៀតដែរ ដោយមានតួនាទីជាជាងដំដែកធ្វើកាំបិត ឬពូថៅជាដើម។ មួយឆ្នាំក្រោយមក ញ៉ិន ក៏បានក្លាយជាជាងកាត់សក់ ដោយពុំធ្លាប់បានរៀនពីមុនមក។ ញ៉ិន បញ្ជាក់ថា ក្នុងរយៈពេលនោះ ភូមិកំណើតរបស់គាត់ត្រូវបានខាងនិរតីមកកាន់កាប់ស្ទើរតែទាំងស្រុង។ ចាប់តាំងពីពេលនោះមក ញ៉ិន ក៏សង្កេតឃើញថា ប្រជាជនដែលរស់នៅក្នុងភូមិស្រុករបស់គាត់ និងប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា ត្រូវបានខាងពួកនិរតី និងក្រុមរបស់ កែ ពក យកទៅសម្លាប់ចោលជារឿយៗ ដោយមានប្រជាជនខ្លះត្រូវបានយកទៅសម្លាប់នៅម្តុំថ្នល់បំបែក ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់ក្នុងភូមិនេះផ្ទាល់។

ញ៉ិន បានបញ្ជាក់ឲ្យដឹងថា មូលហេតុដែលគាត់បានដឹងពីការសម្លាប់នេះ ដោយសារតែខ្មែរក្រហមបានយកឡានមកដឹកគាត់ទៅកាត់សក់ឲ្យ កែ ពក លេខាភូមិភាគខត្តរ (ភូមិភាគកណ្តាល) នៅម្តុំថ្នល់បំបែក ទើបគាត់បានដឹងពីការសម្លាប់ទាំងនេះ។ នៅពេលដែល ញ៉ិន កំពុង កាត់សក់ឲ្យ កែ ពក ស្រាប់តែឃើញខ្មែរក្រហមនាំប្រជាជនមកសម្លាប់ នៅចម្ងាយប្រហែល២០ម៉ែត្រពីគាត់ប៉ុណ្ណោះ។ ញ៉ិន បន្ថែមថា ខណៈពេលដែលខ្មែរក្រហមមកដឹកគាត់ទៅកាត់សក់ឲ្យ កែ ពក និងឈ្មោះ អឿន លេខាតំបន់៤២ (អឿន ត្រូវជាប្អូនថ្លៃរបស់ កែ ពក) នោះ ញ៉ិន ត្រូវបានខ្មែរក្រហមចងរុំភ្នែកដោយក្រណាត់ខ្មៅ ដើម្បីបញ្ចៀសពីការស្គាល់ផ្លូវទៅកន្លែងរបស់ កែ ពក។ មិនតែប៉ុណ្ណោះ ពេលដែល ញ៉ិន ទៅដល់កន្លែង កែ ពក ភ្លាមក៏មានខ្មែរក្រហមមកសាកសួរ ញ៉ិន ថា តើទីនេះជាកន្លែងណាហើយមកតាមផ្លូវណា? ពេលនោះ ញ៉ិន បានឆ្លើយថា គាត់មិនចាំថា មកតាមផ្លូវណា ហើយក៏មិនដឹងថាទីនេះជាកន្លែងណាដែរ។ ទោះបីជា ញ៉ិន បានដឹង ឬស្គាល់ផ្លូវក៏ដោយ ក៏គាត់មិនអាចប្រាប់ត្រង់បានឡើយ ប្រសិនបើប្រាប់បែបនេះច្បាស់ជាខ្មែរក្រហមយកទៅសម្លាប់ចោលជាមិនខាន ព្រោះខ្មែរក្រហមយល់ថា នេះជារឿងសម្ងាត់មិនអាចឲ្យបែកការណ៍បានឡើយ។

ញ៉ិន បានធ្វើជាជាងកាត់សក់ឲ្យ កែ ពក, អឿន និងកម្មាភិបាលផ្សេងទៀត រហូតដល់ខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ហើយគាត់ក៏មិនបានទៅរស់នៅកន្លែងណាផ្សេងទៀតដែរ ក្រៅពីភូមិកំណើតរបស់គាត់។

**ហូ ថុនា**

# សិស្សវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មីទទួលបានចំណេះដឹងពីវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

នៅអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំជាវេទិកាថ្នាក់រៀនមួយ ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យសម្តេចហ៊ុនសែនភ្នំពេញថ្មីដែលមានទីតាំងនៅភូមិគោកឃ្លាំងសង្កាត់គោកឃ្លៀង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន៦០នាក់។

ការរៀបចំបង្កើតឲ្យមានវេទិកាថ្នាក់រៀន លើកទី៣៣នេះឡើង ក្នុងគោលបំណងដើម្បីបង្កើតចំណេះដឹងប្រវត្តិសាស្ត្រ ការជួយជំរុញឲ្យមានការចងចាំ ការការពារកុំឲ្យមានអំពើប្រល័យពូជសាសន៍កើតមានឡើងម្តងទៀតនិងបណ្តុះបណ្តាលឲ្យមានការគិតពិចារណាទៅលើប្រវត្តិសាស្ត្រ និងដើម្បីឲ្យសិស្សានុសិស្សពិភាក្សាគ្នាអំពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យដែលខ្លួនបានដឹង និងបានរៀនសូត្រកន្លងមក។

នៅក្នុងវេទិកាថ្នាក់រៀននេះដែរ លោក ផេង ពង្សរ៉ាស៊ី នាយកនៃកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមដល់និស្សិតទាំងអស់ដែលបានចូលរួម និងបានចាក់ខ្សែភាពយន្តឯកសារខ្លីមានរយៈពេល ២០នាទី ដែលមានចំណងជើង«កុមារកម្ពុជា» ដែលបង្ហាញពីកុមារកម្ពុជារាប់សែននាក់កំព្រាឪពុកម្តាយ ក្រោយរបបរបបខ្មែរក្រហមដួលរលំ និងខ្សែភាពយន្តឯកសារ «តំបន់រំដោះឆ្នាំ១៩៧៣» និងបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន១០០ក្បាល សៀវភៅអត្តសញ្ញាណរបស់ជនជាតិចាម ៧០ក្បាល មុនការបង្រៀននិងឯកសារមេរៀនពីរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលបង្រៀនទៅដល់សិស្សទាំងអស់ ដែលបានចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀននេះ។

លោក អួន ប៉ូណាត អាយុ ៥០ឆ្នាំ ជានាយករងនៃវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី បង្ហាញពីការគាំទ្រ ដែលមានគ្រូមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ប៉ូណាត បានឲ្យដឹងថា នេះជាឱកាសកម្រសម្រាប់សិស្ស ហើយសិស្សានុសិស្សនឹងបានដឹងដោយផ្ទាល់ ពីការបង្រៀនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺយោងទៅលើប្រភពឯកសារច្បាស់លាស់។ ប៉ូណាត បានបន្តថា«ប្រសិនបើយើងមិនបានផ្សព្វផ្សាយនិងមិនបានបង្រៀនក្មេងជំនាន់ក្រោយនឹងមិនជឿថា មានរបបខ្មែរក្រហមកើតឡើងទេ»។ យើងត្រូវប្រែក្លាយការឈឺចាប់នេះ ឲ្យក្លាយជាការខិតខំប្រឹងប្រែងសិក្សារៀនសូត្រវិញ។

អយ ស្រីនាង ជាសិស្សថ្នាក់ទី១២A2 នៃវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី។ ស្រីនាង មានស្រុកកំណើតមកពីខេត្តកំពង់ចាម ហើយបានមករស់នៅទីក្រុងភ្នំពេញប្រហែល៤ឆ្នាំមកហើយ។ ស្រីនាង បានរៀបរាប់ទាំងទឹកមុខរីករាយថា នៅពេលដែលអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាមកបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះគាត់មានអារម្មណ៍រំភើបណាស់ ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកស្រាយពីរឿងរ៉ាវ នៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យគាត់បានដឹងច្បាស់។ កាលពីមុនគាត់នៅមានភាពស្រពេចស្រពិលនិងបានដឹងត្រួសៗប៉ុណ្ណោះតាមរយៈឪពុកម្តាយ លោកគា





និងរៀននៅសាលាតាមកម្មវិធីរបស់ក្រសួងអប់រំ ដែលមានរយៈពេល២ម៉ោងក្នុងមួយសប្តាហ៍។ ស្រីនាង បានលើកឡើងថា នៅពេលដែលគាត់រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់ គាត់មិនហ៊ានសួរលោកគ្រូទេ ប៉ុន្តែនៅពេលមជ្ឈមណ្ឌលឯកសារកម្ពុជា មកបង្រៀនហើយឲ្យសិស្សសរសេរសំណួរដែលខ្លួនឆ្ងល់ ទើបគាត់ហ៊ានឡើងសរសេរនៅលើក្តារខៀន។ ស្រីនាង បានបន្តទៀតថា គាត់ស្អប់ខ្ពើមរបបខ្មែរក្រហម មិនចង់ឲ្យរបបនេះកើតឡើងម្តងទៀតទេ ហើយចង់ចែករំលែកចំណេះដឹងនេះឲ្យសិស្សប្អូននិងមិត្តរៀនសូត្រដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ។

ឌុល ដាវីត មានអាយុ២០ឆ្នាំ ជាសិស្សថ្នាក់ទី១២E2 នៃវិទ្យាល័យ សម្តេច ហ៊ុន សែន ភ្នំពេញថ្មី ដែលបានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានឲ្យដឹងថា កម្មវិធីនេះពិត ជាល្អសម្រាប់គាត់ និងសិស្សានុសិស្សផ្សេងទៀត។ ដាវីត ធ្លាប់បានដឹងឮពីរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈឪពុកដែលបានរៀបរាប់ប្រាប់ថាមិនមានអាហារបរិភោគគ្រប់គ្រាន់។ ដាវីត បានបន្តថា គាត់ មិនមានគំនុំជាមួយខ្មែរក្រហមទេ ប៉ុន្តែនេះជាប្រវត្តិសាស្ត្រដ៏ជូរចត់សម្រាប់ប្រទេសកម្ពុជា។ ខ្មែរទាំងអស់ គួរតែចាប់ដៃគ្នារួមគ្នាកសាងប្រទេសឡើងវិញ។

ហេង ដានុសូដា អាយុ១៨ឆ្នាំ ថ្នាក់ទី១២ E2 នៃវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី បានរៀបរាប់ថា គាត់សប្បាយចិត្តដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មកបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ពិតជាមានសារសំខាន់ ក្នុងការចងចាំសម្រាប់ប្រជាជនខ្មែរដែលឆ្លងកាត់ការឈឺចាប់ និងការកាប់សម្លាប់ពីរបបនេះ។ ដានុសូដា បានដឹងពីប្រវត្តិសាស្ត្រនេះតាមរយៈជីតា ដែលគាត់ជាទាហាន លន់ នល់ និងភាពលំបាកវេទនានៅពេលដែលមានការផ្ទុះអាវុធ រវាងខ្មែរក្រហម និងទាហាន លន់ នល់។ ជីតា ដានុសូដា បច្ចុប្បន្នមានអាយុជាង៧០ឆ្នាំហើយ។ តា និងយាយរបស់ ដានុសូដា រៀបការនៅសម័យខ្មែរក្រហម ដោយអង្គការជាអ្នកចាប់គូឲ្យ។ ដានុសូដា បង្ហាញពីអារម្មណ៍អាណិតចំពោះជនរងគ្រោះ មិនមានអាហារហូបគ្រប់គ្រាន់។ ដានុសូដា បានបន្តទៀតថា ទោះបីយ៉ាងណាគាត់សូមប្រជាជនទាំងអស់ កុំឲ្យមានការរើសអើងចំពោះកូនអតីតកម្មាភិបាលខ្មែរក្រហម ព្រោះគាត់ប្រហែលជាមិនដឹងអំពីអ្វីដែលកើតឡើងទេ មានតែឪពុកម្តាយរបស់គាត់ដែលជាអ្នកប្រព្រឹត្តប៉ុណ្ណោះ។ ក្មេងជំនាន់ក្រោយមិនដឹងពីការកាប់សម្លាប់ទេ រួមទាំងកូនអតីតកម្មាភិបាល។

## ប្រវត្តិ និងការប្តូរឈ្មោះសាលា

នៅឆ្នាំ១៩៥៤ មិនទាន់មានវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មីនោះទេ គឺមានតែសាលាបឋមសិក្សាសំរោងអណ្តែតដែលបានបង្កើតឡើងក្រោមការជួយឧបត្ថម្ភពីសំណាក់ ព្រះតេជគុណ ចៅអធិការវត្តសំរោងអណ្តែតព្រះនាម«គុប ឈិន»



សិស្សសួរសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រ

រួមជាមួយគណៈកម្មាធិការ និងពុទ្ធបរិស័ទ។ នៅពេលនោះ សាលានេះមានតែអគារមួយខ្នងស្មើនឹង៣បន្ទប់ និងមានបុគ្គលិកអប់រំចំនួន២នាក់ប៉ុណ្ណោះ ចំណែកសិស្សានុសិស្សមានចំនួន ៩០នាក់ ដោយមាននាយកសាលាឈ្មោះ ញ៉ូ ព្រឿង។

ក្នុងឆ្នាំ១៩៦៥ សាលាបឋមសិក្សាសំរោងអណ្តែតមានអគារពីរខ្នង ស្មើនឹង៦បន្ទប់ ដោយមានលោក «កើត ហាយ» ជានាយក។ នៅក្នុងរបប ប៉ុល ពត ឆ្នាំ១៩៧៥ សាលាបឋមសិក្សាសំរោងអណ្តែត ត្រូវបានប្រែក្លាយទៅជាឃ្លាំង និងផ្ទះបាយ ខណៈដែលសាលារៀន និងវត្តអារ៉ាម ទូទាំងប្រទេសត្រូវបានខ្មែរក្រហមបំផ្លាញ។ ក្រោយមក សាលាបឋមសិក្សាសំរោងអណ្តែតនេះ ត្រូវបានខ្មែរក្រហមវាយកម្ទេចនៅសល់តែដីទួលទទេប៉ុណ្ណោះ។




កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

នៅក្នុងឆ្នាំ១៩៨២-១៩៨៥ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតសាលារៀនមធ្យមសិក្សាកម្រិតមួយសំរោងអណ្តែត ដើម្បីជំនួសឲ្យ«សាលាបឋមសិក្សាសំរោងអណ្តែត»វិញ។ ការបង្កើតនោះដោយមានការជួយឧបត្ថម្ភគាំទ្រពីព្រះចៅអធិការក្នុងវត្តសំរោងអណ្តែត ពុទ្ធបរិស័ទ្ធ និងអាជ្ញាធរមូលដ្ឋានក្នុងភ្នំពេញថ្មី។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៤ សាលានេះត្រូវបានចាប់ផ្តើមបើកទ្វារទទួលសិស្សឲ្យមកចូលរៀនឡើងវិញបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ និងត្រូវបានរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងជាថ្មី។ ក្នុងឆ្នាំ១៩៨៤ដដែលមានសិស្សសរុបចំនួន២៤៧នាក់ក្នុងនោះសិស្សស្រីមាន៨៩នាក់។ ចំណែកបុគ្គលិកមានចំនួន៥នាក់ មានសមមិត្ត អ៊ុំ គង់ប៊ុនហេង (នាយក) និងសមមិត្ត កួយ សារឿន (នាយករង)។

នៅឆ្នាំ១៩៨៦-១៩៨៧ សាលានេះត្រូវបានដំឡើងទៅអនុវិទ្យាល័យសំរោងអណ្តែត ក្រោមការជួយឧបត្ថម្ភពីគណៈកម្មាធិការប្រជាជនបដិវត្តន៍ ឃុំភ្នំពេញថ្មី។ ក្រោយមក នៅពេលដែលវិស័យអប់រំ នៅប្រទេសកម្ពុជាមានការរីកចម្រើនជាពិសេសតម្រូវការចាំបាច់របស់សិស្សានុសិស្ស នៃអនុវិទ្យាល័យសំរោងអណ្តែត ក្រសួងអប់រំយុវជន និងកីឡាបានចេញប្រកាសលេខ៥៣អ.យ.ក.ប្រ.ក ចុះថ្ងៃ១៣ ខែមករា ឆ្នាំ២០០៥ ស្តីពីការពង្រីកអនុវិទ្យាល័យសំរោងអណ្តែត ទៅវិទ្យាល័យសំរោងអណ្តែត ដោយមានការចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិត«កុល ផេង» ទេសរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា។

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ មាតាបិតាសិស្សានុសិស្ស បានសំណូមពររាជរដ្ឋាភិបាល សម្តេច ហ៊ុន សែន ប្តូរឈ្មោះវិទ្យាល័យសំរោងអណ្តែត ទៅជា«វិទ្យាល័យ សម្តេច ហ៊ុន សែន ភ្នំពេញថ្មី» រហូតមកដល់សព្វថ្ងៃ។

**ដារ៉ារដ្ឋ មេត្តា**

# អ្នកចម្រៀង មាស ហុកសេង ត្រូវខ្មែរក្រហមសម្លាប់នៅ ស្រុកគាស់ក្រឡ ក្នុងភូមិភាគពាយ័ព្យ

បន្ទាប់ពីកងទ័ពខ្មែរក្រហម ចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជន មន្ត្រីរដ្ឋការ ទាហាន ប៉ូលីស កីឡាករ តន្ត្រីករ តារាភាពយន្ត តារាចម្រៀង ត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ឲ្យទៅធ្វើការងារពលកម្មហួសកម្លាំង និងសម្លាប់ចោលនៅតាមទីជនបទដាច់ស្រយាលនានានៅទូទាំងប្រទេស។ លោក មាស ហុកសេង ដែលជាអតីតតារាចម្រៀងដ៏ល្បីនៅអំឡុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០ និងជាម្ចាស់បទលលកញី-ឈ្មោលដ៏ពេញនិយម ត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំជាមួយក្រុមគ្រួសារឲ្យទៅរស់នៅ និងធ្វើការងារពលកម្មនៅក្នុងស្រុកគាស់ក្រឡ ខេត្តបាត់ដំបង (តំបន់១) ភូមិភាគពា-យ័ព្យ។ ជាអកុសលលោក មាស ហុកសេង ក្រុមគ្រួសាររួមជាមួយប្រជាជនថ្មីប្រមាណ ៥០នាក់ផ្សេងទៀតត្រូវបានខ្មែរក្រហមសម្លាប់ដោយចោទប្រកាន់ថា មានគម្រោងរត់គេចទៅប្រទេសថៃ។

ឈុន លាង អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងកងពលតូចលេខ៥ប្រចាំការនៅជិតវ៉ាំសំរោង និងមានស្រុកកំណើតនៅ កាកាប ស្រុកដង្កោ ខេត្តកណ្តាល បានរៀបរាប់ថា៖ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានធ្វើដំណើរទៅជាមួយមេបញ្ជាការកងវរសេនាតូចប្រចាំការនៅជិត វ៉ាំសំរោង ឈ្មោះ គ្រាន់ ថា និងទាហានចំនួន៥នាក់ទៀតទៅលាក់ខ្លួននៅក្តីតាកុយ ខាងច្បារអំពៅ ដោយមានតែអង្ករមួយបង្ខិចតែប៉ុណ្ណោះ។ លាង បានឃើញព្រះអង្គម្ចាស់ នរោត្តម នរៈតិប៉ោ និងកងការពារដែលជាអតីតអ្នកប្រដាល់ល្បីឈ្មោះ ជា សារ៉ាក់។ នៅទីនោះខ្មែរក្រហមបានចេញមកអំពាវនាវរើសនិស្សិតបញ្ញវន្តនាយទាហានចាប់ពីស័ក្តិ១ឡើង ដើម្បីទទួលសម្តេច សីហនុ ប៉ុន្តែ លាង មិនជឿលើការឃោសនានេះឡើយ។ បន្ទាប់មក លាង និងក្រុមរបស់គាត់បានបំបែកគ្នាធ្វើ ដំណើរទៅតាមគោលដៅដែលចង់ទៅរៀងៗខ្លួន ព្រោះ លាង បានគិតថា បើខ្មែរក្រហមបានដឹងថាពួកគាត់ជាទាហាន លន់ នល់ នោះនឹងស្លាប់ទាំងអស់គ្នា។

លាង បានសុំខ្មែរក្រហមធ្វើដំណើរតាមទូកឆ្លងកាត់ទន្លេទៅជួបមិត្តភក្តិរបស់គាត់ម្នាក់ឈ្មោះ ម៉ាច នៅវត្តចុងព្រែក ក្នុងឃុំរការកោង ខេត្តកណ្តាល។ បន្ទាប់ពីបានស្នាក់នៅជាមួយ ម៉ាច មួយយប់ លាង បានធ្វើដំណើរទៅកាន់ស្រុកខដុង្គ ដើម្បីទៅរកម្តាយ និងបងប្អូនដែលបានជម្លៀសទៅទីនោះ ប៉ុន្តែខ្មែរក្រហម មិនអនុញ្ញាតឲ្យគាត់ធ្វើដំណើរទៅកាន់កន្លែងនោះឡើយ។ លាង បានសម្រេចចិត្តរស់នៅ និងធ្វើការតាមជើងភ្នំខដុង្គ ក្នុងសហករណ៍ត្រពាំងរំពាក់ក្នុង ឃុំភ្នំបាត ស្រុកខដុង្គ ខេត្តកំពង់ស្ពឺ ដែលមានប្រធានសហករណ៍ឈ្មោះ តាវ៉ាង។ លាង រស់នៅសហករណ៍ត្រពាំងរំពាក់ក្នុងបានប្រហែល៣ខែ ខ្មែរក្រហមក៏បានស្រាវជ្រាវដឹងពីប្រវត្តិរូបរបស់គាត់ តាមរយៈរូបថតដែលគាត់បានថត តាំងក្នុងផ្ទះរបស់គាត់នៅបន្ទាយស្លឹកទីក្រុងភ្នំពេញ។ បន្ទាប់មកខ្មែរក្រហមបានធ្វើដំណើរមកចាប់ លាង នៅក្នុងសហករណ៍នេះតែម្តង។ ជាភ័ព្វសំណាងល្អ តាវ៉ាង ជាប្រធានសហករណ៍បានឲ្យកូនគាត់មកប្រាប់ លាង ឲ្យរត់គេចខណៈពេលដែល លាង កំពុងតែភ្ជួរស្រែ។ តាវ៉ាង បានឲ្យអង្ករខ្លះទៅ លាង សម្រាប់ដាំហូបពេលរត់គៀសខ្លួនដេកនៅក្នុងព្រៃ។ លាង បានដើរផ្សងព្រេងទៅដល់បាត់ដឹង ក្នុងស្រុកខដុង្គ ខេត្តកំពង់ស្ពឺ និងបានបន្តដំណើរតាមរថភ្លើងជាមួយប្រជាជនដែលខ្មែរក្រហមជម្លៀសជាច្រើននាក់ទៀត

ទៅកាន់ខេត្តបាត់ដំបង។

ពេលមកដល់ខេត្តបាត់ដំបងដំបូង លាង ត្រូវបានខ្មែរក្រហម បញ្ជូនឲ្យទៅធ្វើការក្នុងភូមិទួលជ្រេះ ឃុំសុភី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ក្នុងតំបន់១ ដែលពេលនោះ លាង ចាប់ផ្តើមដូរឈ្មោះពី ឈុន ឡាយ មក ឈុន លាង វិញ។ លាង បានប្រាប់ទៅកម្មាភិបាលខ្មែរក្រហមថា គាត់ឈ្មោះ ឈុន លាង ជាសិស្សនិងមានស្រុកកំណើតមកពីខេត្តតាកែវ ព្រោះ លាង ដឹងថាបើមិនលាក់បាំងប្រវត្តិរូបពិតប្រាកដទេ គាត់នឹងត្រូវសម្លាប់។ លាង ធ្លាប់បានឃើញបុរសម្នាក់ ជាអតីតទាហាន លន់ នល់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន ហើយយកទៅសម្លាប់ដោយសារតែខ្មែរក្រហម បានការស៊ើបរកប្រវត្តិរូបតាមរយៈមនុស្ស ក្នុងក្រុមគ្រួសារ និងមនុស្សមកពីស្រុកកំណើតជាមួយគ្នា។

នៅក្នុងស្រុកគាស់ក្រឡនេះ លាង បានជួបតារាចម្រៀងល្បីពីររូប គឺលោក មាស ហុកសេង និងអ្នកស្រី ហែម សុវណ្ណ ដែលត្រូវខ្មែរក្រហមជម្លៀសមករស់នៅស្រុកនេះដែរ។ លាង នៅចាំថាពេលកំពុងធ្វើការងារនៅតាមវាលស្រែ ខ្មែរក្រហមតែងតែបាត់តាំងឲ្យអ្នកស្រី ហែម សុវណ្ណ ស្រែកច្រៀងចម្រៀងបដិវត្តន៍ផ្សេងៗ នៅខណៈដែលកំពុងធ្វើការពលកម្មនោះ។ នៅពេលរសៀលមួយក្នុងរដូវវស្សាឆ្នាំ១៩៧៧ លាង និងយុវជនប្រមាណជាង ១០នាក់ទៀត ត្រូវបានកម្មាភិបាលខ្មែរក្រហមបញ្ជាឲ្យជីករណ្តៅទំហំ១០ម៉ែត្រ ៤ជ្រុង ដើម្បីទុកឲ្យពួកគេអារកសម្លាប់មនុស្ស រួចហើយទម្លាក់ចូលក្នុងរណ្តៅនេះ នៅពេលព្រលប់ថ្ងៃដដែលនោះ។ មនុស្សដែលត្រូវសម្លាប់មានចំនួនប្រហែលជាង៦០នាក់ ក្នុងចំណោមនោះក៏មានលោក មាស ហុកសេង និងក្រុមគ្រួសារដែលត្រូវខ្មែរក្រហមចោទប្រកាន់ថា រៀបចំផែនការរត់គេចខ្លួនទៅប្រទេសថៃ។ លាង និងអ្នកជីករណ្តៅផ្សេងទៀត ត្រូវខ្មែរក្រហមបញ្ជាឲ្យឈររង់ចាំលុបរណ្តៅវិញនៅចម្ងាយប្រហែល ជាជាង១០ម៉ែត្រពីកន្លែងសម្លាប់។ លាង បានឃើញហេតុការណ៍យ៉ាងច្បាស់ថា មនុស្សទាំងអស់ត្រូវបានចងស្លាបសេកនិងអារកដោយកាំបិតត្នោតរួចធាក់ទម្លាក់ចូលទៅក្នុងរណ្តៅ ជាមួយនឹងសំឡេងស្រែកយំលាន់រំពង។ បន្ទាប់ពីសម្លាប់រួច កម្មាភិបាលខ្មែរក្រហមទាំងនោះបានបញ្ជាឲ្យ លាង និងយុវជនផ្សេងទៀត



ឈុន លាង



មាស ហុកសេង

កាយដឹកប់រណ្តៅវិញ ហើយមានអ្នកខ្លះមិនទាន់ទាំងដាច់ខ្យល់ផង។ លាង ប្រាប់ថាឈ្លបខ្មែរក្រហម ឈ្មោះ ជឹប និងបក្ខពួក៥នាក់ទៀតជាអ្នកសម្លាប់។ នៅក្នុងស្រុកគាស់ក្រឡមានគុកមួយ ស្ថិតនៅក្នុងវត្តពន្លៃដូនបា រីឯទីតាំងសម្លាប់មនុស្សវិញស្ថិតនៅក្រោយវត្ត ជិតទំនប់ដំណាក់សៀម។

លាងបានរៀបរាប់បន្តទៀតថាខ្មែរក្រហមបានចាត់តាំងឲ្យគាត់ធ្វើការនៅក្នុងសហករណ៍ ដែលគ្រប់គ្រងដោយ តាថាវ។ ដំបូង តាថាវ បានឲ្យ លាង រស់នៅជាមួយចាស់ៗមួយក្រុម តែមិនយូរប៉ុន្មានក៏ផ្លាស់ប្តូរឲ្យទៅរស់នៅក្នុងកងចល័តវិញ។ ជីវិតនៅស្រុកគាស់ក្រឡជួបការលំបាកជាខ្លាំង ការផ្គត់ផ្គង់អាហារមិនបានគ្រប់គ្រាន់ឡើយ គឺអង្ករ២កំប៉ុងសម្រាប់ចម្អិនបបរមួយខ្ទះធំ ហើយខ្មែរក្រហមបានបន្ថែមអំបិលមួយចុងស្លាបព្រាសម្រាប់មនុស្សម្នាក់ក្នុងមួយពេលៗ។ ប្រជាជនហត់ហេវ បានបោចស្លឹកឈើ និងបន្លែសម្រាប់បរិភោគបន្ថែមដើម្បីបំពេញក្រពះ។ នៅក្នុងកងចល័ត លាង ត្រូវចាត់តាំងឲ្យធ្វើការងារលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែជាដើម។ លាង បន្ថែមថា ប្រជាជនថ្មីត្រូវបានខ្មែរក្រហមតាមដានប្រវត្តិរូប និងយកទៅសម្លាប់ប្រសិនជាធ្វើការងារមិនសកម្ម។ ទោះបីជាធ្វើការងារធ្ងន់ ដោយគ្មានអាហារគ្រប់គ្រាន់ក៏ដោយ តែ លាង ត្រូវតែខិតខំធ្វើការមិនហ៊ានឈប់សម្រាកឡើយ ព្រោះ លាង ខ្លាចមានកំហុសដែលឈានទៅដល់ការស៊ើបអង្កេតប្រវត្តិរូប។ ដោយប្រធានសហករណ៍បានមើលឃើញថា លាង ខិតខំធ្វើការងារនោះ ក៏ចាត់តាំង លាង ឲ្យធ្វើជាប្រធានកងតូចដែលគ្រប់គ្រងប្រជាជនប្រហែលពី ២០ ទៅ ៣០នាក់ ដែលភាគច្រើនជាប្រជាជនថ្មីដូច លាងដែរ។ លាងបានឲ្យដឹងទៀតថា ទោះបីជាប្រជាជនសាមញ្ញ ឬជាប្រធានកងតូចក៏ដោយស្ថានភាពកាន់តែលំបាកពីមួយថ្ងៃទៅមួយថ្ងៃធ្វើការងារលើសកម្លាំង អាហារមិនគ្រប់គ្រាន់ ហើយមានពេលខ្លះ លាង បានឆ្លៀតពេលចាប់ក្តាម កណ្តុរ និងបាចត្រីតាមទីវាលហូបខ្លួនឯង។

នៅក្នុងឆ្នាំ១៩៧៧ អង្គការចាត់តាំង លាង យុវជនយុវនារី រាប់រយឲ្យទៅលើកទំនប់ ធ្វើអាងទឹកនៅភ្នំធិបដេ អស់រយៈពេលពេញ១រដូវប្រាំង។ ការងារលើកទំនប់នៅភ្នំធិបដេមិនមែនជាការងារស្រួល សម្រាប់ប្រជាជនទាំងអស់ឡើយ ដែលពេលនោះមានប្រជាជនជាច្រើន បានស្លាប់ដោយសារជំងឺកាន់តែច្រើនទៅពីមួយថ្ងៃទៅមួយថ្ងៃ។ បន្ទាប់មកខ្មែរក្រហមដកអ្នកធ្វើស្រែនៅស្រុកគាស់ក្រឡមកវិញនៅរដូវវស្សា។ នៅឆ្នាំ១៩៧៨ អង្គការបានចាត់តាំង លាង និងកងយុវជនយុវនារីឲ្យទៅលើកទំនប់នៅជង្ហុកត់ទប់ស្ទឹងសង្កែរទៀត។

គណៈស្រុកគាស់ក្រឡចាស់ឈ្មោះ តាព្រឿង។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ស្រុកគាស់ក្រឡមានការចាប់និងសម្លាប់កម្មាភិបាលចាស់នៅភូមិភាគពាយ័ព្យ ដោយកម្មាភិបាលថ្មីមកពីភូមិភាគនិរតី ហើយសមាសភាពអ្នកដឹកនាំក្នុងឃុំ ស្រុក និងតំបន់ត្រូវដាក់ជំនួសដោយកម្មាភិបាល មកពីភូមិភាគនិរតីវិញ។

នៅខណៈពេលដែលកងទ័ពវៀតណាមចូលមកដល់ខេត្តបាត់ដំបងក្នុងឆ្នាំ១៩៧៩ ហេតុការណ៍ជម្លៀសប្រជាជនចាប់ផ្តើមកើតឡើងម្តងទៀត។ ក្នុងពេលនោះយោធាខ្មែរក្រហមបានបង្ខំប្រជាជនឲ្យធ្វើដំណើរទៅជាមួយ ដើម្បីធ្វើជារនាំងបាំងកុំឲ្យកងទ័ពវៀតណាមបាញ់ត្រូវពួកគេ។ ពេលធ្វើដំណើរតាមផ្លូវ ដោយមានប្រជាជនមួយចំនួនមានជំងឺ មិនអាចធ្វើដំណើរបានលឿន និងដោយខ្លាចកងទ័ពវៀតណាមតាមមកទាន់នោះ កម្មាភិបាលខ្មែរក្រហមក៏បានចាកចេញទៅមុន។ បន្ទាប់មក លាង និងប្រជាជនមួយចំនួន បានហែលឆ្លងស្ទឹងសង្កែ មករកកងទ័ពវៀតណាម និងបន្តការស្នាក់នៅខេត្តបាត់ដំបងចាប់ពីពេលនោះមក។

លាង បន្តរស់នៅខេត្តបាត់ដំបងរហូតពាក់កណ្តាលឆ្នាំ១៩៨០ ដោយសារការខ្វះខាតអាហារ និងមធ្យោបាយធ្វើដំណើរត្រឡប់មកស្រុកកំណើត។ ក្រោយមក លាង ក៏បានត្រឡប់មកភ្នំពេញវិញ។ នៅក្នុងរបបខ្មែរក្រហមពី១៩៧៥-១៩៧៩ លាង បានបាត់បង់ម្តាយ និងប្អូនពីរនាក់។

**អ៊ិន សុដាវី**

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន៣០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរពីប្រវត្តិសាស្ត្ររឿងរ៉ាវចេញពីភូមិឃុំកំណើត ឬភូមិឃុំដែលខ្លួនកំពុងរស់នៅ ដែលជាប់ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់លោកគ្រូអ្នកគ្រូ នឹងត្រូវបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនលោកគ្រូអ្នកគ្រូវិញដើម្បីប្រើប្រាស់ជាសម្ភារៈឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។

   

*លក្ខខណ្ឌជ្រើសរើស*

១) អ្នកស្រាវជ្រាវ គឺត្រូវតែជាគ្រូមុខវិជ្ជាប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កណ្តាល (ស្រុកមុខកំពូល ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជាការធ្វើបទសម្ភាសន៍, ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួន។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសម្លេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

*លក្ខខណ្ឌការងារ*

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ឯកសារយោង កំណត់គោលដៅសម្រាប់សម្ភាសន៍ ការសម្ភាសន៍ វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរពីកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសម្លេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុកនិងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរចេញពីភូមិកំណើតរបស់ខ្លួន តាមអស័យដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរស័ព្ទ ០១២ ៦៩៦ ៩៦១ ឬអ៊ីមែល: truthrasy.p@dccam.org ៕

# ខ្មែរក្រហមបានបង្ហាត់យុទ្ធសាស្ត្រកងទ័ព និងរបៀបប្រើកាំភ្លើង ដល់កុមារដែលមិនទាន់គ្រប់អាយុ

«កុមាររាប់រយនាក់ត្រូវបានខ្មែរក្រហមបញ្ជូនមកបង្ហាត់បង្រៀនពីយុទ្ធសាស្ត្រកងទ័ព និងវិធីសាស្ត្រប្រើប្រាស់កាំភ្លើងនៅក្បែរព្រំដែនវៀតណាមក្នុងស្រុកមេមត់ ខេត្តកំពង់ចាម ដើម្បីឲ្យកុមារចូលរួមក្នុងការប្រយុទ្ធប្រឆាំងជាមួយនឹងកងទ័ពវៀតណាមនៅតាមព្រំដែន»។

ខាងលើនេះ គឺជាការរៀបរាប់របស់ ពេជ លឹម ហ៊ាង ដែលមានស្រុកកំណើតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។


កុមារតូចៗដែលខ្មែរក្រហមជ្រើសរើសឲ្យចូលបម្រើយោធា

លឹមហ៊ាង ពិតជាមានអារម្មណ៍ត្រេកអរខ្លាំងណាស់ បានមានឱកាសចែករំលែកអំពីបទពិសោធន៍ជីវិតដ៏ជូរចត់ ក៏ដូចជារឿងរ៉ាវផ្ទាល់ខ្លួនដែលគាត់ធ្លាប់បានជួបប្រទះជាច្រើនសម័យកាលជាពិសេសសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

កាលពីសង្គមចាស់ លឹមហ៊ាង បានសម្រេចចិត្តបួសធ្វើជាព្រះសង្ឃដើម្បីរៀនសូត្រក្រេប យកចំណេះដឹងខ្លះៗទាំងផ្នែកខាងសង្គម ក៏ដូចជាផ្នែកខាងព្រះពុទ្ធសាសនា។ លឹមហ៊ាង បួសធ្វើជាព្រះសង្ឃបានត្រឹមតែបីព្រះវស្សាតែប៉ុណ្ណោះ ក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងដោយសេនាប្រមុខ លន់ នល់ ក្នុងឆ្នាំ១៩៧០។ ក្រោយមក លឹមហ៊ាង និងព្រះសង្ឃ២០អង្គផ្សេងទៀត ត្រូវបានខ្មែរក្រហមចាប់បង្ខំឲ្យសឹក ដើម្បីជួយបម្រើដល់ក្រុមខ្លួន។ ភ្លាមៗនោះ ខ្មែរក្រហមបានចាត់តាំង លឹមហ៊ាង ឲ្យធ្វើជានីរសារ ក្នុងឃុំអូរម្លូ ក្រោមការគ្រប់គ្រងរបស់ តាឆែម។ កន្លះខែក្រោយមក លឹមហ៊ាង ត្រូវបានខ្មែរក្រហមដកចេញពីខាងនីរសារ ហើយបានបញ្ចូលនៅក្នុងកងឈ្លបភូមិវិញ។ មកដល់ឆ្នាំ១៩៧៣ ខ្មែរក្រហមបានបញ្ជូន លឹមហ៊ាង ឲ្យទៅសមរភូមិប្រយុទ្ធជាមួយកងទ័ពរដ្ឋាភិបាល លន់ នល់ ហើយក៏ជាពេលដែលខ្មែរក្រហម បានចាប់ផ្តើមរៀបចំកងកម្លាំងទៅតាមវរកងពលនីមួយៗ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ក៏ដូចជាងាយស្រួលក្នុងការចាត់តាំងនៅពេលចុះទៅសមរភូមិប្រយុទ្ធ។ រីឯ លឹមហ៊ាង ក៏ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលក្នុងអង្គភាពកងពលដែលមានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ចាម។ បន្ទាប់ពីរៀបចំកងកម្លាំងរួចមក ខ្មែរក្រហមក៏ចាប់ផ្តើមវាយសម្រុកចូលទីរួមខេត្តកំពង់ចាម។ ក្រោយមកកងពលរបស់ លឹមហ៊ាង បានដកមកស្រុកបាធាយ ដើម្បីត្រៀមវាយចូលទីក្រុងភ្នំពេញ។ ក្នុងរយៈពេលនោះ លឹមហ៊ាង ត្រូវបានចាត់តាំងឲ្យបម្រើការងារនៅក្នុងកងដឹកជញ្ជូនស្បៀង និងជួយដឹកគ្រាប់ សព្វាវុធទៅឲ្យកងទ័ព។

នៅឆ្នាំ១៩៧៤ នៅខណៈពេលដែលកំពុងដឹកជញ្ជូនគ្រាប់ លឹមហ៊ាង និងសមាជិកក្រុមដឹកជញ្ជូនបានជាន់មីនស្លាប់ និងរបួសជាច្រើននាក់។ រីឯ លឹម ហ៊ាង ក៏ត្រូវអំបែងមីនខ្ទាតចំដៃ និងត្រគៀកធ្លាក់ខ្លួនពិការរហូតមកដល់សព្វថ្ង

នៃនេះ។ បន្ទាប់ពី លឹមហ៊ាង រងរបួសភ្លាម គាត់ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅសម្រាកព្យាបាលរបួស នៅមន្ទីរពេទ្យ ព-២១។ លឹម ហ៊ាង សម្រាកព្យាបាលរបួសនៅទីនោះរហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះប្រហែលមួយសប្តាហ៍ គាត់ក៏ត្រូវបានខ្មែរក្រហមឲ្យចាកចេញពីមន្ទីរពេទ្យព-២១ទាំងរបួសមិនទាន់ជាសះស្បើយ និងធ្វើដំណើរទៅអង្គភាពកងវរសេនាធំ ដែលមានទីតាំងស្ថិតនៅសេះសក្នុងស្រុកបាធាយ ខេត្តកំពង់ចាម។ បន្ទាប់មកទៀត លឹមហ៊ាង បានបន្តដំណើរមកទីក្រុងភ្នំពេញ និងឃើញទិដ្ឋភាពទីក្រុងមានសភាពស្ងាត់ជ្រងំ។ នៅពេលនោះ លឹមហ៊ាង មានអារម្មណ៍គួរឲ្យសង្វេគយ៉ាងខ្លាំងព្រោះកាលនោះប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ ត្រូវបានខ្មែរក្រហមជម្លៀសចេញទៅតាមទីជនបទនានាដើម្បីធ្វើស្រែចម្ការ។ តមកទៀត លឹម ហ៊ាង បានត្រឡប់មកអង្គភាពកងវរសេនាធំនៅសេះសវិញ ប៉ុន្តែពេលមកដល់បែរជាគ្មានកងទ័ពស្នាក់នៅ ព្រោះថ្នាក់លើបានបញ្ជូនវរសេនាធំឲ្យទៅឈរជើងនៅខេត្តរតនៈគិរី។ លឹម ហ៊ាង ក៏បានបន្តដំណើរឆ្ពោះទៅខេត្តរតនៈគិរី ដើម្បីចូលរួមធ្វើសកម្មភាពនៅក្នុងអង្គភាពរបស់ខ្លួន។ មួយរយៈក្រោយមក លឹមហ៊ាង និងកងវរសេនាធំរបស់គាត់ ត្រូវបានថ្នាក់លើបញ្ជូនមកខេត្តក្រចេះ ដើម្បីធ្វើផ្លូវសម្រាប់ដឹកអង្ករពីក្រចេះទៅខេត្តរតនៈគិរី។ ក្នុងឱកាសនោះ លឹមហ៊ាង ក៏បានសុំអនុញ្ញាតថ្នាក់លើ សុំសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យក្នុងខេត្តក្រចេះ ព្រោះរបួសគាត់មិនទាន់ជាសះស្បើយនៅឡើយ។ លឹមហ៊ាង សម្រាកព្យាបាលពីមួយ ថ្ងៃទៅមួយថ្ងៃ រីឯរបួសរបស់គាត់ក៏មិនបានធូរស្រាលដែរ ទើបគាត់បានសម្រេចចិត្តទៅព្យាបាលរបួសនៅទីក្រុងភ្នំពេញបន្តទៀត។ មួយរយៈក្រោយមក លឹមហ៊ាង ក៏បានជាសះស្បើយពីរបួស ហើយគាត់ក៏ត្រូវបានកងវរសេនាធំបញ្ជូលគាត់ឲ្យនៅក្នុង (មន្ទីរពិការក-៤) ដែលមានទីតាំងស្ថិតនៅម្តុំវត្តឃ្មួញ ដាយក្រុងភ្នំពេញ។ លឹមហ៊ាង មានតួនាទីដាំបន្លែ និងចញ្ចឹមសត្វ។

ប្រហែលជាឆ្នាំ១៩៧៧ អង្គភាពរបស់ លឹមហ៊ាង ត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅវាយ ជាមួយកងទ័ពវៀតណាមនៅទល់ដែនក្នុងស្រុកមេមត់ ខេត្តកំពង់ចាម ប៉ុន្តែ លឹមហ៊ាង មិនបានចូលរួមប្រយុទ្ធផ្ទាល់ទេ ពីព្រោះគាត់នៅខាងសេដ្ឋកិច្ច ហើយសមរភូមិប្រយុទ្ធក៏មិននៅឆ្ងាយពីកន្លែង លឹមហ៊ាង ស្នាក់នៅដែរ។ លឹមហ៊ាង បានរៀបរាប់ថា ខណៈពេលប្រយុទ្ធគ្នាកងទ័ពទាំងសងខាងបានត្រូវរបួស និងស្លាប់ជាច្រើននាក់។ ក្នុងឆ្នាំ១៩៧៨ លឹមហ៊ាង បានឃើញកងទ័ពខ្មែរក្រហមដឹកកុមារជាច្រើនរយនាក់មកដាក់ក្បែរអង្គភាពរបស់គាត់។ ខ្មែរក្រហមត្រៀមបង្ហាត់បង្រៀនពីយុទ្ធសាស្ត្រកងទ័ព និងវិធីសាស្ត្រផ្សេងៗ ក្នុងការប្រើប្រាស់កាំភ្លើងដល់កុមារៗទាំងនេះ ដើម្បីជួយដល់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងជាមួយនឹងកងទ័ពវៀតណាមនាពេលខាងមុខ។ លឹមហ៊ាង បានធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ចវរសេនាតូច រហូតដល់របបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩។

បន្ទាប់ពីរបបខ្មែរក្រហម ត្រូវបានផ្តួលរំលំដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាសហការជាមួយកងទ័ពវៀតណាមរួចមក លឹមហ៊ាង ក៏បានវិលត្រឡប់មករស់នៅក្នុងស្រុកកំណើតវិញ ហើយបានខិតខំប្រឹងប្រែងកសាងជីវិតថ្មីទាំងខ្លួនជាជនពិការ។ ដោយសារតែស្រុកទេសកើតមានសង្គ្រាមជាពិសេសរបបដ៏សាហាវព្រៃផ្សៃយង់ឃ្នងរបស់មេដឹកនាំ ប៉ុល ពត ក្នុងឆ្នាំ១៩៧៥-១៩៧៩ បានធ្វើឲ្យប្រជាជនខ្មែរស្លូតត្រង់ ប្រមាណជិតពីរលាននាក់បានស្លាប់ និងបានបន្សល់ទុកនូវជនពិការចំនួន១៤១,៨៤៨មកដល់សព្វថ្ងៃនេះ។ ទោះជាយ៉ាងនេះក្តី ក៏ លឹមហ៊ាង មិនដែលតូចចិត្តនឹងខ្លួនពិការដែរ ព្រោះគាត់យល់ថា វាគឺជាប្រវត្តិសាស្ត្រមួយដ៏ជូរចត់សម្រាប់ក្មេងជំនាន់ក្រោយ ត្រូវធ្វើការសិក្សាស្វែងយល់ឲ្យបានច្បាស់ ដើម្បីកុំឲ្យប្រវត្តិសាស្ត្រដ៏សាហាវព្រៃផ្សៃបែបនេះកើតឡើងសារជាថ្មីនៅក្នុងប្រទេសកម្ពុជា។

**ហួ ផុនា**

# និស្សិតមហាវិទ្យាល័យច្បាប់ និងរដ្ឋបាលសាធារណៈស្វែងយល់ពីកិច្ចការស្រាវជ្រាវ និងប្រភពធនធានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

និស្សិតមហាវិទ្យាល័យច្បាប់ និងរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន ៨៥នាក់ បានមកផ្លាស់ប្តូរបទពិសោធន៍របស់ខ្លួនជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ពីទម្រង់នៃការស្រាវជ្រាវនិងស្វែងយល់បន្ថែមពីប្រភពឯកសារស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីជាការយល់ដឹង និងបំពេញបន្ថែមពិភារកិច្ច និងតួនាទីរបស់ខ្លួនដែលកំពុងសិក្សាពីច្បាប់ និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។

ក្នុងជំនួបជាមួយនិស្សិតទាំងនេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពន្យល់ និងបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ និងប្រភពធនធានដ៏សម្បូរណ៍បែបស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយផ្តោតសំខាន់លើចំណុចចំនួន ៣គឺ៖ ១) របៀបនៃការស្វែងរកប្រធានបទតូចៗ ទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ ២) ប្រភពធនធានដ៏សម្បូរណ៍បែបនៃឯកសារទាក់ទងនឹងរបបខ្មែរក្រហមដែលមានតម្កល់នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា និង៣) ការផ្តល់គំនិតយោបល់សំខាន់ៗមួយចំនួនដែលបង្ហាញពីភាពជាប់ទាក់ទងគ្នារវាងអតីតកាលនៃរបបខ្មែរក្រហមដែលបន្តជះឥទ្ធិពលមកដល់បច្ចុប្បន្នកាល និងអនាគតកាលដែលក្មេងៗជំនាន់ក្រោយមិនគួរមើលរំលង ប៉ុន្តែត្រូវបង្កើនការត្រិះរិះពិចារណាឲ្យស៊ីជម្រៅ ពីឫសគល់នៃការកកើតរបបប្រល័យពូជសាសន៍នៅកម្ពុជា។ និស្សិតទាំងអស់ មិនត្រឹមតែទទួលបានមេរៀនថ្មីៗពីការធ្វើកិច្ចការស្រាវជ្រាវ និងប្រភព


និស្សិតមកពីមហាវិទ្យាល័យច្បាប់ និងរដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កំពុងស្តាប់ការធ្វើបទបង្ហាញរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ពីប្រធានបទសំខាន់ៗរបស់ខ្លួនដែលនឹងត្រូវសរសេរ

ឯកសារប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងទទួលបានគំនិតថ្មីៗបន្ថែមទៀត ស្តីពីភាពជាប់ទាក់ទងគ្នាទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍ រវាងអ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមជាមួយនឹងមនុស្សជាច្រើននាក់ ដែលបានស្លាប់ និងសម្លាប់ដោយខ្មែរក្រហមនាអំឡុងពេលដែលខ្លួនកាន់កាប់អំណាច។ លោក ឆាំង យុ បានសង្កត់ធ្ងន់ថា ការជាប់ទាក់ទងគ្នានេះ គឺពិតជាមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ ទោះបីជារយៈពេលជិត ៤០ឆ្នាំ ក្រោយរបបខ្មែរក្រហមដួលរលំបានកន្លងផុតទៅហើយក៏ដោយ។ លោកបាននិយាយដូច្នេះថា «ប្រសិនបើអ្នកបានរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ អ្នកគឺជាមនុស្សដែលមានសំណាងខ្លាំងណាស់។ អ្នកអាចចាប់ផ្តើមជីវិតសារជាថ្មីម្តងទៀត។ អ្នកអាចមានទីជម្រក មានផ្ទះសម្បែង មានការងារធ្វើ មានមិត្តភក្រ្តិ និងចាប់ផ្តើមកសាងគ្រួសារថ្មីមួយ។ ប៉ុន្តែអ្នកនឹងមានការរំខានដោយសារតែរឿងរ៉ាវជាច្រើនដែលបានកើតឡើងមកលើអ្នក។ ជីវិត និងផ្លូវចិត្តរបស់អ្នកទទួលរងនូវការបែកបាក់។ បេះដូងរបស់អ្នកទទួលរងនូវការឈឺចាប់ ដោយសារតែការបាត់បង់មនុស្សជាទីស្រឡាញ់។ អ្នកត្រូវបានរំខានដោយការចងចាំរបស់អ្នក។ អ្នកមានអារម្មណ៍ថាមានកំហុសព្រោះថា អ្នកបានរស់រានមានជីវិតខណៈដែលមនុស្សជាច្រើនទៀតបានស្លាប់បាត់បង់ជីវិត ហើយអ្វីដែលកាន់តែអាក្រក់ជាងនេះទៀតនោះ គឺអ្នកអាចបាត់បង់ក្តីសង្ឃឹម។ ក្រៅពីគំនិតដូចមានរៀបរាប់ខាងលើ ដែលលោកនាយកបានផ្តល់ដល់និស្សិត លោកបានបង្ហាញគំនិតជាច្រើនទៀត សុទ្ធសឹងតែជាប្រធានបទសំខាន់ដែលនិស្សិតទាំងអស់ ធ្វើការពិចារណាសម្រាប់សំណេររបស់ខ្លួន ដូចជាៈ ១)«យើង ទាំងអស់គ្នា កំពុងជាប់គាំងនៅក្នុងទស្សនៈរបស់ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមនៃប្រវត្តិសាស្ត្ររបស់យើង»។ ២) «យើងទាំងអស់គ្នាដែលធ្លាប់បានឆ្លងកាត់អំពើប្រល័យពូជសាសន៍ ពិតជាបានដឹងគ្រប់គ្នាហើយថា គ្មាននរណាម្នាក់ និងគ្មានអ្វីដែលអាចផ្តល់ជាសំណង ចំពោះអ្វីដែលបានកើតឡើងរួចមកហើយបានទេ ព្រោះថា អំពើប្រល័យពូជសាសន៍បានបំផ្លាញប្រទេសមួយតាមមធ្យោបាយជាច្រើន»។ ៣) «...សង្គមមួយមិនអាចស្គាល់ខ្លួនឯងបានទេ ប្រសិនបើមិនមានការចងចាំដ៏ត្រឹមត្រូវមួយអំពីប្រវត្តិសាស្ត្ររបស់ខ្លួន»។



សូមបញ្ជាក់ថា ជំនួបនេះបានប្រព្រឹត្តទៅនៅក្នុងវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ដែលជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំបណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលដែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួមវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត រួមចំណែកដល់ការលើកកម្ពស់ និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។ **ស៊ាង ចិន្តា**

# វគ្គបណ្តុះបណ្តាលស្តីពីការកត់ត្រាឯកសារស្តីពីសិទ្ធិមនុស្ស នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

ក្រុមការងារនៃយុត្តិធម៌អន្តរកាល របស់អង្គការក្រៅរដ្ឋាភិបាល និងអង្គការជំរុញឲ្យមានការទទួលខុសត្រូវ ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការកត់ត្រា ឯកសារស្តីពីសិទ្ធិមនុស្ស ដែលមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨។ សិក្ខាកាមនៃវគ្គបណ្តុះបណ្តាលនេះ រួមមាន៖ អ្នកតំណាងពីររូបពីក្រុមអ្នកចងក្រងឯកសារស្តីពីសិទ្ធិមនុស្សរបស់ប្រទេសហ្វីលីពីន គ្រូខ្មែរពីររូបបុគ្គលិករបស់ក្រុមការងារនៃយុត្តិធម៌អន្តរកាល និងអង្គការជំរុញឲ្យមានការទទួលខុសត្រូវចំនួនប្រាំរូប និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

គោលដៅនៃការរៀបចំវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីធ្វើបទបង្ហាញស្តីពីការផ្តល់ជំនួយបន្ទាន់សម្រាប់ជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្ស ការគាំទ្រទៅលើការបង្កើតមូលដ្ឋាន



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងកម្មាភិបាលខ្មែរក្រហមបីរូបដែលធ្លាប់ធ្វើការនៅក្នុងមន្ទីរស២១ អតីតឆ្មាំគុក និងអ្នកកត់ត្រាឈ្មោះអ្នកទោស

គ្រឹះផ្នែកច្បាប់ ស្តីពីបទល្មើសសិទ្ធិមនុស្ស ការធ្វើយុទ្ធនាការដើម្បីផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋាភិបាល ការពិភាក្សាអំពីវិធីសាស្ត្រនៃការស្រាវជ្រាវដែលទាក់ទងនឹងសិទ្ធិមនុស្ស ការចងក្រងកំណត់ត្រាប្រវត្តិសាស្ត្រ និងការសរសេររបាយការណ៍ទៅកាន់គណៈកម្មាធិការអន្តរជាតិ។

សមាជិករបស់ក្រុមការងារនៃយុត្តិធម៌អន្តរកាលឈ្មោះថា សារ៉ា សុនគឺជាអ្នករៀបចំក៏ដូចជាអ្នកធ្វើបទបង្ហាញទីមួយនៃវគ្គបណ្តុះបណ្តាល។ សារ៉ា បានផ្តល់ជាសេចក្តីសង្ខេបខ្លីអំពីយុទ្ធនាការ និងប្រវត្តិរបស់ក្រុមការងារនៃយុត្តិធម៌អន្តរកាល។ ក្នុងនោះអ្នកស្រីបានបញ្ជាក់ថាក្រុមការងារនៃយុត្តិធម៌អន្តរកាលបានបង្កើតឡើងរយៈពេលប្រមាណ៣ឆ្នាំមកហើយ ក្នុងគោលបំណងកត់ត្រា និងចងក្រងឯកសារអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ប្រទេសកូរ៉េខាងជើង។ អ្នកស្រី ក៏បានបង្ហាញអំពីវិធីសាស្ត្ររបស់ក្រុមការងារនៃយុត្តិធម៌អន្តរកាល ក្នុងការប្រមូលព័ត៌មានដូចជាចម្លើយសារភាពពីអ្នកផ្តាច់ខ្លួនពីប្រទេសកូរ៉េខាងជើង។ អ្នកស្រីបានបញ្ជាក់ថា ក្រុមការងារនៃយុត្តិធម៌អន្តរកាល ប្រើប្រាស់ព័ត៌មានដែលប្រមូលបានក្នុងការតស៊ូមតិ ហើយអ្នកស្រីក៏សង្ឃឹមថានឹងអាចប្រើព័ត៌មានទាំងនេះ នៅក្នុងការកាត់ក្តីមេដឹកនាំនៃប្រទេសកូរ៉េខាងជើងនាពេលអនាគត។ អ្នកស្រី សារា បានបន្ថែមទៀតថា អង្គការជំរុញឲ្យមានការទទួលខុសត្រូវ ដែលនឹងបង្កើតឡើងក្នុងពេលចាប់ៗនេះ មានកម្មវត្ថុក្នុងការបណ្តុះបណ្តាលអង្គការក្រៅរដ្ឋាភិបាលដទៃក្នុងការកត់ត្រាអំពីការបំពានសិទ្ធិមនុស្ស។

ក្រោយពីអ្នកស្រី សារ៉ា បានបញ្ចប់បទបង្ហាញសិក្ខាកាម



ទាំងអស់ចាប់ផ្តើមណែនាំខ្លួន និងអំពីការងាររបស់ខ្លួន ដែលសិក្ខាកាមភាគច្រើន ជាអ្នកធ្វើការទាក់ទងនឹងការកត់ត្រាអំពីការរំលោភសិទ្ធិមនុស្សនៅប្រទេសហ្វីលីពីន។ ការងាររបស់អ្នកទាំងនោះមានការទាក់ទងនឹងផ្នែក ក៏ដូចជាវិធីសាស្ត្រជាច្រើនក្នុងការដោះស្រាយ និងកត់ត្រាអំពើរំលោភសិទ្ធិមនុស្ស។

ក្រោយពីការសម្រាកហូបអាហារថ្ងៃត្រង់ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើបទបង្ហាញខ្លីមួយអំពីប្រវត្តិ កម្មវត្ថុ និងរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌល។ លោកឆាំងយុមានប្រសាសន៍ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ក្រោមច្បាប់ស្តីពីយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជារបស់សភាសហរដ្ឋអាមេរិក ដែលបានផ្តល់ជាការគាំទ្រផ្នែកហិរញ្ញវត្ថុដំបូងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកក៏បានបង្ហាញអំពីកម្មវត្ថុទាំង៥របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរួមមាន យុត្តិធម៌ ការចងចាំ ហិរញ្ញវត្ថុ សន្តិភាព និងការសះស្បើយ។ ជាចម្បង លោកឆាំងយុ បានសង្កត់ធ្ងន់ទៅលើសារសំខាន់ នៃនិរន្តរភាពសម្រាប់អង្គការក្រៅរដ្ឋាភិបាល ទាំងក្នុងផ្នែកហិរញ្ញវត្ថុនិងផ្នែកនយោបាយ។ លោកព្រមទាំងបានផ្តោតសំខាន់ទៅលើសារសំខាន់ក្នុងការកសាង និងថែរក្សាទំនាក់ទំនងជាមួយនឹងម្ចាស់ជំនួយនិងរដ្ឋាភិបាល ហើយក្នុងពេលតែមួយថែរក្សាឯករាជ្យភាពផ្នែកសេដ្ឋកិច្ចរបស់ខ្លួន។

នៅពេលដែលសិក្ខាកាមម្នាក់ ចោទសួរទៅកាន់លោក ឆាំង យុ ថាតើពេលណាដែលគួរតែចាប់ផ្តើមធ្វើការកត់ត្រា (ជាពិសេសក្នុងករណីប្រទេសហ្វីលីពីន) លោកបានឆ្លើយតបថាបច្ចុប្បន្នគឺជាពេលដែលប្រសើរបំផុត។ លោកបានបន្តទៀតថា ការកត់ត្រាបទល្មើសនៅពេលដែលវាកំពុងតែកើតឡើង ទទួលបានព័ត៌មានច្រើនជាងការចាប់ផ្តើម នៅពេលដែលសកម្មភាពនោះបញ្ចប់។ ក្នុងករណីប្រទេសហ្វីលីពីន ហេតុការណ៍ នៅដក់ជាប់ក្នុងការចងចាំរបស់ជនរងគ្រោះ ហើយឯកសារ និងភ័ស្តុតាងក៏មិនទាន់បាត់បង់។ ចំណែកក្នុងករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជាវិញ ដោយសារព្រឹត្តិការណ៍និងការប្រមូលភ័ស្តុតាងមានរយៈពេលឆ្ងាយពីគ្នា បណ្តាលឲ្យឯកសារមួយចំនួនបាត់បង់ ហើយជនរងគ្រោះជាច្រើនទទួលមរណភាព ឬបាត់ការចងចាំអំពីព្រឹត្តិការណ៍។ លោក ឆាំង យុ ក៏បានបន្ថែមទៀតថា ផ្ទុយពីកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ប្រទេសហ្វីលីពីន មិនមានឯកសារអំពីការបំពានសិទ្ធិមនុស្សក្នុងរបបមុនសម្រាប់យុវជនហ្វីលីពីនជំនាន់ក្រោយ សម្រាប់សិក្សាឡើយ ដែលអាចបណ្តាលឲ្យការបំពានសិទ្ធិមនុស្សបែបនេះអាចកើតឡើងម្តងទៀត។

ជាសេចក្តីបញ្ចប់សម្រាប់ថ្ងៃទី១ របស់វគ្គបណ្តុះបណ្តាលនេះ លោក នីកូឡាស គាំចាន់ សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចូលរួម ដើម្បីផ្តល់បទបង្ហាញខ្លីមួយអំពីតុលាការ។ លោកបានបកស្រាយអំពីនីតិវិធីក្នុងតុលាការ។ លោកបានបកស្រាយទៀតថា តុលាការតែងតែជួបប្រទះភាពលំបាកក្នុងការស្វែងរកភ័ស្តុតាង និងនាំខ្លួនអតីតកម្មាភិបាលខ្មែរក្រហមមកធ្វើជាសាក្សី។ នៅពេលដែលត្រូវបានចោទសួរ ពីមូលហេតុដែលតុលាការខ្មែរក្រហមនិងរដ្ឋាភិបាលកម្ពុជាមិនបានផ្តោតសំខាន់លើការផ្តល់សំណងទៅកាន់ជនរងគ្រោះ លោកបានឆ្លើយតបថា ដោយសារភាគីទាំងពីរមិនមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ ដើម្បីផ្តល់សំណង។ លោក ឆាំង យុ បានបន្ថែមទៅលើបញ្ហានេះថា ការផ្តល់សំណងផ្នែកហិរញ្ញវត្ថុមិនគ្រប់គ្រាន់សម្រាប់ជនរងគ្រោះឡើយ ដោយឃើញថាជនរងគ្រោះជាច្រើនមិនចង់បានអ្វីពីការវិលត្រឡប់មកវិញរបស់បងប្អូនសាច់ញាតិរបស់ខ្លួន។

វាគ្មិនចុងក្រោយ ដែលជាជំនួយការសហព្រះរាជអាជ្ញា លោក ខូមែន ខេននី បានផ្តល់បទបង្ហាញសង្ខេបអំពីការចងក្រងឯកសារពីមន្ទីរសន្តិសុខស-២១ និងការប្រមូលព័ត៌មានអំពីជនរងគ្រោះនៃទីតាំងនេះ។ លោកបានមានប្រសាសន៍ថា ការងារចម្បងរបស់លោក មានការពាក់ព័ន្ធនឹងការចងក្រងបញ្ជីជនរងគ្រោះនៅគុកទួលស្លែង តាមរយៈឯកសារដែលរកឃើញនៅទីតាំងនោះ។ លោកលើកឡើងថានៅមន្ទីរស២១ មានជនរងគ្រោះប្រមាណជា១៨០០០នាក់។ **អាលីសុន វេលខេស**

# ពិធីបុណ្យដែលនាំមកនៅស្មារតីសាមគ្គីភាព

ប្រជាជនខ្មែរអ៊ីស្លាមចាប់ផ្ដើមតមអាហារក្នុងខែរ៉ាម៉ាដាន ដែលតម្រូវឲ្យអ្នកកាន់សាសនាអ៊ីស្លាមតមអាហារចាប់តាំងពីថ្ងៃរះ រហូតដល់ថ្ងៃលិចក្នុងរយៈពេលមួយខែ គឺក្នុងខែទី៩ នៃប្រតិទិនអ៊ីស្លាម ដែលត្រូវនឹងខែ៥ ឬខែ៦ នៃប្រតិទិនគ្រិស្តសាសនា។ ខែរ៉ាម៉ាដាន បានសរសេរក្នុងគម្ពីរគួរអានដោយបានបង្ហាញ និងណែនាំផ្លូវមនុស្សជាតិ ពីអំពើល្អ និងអាក្រក់។ សាសនិកអ៊ីស្លាមមានជំនឿថា ក្នុងខែនេះ ទ្វារឋានសួគ៌បានបើកចំហរ ចំណែកទ្វារនរកបានបិទ ហើយសភាវៈអាក្រក់ត្រូវបានឃុំខ្លួននៅឋាននរក។ នៅក្នុងខែរ៉ាម៉ាដាននេះ អ្នកកាន់អ៊ីស្លាមតមអាហារមានរយៈពេល៣០ថ្ងៃវាជាពេលវេលាដ៏លំបាកមួយ ដែលអ្នកកាន់អ៊ីស្លាមត្រូវប្រឈម ដូចជា តមអាហារ ទឹក ឬការរួមដំណេក។ នៅពេលដែលព្រះអាទិត្យអស្ដង្គត ប្រជាជនខ្មែរអ៊ីស្លាមក្នុងភូមិ រួមមានសិស្សនិស្សិតខ្មែរអ៊ីស្លាម ដែលសម្រាកពីសាលា និងអ្នកកាន់សាសនា អ៊ីស្លាមទូទៅបានជួបជុំគ្នាក្នុងព្រះវិហារ ដើម្បីហូបអាហារពេលល្ងាចជាមួយគ្នាយ៉ាងរីករាយដែលមានក្រុមស្ត្រីៗប្រមាណប្រាំទៅប្រាំមួយនាក់ជាអ្នករៀបចំធ្វើម្ហូបតាំងពីព្រឹកព្រលឹម។

ក្នុងថ្ងៃតមអាហារនៃខែរ៉ាម៉ាដាន ប្រជាជនខ្មែរអ៊ីស្លាមមិនអនុញ្ញាតឲ្យនិយាយអំពីរឿងរបស់អ្នកដ៏ទៃ ឬនិយាយអាក្រក់ ហើយនៅក្នុងសហគមន៍មិនឲ្យមានជម្លោះធំដុំណាមួយកើតឡើងទេ។ សាសនា គឺជាកត្តាលើកទឹកចិត្ត និងជំរុញមនុស្សឲ្យប្រព្រឹត្តអំពើល្អ ហើយវាបាននាំមកនៅសេចក្ដីសុខស្ងប់ចិត្តដល់អ្នកដែលមានជំនឿ។

តាមរយៈការស្រាវជ្រាវ និងការសង្កេត ខ្ញុំយល់ឃើញថា ស្មារតីសាមគ្គីភាពបានកើតឡើងតាមរយៈពិធីបុណ្យនានា នៃសាសនាអ៊ីស្លាម ជាពិសេសរ៉ាម៉ាដាន។ ពិធីបុណ្យនេះ ក៏នាំមកនូវការបង្រួបបង្រួមក្នុងសហគមន៍ចាម។ ប្រជាជនចាមបានភៀសខ្លួនមករស់នៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់ពីការបាត់បង់អាណាចក្រចម្ប៉ា នាសតវត្សរ៍ទី១៥ ដែលសព្វថ្ងៃស្ថិតនៅវៀតណាមកណ្ដាល។ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលបានស្វាគមន៍ផ្ដល់ជាការស្នាក់នៅសម្រាប់ប្រជាជនខ្មែរអ៊ីស្លាម។ ប្រជាជនទាំងនេះ បានធ្វើជោគវាសនារបស់ខ្លួនក្នុងប្រទេសកម្ពុជា ហើយក៏បានទទួលរងគ្រោះពីអំពើប្រល័យពូជសាសន៍ ដូច ប្រជាជនកម្ពុជាទូទៅដែរ។ នៅក្នុងរបបខ្មែរក្រហមវិហារចាមត្រូវបានបំផ្លាញ ខ្មែរក្រហមបានហាមឃាត់ការនិយាយភាសាចាម ការប្រណិប័តន៍សាសានាអ៊ីស្លាម ចំណែកស្ត្រីត្រូវបានបង្ខំឲ្យកាត់សក់ខ្លី ដែល ខុសទៅនឹងវិន័យទំនៀមទម្លាប់របស់ចាម និងការបង្ខំ ឲ្យបរិភោគសាច់ជ្រូក និងការអនុវត្តផ្សេងៗទៀត ដែលខុសទៅនឹងវិន័យសាសនាអ៊ីស្លាម។ ទាំងអស់នេះ គឺសោកនាដកម្មដែលជនជាតិចាមទទួលរងនៅក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីសង្គ្រាមស៊ីវិលនិងរបបខ្មែរក្រហមបានបញ្ចប់ ប្រជាជនខ្មែរអ៊ីស្លាម បានចាប់ផ្ដើមស្ដារសហគមន៍របស់ខ្លួនឡើងវិញ។ នៅក្នុងឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសកម្ពុជាត្រូវបានបង្កើតឡើង ក្នុងនោះប្រជាជនកម្ពុជាទាំងអស់មានសិទ្ធិ និងជំនឿទៅ លើសាសនាដោយគ្មានការហាមឃាត់ និងបានកំណត់ សាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ ហើយសាសនាផ្សេងៗ ដូចខ្មែរអ៊ីស្លាមមានសិទ្ធិអនុវត្តសាសនារបស់ខ្លួន ទៅតាមជំនឿដែលជនជាតិខ្លួនបានប្រត្តិបត្តិ។

**អ៊ិន វណ្ណារ៉ា**

# ដំណើរទស្សនកិច្ចសិក្សាស្ដីពីសន្តិភាព និងសិទ្ធិមនុស្ស ការវេញសសៃអំ
# ការតភ្ជាប់ទីកន្លែង និងការចងចាំ







ាះចាស់និងថ្មីបញ្ចូលគ្នា ៖











# រូបថតមួយសន្លឹកបានធ្វើឲ្យខ្ញុំនឹកដល់អតីតកាល

កាលពីពេលថ្មីៗនេះខ្ញុំមានដំណើរទស្សនកិច្ចខ្លីមួយឆ្ពោះទៅស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ ហើយដំណើរទស្សនកិច្ចនេះគឺធ្វើឡើង ដើម្បីចូលទស្សនាសារមន្ទីរតាម៉ុក ទំនប់ថ្មី និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅខណៈពេលដែលខ្ញុំកំពុងធ្វើដំណើរមកដល់ស្រុកអន្លង់វែង ខ្ញុំក៏ប្រទះឃើញលោកពូម្នាក់ដែលពិការដៃទាំងសងខាង កំពុងតែសម្រាកនៅក្នុងផ្ទះស្បូវតូចមួយ បន្ទាប់ពីគាត់ពិសាអាហារថ្ងៃត្រង់រួចៗ លោកពូមានសម្បុរខ្មៅស្រអែម កម្ពស់និងមាឌសមល្មម ព្រមទាំងមានសម្លៀកបំពាក់អាវដៃខ្លីពណ៌ប្រផេះ និងខោជើងខ្លីពណ៌ខ្មៅ។ ខ្ញុំពិតជាចាប់អារម្មណ៍លោកពូម្នាក់នេះខ្លាំងណាស់ ព្រោះខ្ញុំចង់ស្វែងយល់ពីមូលហេតុនៃពិការភាពរបស់គាត់ថាតើបណ្តាលមកពីមូលហេតុអ្វីៗភ្លាមៗនោះខ្ញុំបានចូលជម្រាបសួរ និងសួរសុខទុក្ខគាត់ ហើយខ្ញុំក៏បានកាន់សៀវភៅមួយក្បាលដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» ដើម្បីជូនដល់គាត់ទុកអានពេលទំនេរពីធ្វើស្រែចម្ការ។

នៅពេលដែលខ្ញុំ បានជូនសៀវភៅគាត់ភ្លាម ស្រាប់តែគាត់ មានអារម្មណ៍ភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយក្របមុខរបស់សៀវភៅ «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» នេះមានភ្ជាប់រូបថតមួយសន្លឹក ដែលបានឆ្លុះបញ្ចាំងពីកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្ម ចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា។ បន្ទាប់ពីលោកពូឃើញរូបថតមួយសន្លឹកនេះ បានធ្វើឲ្យគាត់


នួន ស ទទួលសៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង


ចៅស្រីរបស់ នួន ស

នឹកដល់អតីតកាលដ៏ជូរចត់ ដែលគាត់ធ្លាប់បានជួបប្រទះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ លោកពូបានរម្លឹកថា គាត់មិនដែលមានអារម្មណ៍នឹកឃើញដល់អតីតកាលបែបនេះយូរមកហើយ ព្រោះគាត់មិនចង់ចងចាំប្រវត្តិសាស្ត្រដ៏សាហាវយង់ឃ្នងបែបនេះតទៀតទេ ប៉ុន្តែរូបថតមួយសន្លឹកនេះ បានធ្វើឲ្យគាត់នឹកដល់រឿងរ៉ាវដ៏សាហាវព្រៃផ្សៃរបស់មេដឹកនាំ ប៉ុល ពត ដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាទាំងការធ្វើទុក្ខបុកម្នេញ ការធ្វើទារុណកម្ម ការបង្អត់អាហារ ការធ្វើការហួសកម្លាំង និងការសម្លាប់រង្គាល។ ការនឹកឃើញដល់រឿងរ៉ាវទាំងនេះឡើង បានធ្វើឲ្យលោកពូមានអារម្មណ៍ចង់ចែករំលែកអំពីបទពិសោធន៍ជីវិតដ៏លំបាកវេទនាដែលគាត់ធ្លាប់បានជួបប្រទះ នៅក្នុងសម័យខ្មែរក្រហមជាមួយនឹងខ្ញុំបាទ។

លោកពូមានឈ្មោះ នួន ស មានស្រុកកំណើតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ សព្វថ្ងៃ ស និងប្រពន្ធកូនរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ព្រមទាំងមានមុខរបរចិញ្ចឹមជីវិត ដោយធ្វើស្រែចម្ការ។ កាលពីសង្គមចាស់ ស បានស្ម័គ្រចិត្តបួសធ្វើជាព្រះសង្ឃនៅវត្តឈូករាសី ដើម្បីសងគុណឪពុកម្តាយ និងចង់ចូលបម្រើដល់ព្រះពុទ្ធសាសនាផង។ ស បួសធ្វើជាព្រះសង្ឃ បានត្រឹមតែបួនព្រះវស្សាប៉ុណ្ណោះ ក៏កើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងដោយសេនាប្រមុខ លន់ នល់ ក្នុងឆ្នាំ១៩៧០។ ភ្លាមៗនោះ ខ្មែរក្រហមបានចាប់បង្ខំ ស និងព្រះសង្ឃ៧០អង្គផ្សេងទៀតឲ្យសឹកដើម្បីជួយបម្រើដល់ក្រុមខ្លួន។ បន្ទាប់ពី ស សឹករួចមកគាត់ក៏ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែចម្ការ និងឃ្វាលគោក្របី។ រហូតដល់ឆ្នាំ១៩៧៣ ខ្មែរក្រហមបានបញ្ចូល ស ឲ្យធ្វើជាកងទ័ពរំដោះ (កងទ័ពខ្មែរក្រហម) ដោយមានតួនាទីដើរអំពាវនាវឲ្យប្រជាជនប្រយុទ្ធប្រឆាំង ជាមួយនឹងរដ្ឋាភិបាល លន់ នល់។ ស បានធ្វើសកម្មភាពទាំងនេះរហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចភ្លាម ស ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែចម្ការ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលជាស្រុកកំណើតរបស់គាត់។ ស បានបញ្ជាក់ថា នៅភូមិ ស្រុករបស់គាត់នាពេលនោះ មានប្រជាជនថ្មីជាច្រើន គ្រួសារដែលត្រូវបានខ្មែរក្រហមជម្លៀសមកពីតំបន់ផ្សេងៗឲ្យចូលមករស់នៅ និងធ្វើស្រែចម្ការ។ ដល់ឆ្នាំ១៩៧៧ ភូមិកំណើតរបស់ ស ត្រូវបានថ្នាក់លើបញ្ជូនខាងនិរតីមកកាន់កាប់ ហើយខណៈពេលនោះ ខាងនិរតីទាំងនេះបានធ្វើការស្រាវជ្រាវ និងស៊ើបអង្កេតរកខ្សែរយៈបក្សពួកក្បត់បដិវត្តន៍ ឬអ្នកដែលមានជាប់និន្នាការក្នុងរបបណាមួយ ហើយអ្នកទាំងនេះនឹងត្រូវបានខ្មែរក្រហមយក ទៅដាក់គុក ឬសម្លាប់ចោលភ្លាមៗតែម្តង។ ប្រហែល ជាចុងឆ្នាំ ១៩៧៧ ស ត្រូវបានថ្នាក់លើបង្ខំឲ្យភ្ជួរស្រែនឹងនង្គ័លគោមួយហិចតាឲ្យរួចក្នុងរយៈពេលមួយថ្ងៃភ្លាមៗ នោះគាត់ក៏បានរិះរកវិធីសព្វគ្រប់បែបយ៉ាង ដើម្បីភ្ជួរស្រែឲ្យទាន់ផែនការរបស់អង្គការ។ មួយរំពេចនោះ ស ក៏បានរកឃើញវិធីល្អមួយគឺភ្ជួរស្រែដោយប្រើនង្គ័លបី ហើយត្រូវវាយបង្ខំគោរត់ឲ្យលឿនជាងរាល់ដងទើបអាចទាន់ផែនការរបស់អង្គការ។ ស្រាប់តែពេលនោះ គោរត់កាន់តែលឿនធ្វើឲ្យនង្គ័លគោចាក់ខ្វាស់ចូលទៅក្នុងដីជ្រៅហើយបណ្តាលឲ្យនង្គ័លគោទាំងនេះបាក់។ ភ្លាមៗនោះ ស ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា គាត់មានបំណងបំផ្លេចបំផ្លាញទ្រព្យសម្បត្តិសហករណ៍ និងមានបំណងក្បត់បដិវត្តន៍ខ្មែរក្រហម។ តមកទៀត ស ត្រូវបានខ្មែរក្រហមចាប់ដាក់គុកនៅភ្នំដូនអែន ក្នុងស្រុកវ៉ារិន្ទ។ នៅពេលដែល ស មកដល់គុកភ្លាម គាត់ត្រូវបានខ្មែរក្រហមសួរចម្លើយ រកខ្សែរយៈបក្សពួកក្បត់ ហើយព្រមទាំងបានសួរគាត់ថា តើគាត់ជាខ្សែក្បត់មកពីខាងណា? ស ក៏បានរៀបរាប់ដូចហេតុការណ៍ខាងលើថា គាត់មិនមានខ្សែរយៈក្បត់ ហើយគាត់ក៏មិនបានក្បត់បដិវត្តន៍ខ្មែរក្រហមដែរ នង្គ័លបាក់ គឺដោយសារតែគាត់បង្ខំគោឲ្យរត់លឿន ដើម្បីឲ្យទាន់ផែនការរបស់អង្គការដែលបានដាក់បញ្ជាមក។ បន្ទាប់ពី ស សារភាពរួចមក ខ្មែរក្រហមក៏មិនទាន់បានដោះលែង

គាត់ឲ្យទៅធ្វើស្រែវិញដែរ បែរជាឃុំឃាំងគាត់នៅក្នុងគុក អស់រយៈពេលពីរខែ ដើម្បីឲ្យកសាងខ្លួនៗ ក្នុងរយៈពេលពីរខែនេះ ស ក៏បានសង្កេតឃើញខ្មែរក្រហម ចាប់អ្នកទោសជាច្រើនមក សួរចម្លើយនៅក្នុងគុកដែលគាត់កំពុងជាប់ឃុំឃាំងៗ មានអ្នកទោសខ្លះជាគ្រូបង្រៀនខ្លះទៀត ជាប់និន្នាការក្នុងរបប លន់ នល់ៗ មិនតែប៉ុណ្ណោះ ស ក៏ធ្លាប់បានឃើញខ្មែរក្រហម យកអ្នកទោសដែលជាអតីតគ្រូបង្រៀនក្នុងរបប លន់ នល់ យកមកសម្លាប់ចោលប្រហែលជា ១០នាក់នៅចំពោះមុខគាត់ៗ

ពីរខែក្រោយមក ស ក៏ត្រូវបានខ្មែរក្រហមដោះលែងឲ្យមកធ្វើស្រែចម្ការនៅក្នុងភូមិកំណើតវិញហើយ គាត់ក៏បានធ្វើស្រែរហូតដល់ខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ៗ បន្ទាប់ពីខ្មែរក្រហមដួលរលំប្រហែល មួយឆ្នាំ ស ក៏បានស្ម័គ្រចិត្តចូលបម្រើជាកងទ័ពប៉ាវ៉ា ដោយមានគោលបំណងចង់ប្រយុទ្ធប្រឆាំងជាមួយ ខ្មែរក្រហមដែលនៅសេសសល់ ពីព្រោះគាត់នៅមានកំហឹងក្នុងចិត្តជាប់ជានិច្ច ដែលខ្មែរក្រហមបានចាប់គាត់ដាក់គុក ទាំងគាត់គ្មានកំហុសអ្វីសោះៗ កាល ណោះ ស ក៏បានចូលនៅក្នុងអង្គភាពដោះមីន ដែលឈរជើងនៅស្រុកអូរស្មាច់ ក្នុងខេត្តឧត្តរមានជ័យៗ

រហូតដល់ឆ្នាំ១៩៩៤ ស ត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅដោះមីននៅឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ដើម្បីធ្វើជាផ្លូវមួយសម្រាប់ឲ្យកងទ័ពប៉ាវ៉ាវាយសម្រុកចូលដល់កន្លែងកងទ័ពខ្មែរក្រហមឈរជើងៗ នៅខណៈពេលដែល ស កំពុងបំពេញភារកិច្ចក៏ស្រាប់តែគាត់បានជាន់មីន៦៩ បណ្ដាលឲ្យគាត់ពិការដៃទាំងសងខាងរហូតមកដល់សព្វថ្ងៃនេះៗ ដោយសារតែ ស មានចិត្តគុំគួន និងចងកំហឹងជាមួយខ្មែរក្រហមទើបធ្វើឲ្យគាត់បានសម្រេចចិត្តចូលបម្រើជាកងទ័ពប៉ាវ៉ារហូត ដល់ធ្លាក់ខ្លួនពិការៗ ស ក៏បានបន្ថែមថា ការគុំគួន និងការចងកំហឹងគឺវាគ្មានលទ្ធផលល្អសម្រាប់ នរណាម្នាក់ទេ ដូច្នេះទើបគាត់បានបំភ្លេចចោលនូវអ្វីដែលគាត់ធ្លាប់បានខឹងជាមួយខ្មែរក្រហមពីមុនមកៗ

តាមរយៈរឿងរ៉ាវរបស់លោកពូ នួន ស ខាងលើបានធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់ អំពីការអត់ឱនអធ្យាស្រ័យ និងការអភ័យទោស ព្រោះប្រសិនបើគ្មានជម្លោះក៏គ្មានការផ្សះផ្សាដែរៗ

**ហូ ថុនា**



ផ្លូវចូលទៅផ្ទះ នួន ស

# សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង០០២

## ស្រមោលត្រួតគ្នារបស់ ប៉ុល ពត ៖ នួន ជា និង ខៀវ សំផន

*(តពីលេខមុន)*

***ខៀវ សំផន***

*ចំណែកការផាររស់នៅរាល់ថ្ងៃហូបបាយទឹកទាំងលោក ប៉ុល ពត ទាំងលោក នួន ជា ហូបបាយជាមួយយើងខ្ញុំ ហូបបាយជាមួយខ្ញុំ ទាំងអស់គ្នាហូបបាយរួមអ៊ីចឹងៗ អត់មានអីដោយឡែកៗ*

នួន ជា និង ខៀវ សំផន មិនត្រឹមតែជាជនស្មោះត្រង់នឹង ប៉ុល ពត ប៉ុណ្ណោះទេ ពួកគេថែមទាំងជាអ្នកជំនិតនិងជាអ្នកគាំទ្រជិតស្និទ្ធបំផុតរបស់ ប៉ុល ពត។ នួន ជា បានគាំទ្រចម្លើយរបស់ ខៀវ សំផន ថាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នកទាំងបីបានហូបអាហារជាមួយគ្នាជាប្រចាំ ហើយ នួន ជា បានថ្លែងថា ពួកគាត់ក៏បានចូលរួមវគ្គស្វ័យទិតៀនជាមួយគ្នាដែរ។

ប៉ុលពត,នួនជានិងខៀវសំផនមានប្រវត្តិស្រដៀងគ្នាក្នុងនាមជាបញ្ញវន្តម្នាក់ៗ បានកោតសរសើរ និងផ្សព្វផ្សាយអំពីមនោគមវិជ្ជារបស់បក្សខ្លួន ដែលបានអនុវត្តបដិវត្តន៍កសិកម្មសង្គមនិយមជ្រុល។ អ្នកទាំងបីបានសិក្សានៅក្រៅប្រទេស ប៉ុល ពត និង ខៀវ សំផន នៅប្រទេសបារាំង ចំណែក នួន ជា នៅប្រទេសថៃ។ ខណៈដែលទទួលខុសត្រូវចំពោះការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់មនុស្សរាប់ពាន់នាក់នោះ ម្នាក់ៗស្ថិតនៅខាងក្រោយជួរមេដឹកនាំ។ ខុសពីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ផ្សេងទៀត ដូចជា សោ ភឹម, តាម៉ុក, វន វ៉េត, សុន សេន, កុយ ធួន និង រស់ ញឹម ដែលមានបទពិសោធន៍ច្រើនក្នុងការបញ្ជាកម្លាំងប្រយុទ្ធផ្ទាល់នោះ ប៉ុល ពត, នួន ជា និង ខៀវ សំផន ស្ថិតនៅឆ្ងាយពីសមរភូមិ។

ទាំងនួនជាទាំងខៀវសំផននៅតែស្មោះត្រង់នឹងប៉ុលពតពេញមួយជីវិតរបស់គាត់និងនៅបន្តការពារអំពើរបស់ប៉ុល ពត យូរមកទៀតក្រោយពេលមរណៈភាពរបស់ ប៉ុល ពត។ ទោះបីជាអង្គហេតុដែលគាត់បានបន្ទោស ប៉ុល ពត ចំពោះ ស-២១ក៏ដោយ ក៏ខៀវសំផនបានសរសេរក្នុងសៀវភៅមួយរបស់គាត់ថា «មេៗខ្មែរក្រហមទាំងអស់ចាត់ទុក ប៉ុល ពត ជាមគ្គុទេសក៍ជាប្រវត្តិសាស្ត្រដែលវិភាគនិងសម្រេចមិនចេះខុស»។ នួន ជា បានរៀបរាប់ថា ប៉ុល ពត ជា«មិត្ត និងជាយុទ្ធមិត្ត» និងជា«មនុស្សល្អ» ដែល«បានលះបង់ខ្លួនដើម្បីជាតិ»។

នៅពេលដែល នួន ជា គឺជាលេខាបក្សក្រុងភ្នំពេញនោះ ប៉ុល ពត គឺជាអនុរបស់គាត់។ នៅពេលសមាជបក្សឆ្នាំ ១៩៦០ នួន ជា បានទទួលមុខតំណែងមានអំណាចបំផុតទីពីរក្នុងបក្សជាអនុលេខាខណៈដែល ប៉ុល ពត គឺជាសមាជិកគណៈអចិន្ត្រៃយ៍។ នៅពេលដែលអតីតលេខាបក្ស ទូ សាមុត បានបាត់ខ្លួនក្នុងឆ្នាំ១៩៦២ នួន ជា បានអះអាងថា រូបគាត់បានបញ្ចុះបញ្ចូល ប៉ុល ពត ឲ្យយកតំណែងកំពូលនេះ។ ថេត សម្បត្តិ ដែលជាអ្នកសម្ភាសន៍ នួន ជា អស់រយៈពេលជាច្រើនឆ្នាំ បានសរសេរអំពីទំនាក់ទំនងរវាង ប៉ុល ពត និង នួន ជា ថា៖

ក្នុងកំឡុងពេលដែលពួកគេកាន់អំណាចអ្នកទាំងពីរស្ទើរតែមិនអាចបំបែកពីគ្នាបានផង ដោយចំណាយពេលជាច្រើនជាមួយគ្នា ជាងនៅជាមួយគ្រួសារខ្លួន ឬជាមួយមេដឹកនាំផ្សេងទៀត ហើយមុនពេលបង្ហាញ ផែនការអ្វីមួយ ប៉ុល ពត និង នួន ជា តែងតែពិភាក្សាគ្នាជាមុន ដើម្បីដាក់ចេញនូវ

ទស្សនៈ និងធ្វើឲ្យច្បាស់ថា ពួកគេពិតជាយល់ស្របគ្នាលើគ្រប់ចំណុចទាំងអស់។

នួន ជា បានថ្លែងថា គាត់ និង ប៉ុល ពត មិនមានទំនាស់ ឬបញ្ហានឹងគ្នាទេ ក្នុងកំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានថ្លែងថា៖

*ពួកគេត្រឹមតែហៅគាត់និងខ្ញុំថា បងធំទី១ និង បងទី២ ...ខ្ញុំមិនមែនជាដៃស្តាំ ឬដៃឆ្វេងរបស់ ប៉ុល ពត ទេ...ពួកយើងមានឋានៈស្មើគ្នា។ ប៉ុល ពត មិនបម្រើខ្ញុំ ហើយខ្ញុំក៏មិនបម្រើគាត់ដែរ។ យើងទាំងពីរនាក់បម្រើបក្សដូចគ្នា។*

នួន ជា បាននិយាយថា នៅពេលដែលពួកគេចូលរួមវគ្គស្ម័យទិតៀនជាមួយគ្នា ប៉ុល ពត ទិតៀនគាត់ថា «តឹងតែងពេក»។ ទោះបីជាមានការសម្លាប់ និងទុក្ខវេទនាទាំងអស់របបនេះក៏ ដោយការរិះគន់តែមួយគត់ដែល នួន ជា មានចំពោះ ប៉ុល ពត គឺការប្រាប់គាត់ថា គាត់ធ្វើការច្រើនពេក និងមិនបានយកចិត្តទុកដាក់ប្រពន្ធគាត់ឲ្យបានគ្រប់គ្រាន់ទេ។

ខៀវ សំផន គឺជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ម្នាក់ដែលល្បីល្បាញខ្លាំងជាងគេទាំងក្នុងចំណោមប្រជាជនកម្ពុជាទាំងក្នុងសហគមន៍អន្តរជាតិ ទោះបីជាបានចូលរួមក្នុងការតស៊ូប្រដាប់អាវុធរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយមេដឹកនាំជាន់ខ្ពស់ឯទៀតរបស់បក្សក៏ដោយ។ គាត់ធ្វើការជាចំហរក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ខណៈដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាភាគច្រើនបានធ្វើជាភ្នាក់ងារសម្ងាត់។ ខៀវ សំផន បានបង្កើតកាសែតផ្ទាល់ខ្លួនរបស់គាត់ ត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ និងបានបម្រើរដ្ឋាភិបាល សម្តេច សីហនុ ដែលគាត់បានទទួលការគោរពយ៉ាងទូលំទូលាយចំពោះភាពមិនពុករលួយ។ ទើបតែនៅឆ្នាំ ១៩៦៧ ប៉ុណ្ណោះ ដែលរូបគាត់បានចូលរួមជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតក្នុងព្រៃម៉ាគី។

ទំនាក់ទំនងរបស់ ខៀវ សំផន និង ប៉ុល ពត អាចបកត្រឡប់ទៅក្រោយវិញក្នុងឆ្នាំ១៩៤៣ នៅពេលដែលអ្នកទាំងពីរចូលរៀននៅវិទ្យាល័យកំពង់ចាម ជាមួយគ្នា។ ខៀវ សំផន បានប្រាប់អ្នកសិក្សាស្រាវ ជ្រាវម្នាក់ថា គាត់ និង ប៉ុល ពត បានចូលរួមក្នុងមហោស្រពមួយ និងបានធ្វើដំណើរជាមួយគ្នារយៈពេលមួយខែទៅខេត្តកំពង់ចាមក្នុងឆ្នាំ១៩៤៥។ ខៀវ សំផន ក៏មានប្រវត្តិយូរអង្វែងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាក្នុងប្រទេសកម្ពុជា ក្នុងការអះអាងថ្មីៗជាច្រើនទៀត។ ដូចគ្នានឹង ប៉ុល ពត ដែរ ខៀវ សំផន បានសិក្សានៅប្រទេសបារាំងជាទីកន្លែងដែលគាត់ចូលរួមជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ ១៩៥៩។ ទំនាក់ទំនងដ៏ជិតស្និទ្ធរបស់ ខៀវ សំផន ជាមួយនឹង ប៉ុល ពត និង នួន ជា តួនាទីសាធារណៈរបស់គាត់ និងកេរ្តិ៍ឈ្មោះល្បីល្បាញជាសាធារណៈរបស់គាត់ បញ្ជាក់បានថា ឥទ្ធិពលរបស់គាត់មានហួសឆ្ងាយពីឋានៈក្នុងបក្សរបស់គាត់។ កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់គាត់ ធៀបជាមួយនឹងខ្មែរក្រហមសម្ងាត់ដែលប្រជាជនកម្ពុជាជាច្រើននាក់ និង



ខៀវ សំផន និងសហមេធាវីការពារក្តី ក្នុងសាលស

អស់រយៈពេលជាយូរ សូម្បីតែសម្តេច សីហនុ បានគិតថា ខៀវ សំផន គឺជាមេដឹកនាំចលនានេះ។

ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលឆ្នាំ១៩៧០-៧៥ ខៀវ សំផន បានបម្រើការជាអនុរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានធ្វើឲ្យគាត់ក្លាយជាខ្មែរក្រហម ដែលមានឋានៈខ្ពស់ជាងគេ នៅក្នុងរដ្ឋាភិបាលដែលមានតែឈ្មោះដឹកនាំ ដោយព្រះអង្គម្ចាស់ សីហនុ។ ខៀវ សំផន បានអួតអាងថា រូបគាត់បានដើរតួនាទី«សំខាន់ បើទុកជាមិនអាចខ្វះបានក្តី» នៅក្នុងជ័យជម្នះរបស់ខ្មែរក្រហម ដោយមានការចូលរួមចំណែករបស់គាត់យ៉ាងសំខាន់ ក្នុងការ«ទំនាក់ទំនង»រវាងបក្សកុម្មុយនីស្តកម្ពុជា និងសម្តេចនរោត្តម សីហនុ ដែលមិនស្គាល់ ប៉ុល ពត។ ក្នុងឆ្នាំ១៩៧៦ ខៀវ សំផន បានជំនួសសម្តេច នរោត្តម សីហនុ ក្នុងឋានៈជាប្រមុខរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ និងជាថ្មីម្តងទៀតជាមុខមាត់សាធារណៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចដែលគាត់បានអួតអាងនៅក្នុងបទសម្ភាសន៍ភាពយន្តឯកសារជាមួយនឹងអ្នកការសែតបរទេសថា «រូបភាពរបស់ខ្ញុំ និងឈ្មោះខ្ញុំតំណាងឲ្យប្រទេសកម្ពុជា»។ ខណៈដែល ខៀវ សំផន បានក្លាយជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមក្នុងឆ្នាំ១៩៧១ និងជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៧៦ ការចូលរួមចំណែករបស់គាត់ ក្នុងការលើកកម្ពស់គោលនយោបាយលើសពីតួនាទីផ្លូវការរបស់គាត់នៅក្នុងបក្សទៅទៀត។

ទាំង នួន ជា ទាំង ខៀវ សំផន ម្តងហើយម្តងទៀត បានបង្ហាញពីការលះបង់របស់ពួកគេចំពោះ ប៉ុល ពត សូម្បីតែរយៈពេលដ៏យូរបន្ទាប់ពីមរណៈភាពរបស់ ប៉ុល ពត ក៏ដោយ។ នៅក្នុងភាពយន្តឯកសារ ការប្រឈមមុខនឹងអំពើប្រល័យ


វនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


នួន ជា ក្នុងសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ពូជសាសន៍ (Facing Genocide) ដែលត្រូវបានធ្វើឡើងក្នុងរយៈពេលដ៏ខ្លីមុនការចាប់ខ្លួនគាត់ក្នុងឆ្នាំ២០០៧ ខៀវ សំផន បាននិយាយថា គាត់គោរព ប៉ុល ពត ដោយបានហៅគាត់ថាជា«មេដឹកនាំដ៏អស្ចារ្យ» និងបាននិយាយថា «ខ្ញុំតាមគាត់គ្រប់ពេលដូចស្រមោលអ៊ីចឹង»។ គាត់រំជួលចិត្តដែលនិយាយអំពី ប៉ុល ពត ដោយប្រាប់អ្នកកាសែតថា «ខ្ញុំនៅតែឃើញគាត់នៅលើភ្នំក្រវាញ។ ខ្ញុំតែងតែរក្សារូបភាពគាត់ក្នុងចិត្តរបស់ខ្ញុំ»។ នៅពេលសួរដោយអ្នកផលិតខ្សែភាពយន្តថា តើគាត់នឹក ប៉ុល ពត ទេ? ខៀវ សំផន បានឆ្លើយថា «នឹកពីព្រោះគាត់មានទស្សនៈពិសេស»។

ដូចគ្នានឹង ប៉ុល ពត និង នួន ជា ដែរ ខៀវ សំផន គឺជាបញ្ញវន្តម្នាក់ ដែលបានប្រើប្រាស់មុខតំណែងមានឥទ្ធិពលរបស់ខ្លួន ដើម្បីញុះញង់ឲ្យមានអំពើហិង្សា ប្រឆាំងនឹងអ្នកផ្សេងទៀតខណៈដែលតែងតែធ្វើឲ្យខ្លួននៅឆ្ងាយពីសមរភូមិ។ ខៀវ សំផន បានប្រើប្រាស់មុខងារ និងកិត្តិនាមរបស់គាត់ និងគោលនយោបាយនានារបស់ ប៉ុល ពត និង នួន ជា។ ទោះបី«ការរៀនប្រៀនទុយមុយ»របស់គាត់ក៏ដោយគឺ ខៀវ សំផន ដែលនៅថ្ងៃបញ្ចប់នៃរបបសាធារណរដ្ឋខ្មែរ បានអំពាវនាវឲ្យសម្លាប់«ជនក្បត់ទាំងប្រាំពីរ» និងសឲ្យឃើញនូវជោគវាសនាស្រដៀងគ្នា ដែលបានកើតមានលើរាល់នាយទាហានរបបសាធារណរដ្ឋខ្មែរទាំងអស់ដែលខកខានមិនបានធ្វើតាមតម្រូវការរបស់ខ្មែរក្រហមឲ្យចុះចាញ់។ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ គឺ ខៀវ សំផន ដែលតែងតែញុះញង់កម្មាភិបាលខ្មែរក្រហមឲ្យអនុវត្តគោលនយោបាយឃោរឃៅ និងគួរឲ្យភ័យខ្លាចក្នុងការកំណត់គោលដៅលើ«ខ្មាំង»របស់របបនោះ។ សម្រាប់ថ្ងៃបុណ្យខួបជ័យជម្នះខែមេសា ឆ្នាំ១៩៧៧ របស់ខ្មែរក្រហម ខៀវ សំផន បានទទូចសុំឲ្យកម្មាភិបាល «លើកកម្ពស់ស្មារតី ប្រុងប្រយ័ត្នបដិវត្តន៍គ្រប់ពេលវេលាប្រឆាំងនឹងសត្រូវមកពីគ្រប់ទិសទីទាំងក្នុង និងក្រៅប្រទេស»។ សម្រាប់ធ្វើបុណ្យខួប ឆ្នាំ១៩៧៨វិញ គាត់បានទាមទារថា កម្មាភិបាលត្រូវប្តេជ្ញាចិត្តៈ

*កម្ទេចឲ្យអស់ រាល់បណ្តាភ្នាក់ងារយួនឈ្លានពានពួក វៀតទីនិយមវៀតណាមសាហាវព្រៃផ្សៃ ដែលមាននៅក្នុងអង្គភាពព្រមទាំងទឹកដីប្រទេសកម្ពុជាយើង...។ កម្ទេចឲ្យអស់រាល់បណ្តាភ្នាក់ងារ សេ អ៊ី អា... កម្ទេចចោលខ្មាំងតាមគ្រប់រូបភាពទាំងអស់។ អ្នកដែលត្រូវបានកំណត់ថា ជាជនក្បត់ជាតិសហការជាមួយនឹង សេ អ៊ី អា, កាហ្សេបេ ឬវៀតណាម មានចំនួនសរុប ជាងពាក់កណ្តាលនៃមេដឹកនាំកំពូលផ្នែកយោធា និងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានមុខតំណែងនៅក្នុងគណៈកម្មាធិការមជ្ឈិម លេខាភូមិភាគប្រាំមួយនាក់ក្នុងចំណោមភូមិភាគទាំងប្រាំពីរ ភូមិភាគឧត្តរចាស់ (កុយ ធួន), ភូមិភាគឧត្តរថ្មី (កង ចាប), ភូមិភាគឦសាន (យ៉ា), ភូមិភាគពាយ័ព្យ (រស់ ញឹម), ភូមិភាគបស្ចិម (ជូ ជេត), និងភូមិភាគបូព៌ា (សោ ភឹម), លេខាតំបន់ស្វយ័តនៅតំបន់សៀមរាប (សុត), តំបន់ព្រះវិហារ (ហង់) និងតំបន់ក្រចេះ (យី), មេបញ្ជាការប្រាំរូប ក្នុងចំណោមមេបញ្ជាការទាំងប្រាំបួនរូបរបស់កងពលនៃកងទ័ពបដិវត្តន៍កម្ពុជា កងពល១៧០ (ចក្រី), កងពល២៩០ (គាល់), កងពល៣១០ (អឿន), កងពល៤៥០ (សួង) និងកងពល៩២០ (ឈិន), និងសមាជិកគណៈអចិន្ត្រៃយ៍ វន វ៉េត។*

ប៉ុល ពត នួន ជា និង ខៀវ សំផន ពិតជាបានដឹងថាបក្សកុម្មុយនីស្តកម្ពុជា មិនអាចយកជ័យជម្នះលើរដ្ឋាភិបាល លន់ នល់ និងមិនអាចទប់ទល់ទៅនឹងការឈ្លានពានបែបព្រមានរបស់វៀតណាមក្នុងឆ្នាំ១៩៧៧ បាននោះទេ ប្រសិនបើពាក់កណ្តាលនៃថ្នាក់ដឹកនាំបក្សគឺជាជនក្បត់ ឃុបឃិតជាមួយនឹងសត្រូវដែលពួកគេកំពុងប្រយុទ្ធនោះ។ ប្រសិនបើអ្នកទាំងអស់នេះរួម គំនិតគ្នាប្រឆាំងនឹងថ្នាក់ដឹកនាំមែននោះ ពួកគេអាចទម្លាក់ ប៉ុល ពត ចេញពីអំណាចបានយ៉ាងងាយ ដោយសារតែពួកគេ គ្រប់គ្រងកងកម្លាំងប្រដាប់អាវុធភាគច្រើនរបស់ខ្មែរក្រហម។ ជាជាងប្រើកម្លាំងលើសលប់របស់ខ្លួនប្រឆាំងនឹងរបប ប៉ុល ពត និងខកខានមិនបានតទល់នឹងការចាប់ខ្លួនពួកគេ បញ្ជាក់ឲ្យឃើញថា ការបោសសម្អាតនោះ គឺជាប្រតិ

កម្មលក្ខណៈ មិនទុកចិត្តគ្នារបស់ ក្រុម ប៉ុល ពត ដើម្បីទប់ស្កាត់កុំឲ្យមានការជំទាស់ណាមួយ ទៅនឹងការដឹកនាំដ៏សាហាវយោរយៅ និងគ្មានប្រជាប្រិយភាពរបស់ខ្លួន។

ឋានៈពិសេសរបស់ ខៀវ សំផន ជាសាវ័កដ៏គួរឲ្យទុកចិត្តរបស់ ប៉ុល ពត ធានាដល់ការរស់រានមានជីវិតរបស់គាត់។ ការណ៍នេះបានបង្ហាញយ៉ាងច្បាស់បំផុតនៅក្នុងហេតុការណ៍មួយនៅចុងឆ្នាំ១៩៧៨ នៅចុងបញ្ចប់នៃរបបនោះ។ នៅពេលនោះ បដិវត្តន៍កំពុងស្ថិតនៅក្នុងដំណើរការ«ស៊ីកូនឯង»។ កម្មាភិបាលរាប់ពាន់នាក់ត្រូវបានបញ្ជូនមកមន្ទីរ ស-២១។ នួន ជា បានបញ្ជាក់សក្ខីកម្មរបស់ ឌុច ថា នៅក្នុងបរិយាកាសនៃការបោសសម្អាតទ្រង់ទ្រាយធំនេះ ឌុច បានជូនដំណឹងទៅ នួន ជា អំពីចម្លើយសារភាពពីមន្ទីរស-២១ ដែលបានឆ្លើយដាក់ ខៀវ សំផន។ នួន ជា បានឆ្លើយ តបទាំងកំហឹងទៅកាន់ ឌុច ដោយនិយាយថា«កុំរាយការណ៍ដូចនេះទៀត ហើយកុំនិយាយរឿងនេះទៀត។ ខ្ញុំមិនជឿលើចម្លើយសារភាព ដែលទម្លាក់កំហុសលើ ខៀវ សំផន ឡើយ»។ ខណៈដែលមនុស្សរាប់ពាន់នាក់ផ្សេងទៀត ត្រូវបានដាក់ទោសដោយត្រូវចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ ផ្អែកលើភស្តុតាងបានមកពីចម្លើយសារភាពទាំងនោះ នួន ជា បានធ្វើឲ្យប្រាកដថា ជោគវាសនាដូចគ្នានេះ មិនអាចកើតមានលើ ខៀវ សំផន នោះឡើយ ដែលជាគូកនប្រចាំថ្ងៃរបស់គាត់ និងជាសាវ័កដែល ប៉ុល ពត ទុកចិត្ត។

## ការសម្លាប់ពួកមន្ត្រីរដ្ឋការ នៃសាធារណរដ្ឋខ្មែរ

លោកស្រី ជាំង ស្រីមុំ មកពីស្រុកត្រាំកក់ ៖

*ប្រជាជនមូលដ្ឋានអញ្ចឹងដែរ បើមិនមានការពាក់ព័ន្ធអី មានបងប្អូនធ្វើធំធ្វើអីកាលជំនាន់ហ្នឹង ក៏គេស្រាវ ជ្រាវដែរថា «អូ! បងប្អូនវាសុទ្ធតែអ្នកធំ»។ អញ្ចឹងគេៗត្រូវចាប់យកទៅសម្លាប់ចោលនៅពេលហ្នឹងដែរ។ ពាក្យមួយដែលគេនិយាយច្រើនថា បើសម្លាប់ហើយរំលើងឲ្យអស់ទាំងឫសទាំងគល់អីទាំងអស់។*

ភ្លាមៗក្រោយពីការដួលរលំនៃកងទ័ពសាធារណរដ្ឋខ្មែរដែលដើមឡើយដឹកនាំដោយ លន់ នល់ របបនេះបានកំណត់គោលដៅលើនាយទាហាន និងមន្ត្រីរដ្ឋការជាន់ខ្ពស់ដើម្បីសម្លាប់ចោល។ កូនទាហាន ធម្មតា និងអ្នកដែលជាប់ទាក់ទងនឹងអតីតទាហានសាធារណរដ្ឋខ្មែរត្រូវបានគេសង្ស័យ និងធ្វើទុក្ខបុកម្នេញ ដែលមានមនុស្សជាច្រើនចុងបញ្ចប់ត្រូវបានឃុំខ្លួន ឬសម្លាប់ចោល។ សូម្បីតែកម្មាភិបាលដើងចាស់របស់ខ្មែរក្រហមខ្លះ មានមុខតំណែងដ៏សំខាន់ដែរនោះ បានផ្តល់សក្ខីកម្មថា ពួកគេមានការភ័យខ្លាច និងមានអារម្មណ៍តែលតោល ពីព្រោះពួកគេមាន សមាជិកគ្រួសារដែលធ្លាប់ជាផ្នែកមួយនៃរបប លន់ នល់។

ភស្តុតាងសាក្សី និងឯកសារដែលនៅសល់បញ្ជាក់ ឲ្យឃើញថា របបនោះបានកំណត់ គោលដៅលើអ្នកទាំងឡាយណាដែលជានាយទាហាន លន់ នល់ ឬមានមុខតំណែងជាមន្ត្រីរដ្ឋការថ្នាក់ខ្ពស់ ក្នុងរបបសាធារណរដ្ឋខ្មែរ។ ឯកសារជាច្រើនដែលបានមកពីមន្ទីរ សន្តិសុខក្រាំងតាចាន់ ក្នុងស្រុកត្រាំកក់ បង្ហាញថា កម្មាភិបាលត្រូវបានណែនាំឲ្យស្វែងរកអ្នកដែលមានបណ្តាស័ក្តិពីរបបមុន ឯកសារមួយបានរាយការណ៍ថា «យើងឲ្យឈ្លបឃុំនាំអ្នកដែលមានបណ្តាស័ក្តិ»។

ឃុំពពេល បានរាយការណ៍ក្នុងខែមេសា ឆ្នាំ១៩៧៧ ទៅកាន់«អង្គការ» ស្រុកត្រាំកក់ថា «បន្ទាប់ពី អ ក ក្នុងការប្រុងប្រយ័ត្នខ្លាំងបោសសម្អាត ពួកទាហានខ្មាំងដែលមានបណ្តាស័ក្តិ ក្នុងនោះបានតាម ដានពិនិត្យឃើញមានឈ្មោះដូចខាងក្រោមនេះ»។ ឃុំ ពពេល ក្រោយមកអះអាងថា បានកំណត់អត្តសញ្ញាណទាហានស័ក្តិ១ម្នាក់ និងអតីតបុគ្គលិកក្រសួងអភិវឌ្ឍសហគមន៍ម្នាក់។

ក្នុងខែមេសា ឆ្នាំ១៩៧៧ កម្មាភិបាលបានរាយការណ៍ថា «យើងខ្ញុំក្នុងសាខាមូលដ្ឋានសហករណ៍ ឃុំតាភេម បានពិនិត្យ និងបោសសម្អាតខ្មាំងដែលមានបណ្តាស័ក្តិ ក្រោយពីបានទទួលមតិណែនាំរបស់បក្សចុះពិនិត្យដិតដល់ទៅឃើញថានៅមានអ្នកមានបណ្តាស័ក្តិ៦នាក់ផ្សេងទៀត ហើយឈ្មោះនេះ ធ្វើសកម្មភាពផ្លាស់ឈ្មោះរបស់ខ្លួនជារៀងរាល់ខែ»។

បទបញ្ជាយោធាមួយ ដែលចេញក្នុងខែមិថុនា ឆ្នាំ១៩៧៥

ដោយមេបញ្ជាការកងពលតូចភូមិភាគ ពិសេសរាយការណ៍ឲ្យមជ្ឈិមបក្សនោះ បានបញ្ជាឲ្យសម្លាប់នាយទាហានរបបសាធារណរដ្ឋខ្មែរចំនួន១៦នាក់។ នាយទាហានមានឋានន្តរស័ក្តិពីស័ក្តិមួយទៅវរសេនីយ៍ឯក ហើយបទបញ្ជានោះបានសរសេរថា ទាំងអស់នេះ «បក្សពិនិត្យ និងសម្រេចកម្ទេច»។

ភាពផ្សេងគ្នាដែលថា គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ បានធ្វើវាងនាយទាហាន ស័ក្តិខ្ពស់ដែលត្រូវសម្លាប់ចោល និងទាហានសាធារណរដ្ឋខ្មែរធម្មតា ដែលត្រូវបានគេសង្ស័យ និងជានិច្ចកាលនាំឲ្យមានការសម្លាប់ចោលនោះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍មួយចុះខែមេសា ឆ្នាំ១៩៧៧ ពី យ៉ុំពពេល ទៅកាន់អាជ្ញាធរស្រុកត្រាំកក់៖

ចំពោះអ្នកមានបណ្ដាស័ក្តិ យើងខ្ញុំសូមជូនជាបន្តបន្ទាប់ ហើយពួកទាហាននិងគ្រូខ្លះៗដែលមានសមាសភាពបំផ្លាញ... ប្រឆាំង ប/វ យើងសូមអង្គការឲ្យយោបល់ដែរ ឬឲ្យសម្រេច។

យោងតាម អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ សេចក្តីសម្រេចសម្លាប់នាយទាហានមានបណ្ដាស័ក្តិបានកើតឡើងភ្លាមៗ ក្រោយពេលជ័យជម្នះរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងបទសម្ភាសន៍វាងលោក Steve Heder ជាមួយនឹង អៀង សារី ក្នុងឆ្នាំ១៩៩៦ បានកត់សម្គាល់ឃើញថា កំណត់ត្រាឯកសារបញ្ជាក់យ៉ាងច្បាស់ថា «អ្នកដែលត្រូវសម្លាប់រួមមាននាយទាហាន មន្ត្រីថ្នាក់ខ្ពស់ ភ្នាក់ងារសម្ងាត់ និងក្រុមមនុស្សផ្សេងទៀត ប៉ុន្តែមិនមានកូនទាហានធម្មតា និងមន្ត្រីរដ្ឋការថ្នាក់ទាបដូចជាគ្រូបង្រៀននោះទេ» ដែល អៀងសារី ឆ្លើយតបថា ក្រោយពេលដែលខ្មែរក្រហមបានចូលមកទីក្រុងភ្នំពេញ ពួកគេបានឆែកឆេរផ្ទះរបស់នាយទាហាន និងបានរកឃើញសព្វាវុធដូច្នេះសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង ប្រហែលជាថ្ងៃទី២០ ខែមេសា «ត្រូវធ្វើអ្វីក៏ដោយដើម្បីធ្វើយ៉ាងណាកុំឲ្យពួកគេធ្វើការវាយបកប្រឆាំងនឹងបដិវត្តន៍វិញ»។

បញ្ញវន្តឆ្វេងនិយមម្នាក់ដែលបានឈប់នៅក្រុងហាណូយ ក្នុងខែធ្នូ ឆ្នាំ១៩៧៦ ត្រូវបានជូនដំណើរដោយស្ថានទូតកម្ពុជាប្រជាធិបតេយ្យថា «មានតែនាយទាហានឋានៈវរសេនីយ៍ឡើងទៅ» និងនគរបាល«ភ្នាក់ងារសម្ងាត់» តែប៉ុណ្ណោះ គឺជាគោលដៅសម្លាប់។

ក្រុមគ្រួសារទាំងមូល ត្រូវបានសម្លាប់ចោល ដោយមកពីការជាប់ទាក់ទងនឹងនាយទាហាន និងមន្ត្រីរដ្ឋការនៃ



សាធារណខ្មែរ។ កូនចំនួនបួននាក់របស់អតីតមន្ត្រីក្រសួងអប់រំ លោក ថាច់ ដា ត្រូវបានសម្លាប់ចោលនៅមន្ទីរស-២១ ហើយប្រពន្ធរបស់គាត់ត្រូវបានសម្លាប់ចោល បន្ទាប់ពីបានដាក់ឲ្យនៅក្រោមការពិសោធន៍វះកាត់។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៧ យ៉ុំពពេល បានអះអាងទៅកាន់ស្រុកត្រាំកក់ថា «គ្រួសារទាហានចំនួន១០៦គ្រួសារ» ត្រូវបាន«អង្គការកម្ទេច»។

## ការផ្ទេរសិទ្ធិអំណាចសម្លាប់

*សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន, ៣០ មីនា ១៩៧៦*

***សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ***

*សំណូមពរ៖*



*១) ឲ្យមានក្របខណ្ឌ ក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តន៍របស់យើង។*

*២) ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង។*

*ទាំងអស់នេះ ដើម្បីពង្រឹងរដ្ឋអំណាចរបស់យើង។*

- *បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច។*
- *ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។*
- *តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច។*
- *កងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច។*

នៅក្នុងរបបដែលគ្មានច្បាប់ ឬតុលាការ សេចក្តីសម្រេចអំពីអាយុជីវិត ឬការស្លាប់រស់របស់ប្រជាពលរដ្ឋត្រូវបានផ្ទេរដោយមេដឹកនាំរបបឲ្យទៅកម្មាភិបាលថ្នាក់ក្រោមៗ ឥឡូវនេះដោយប្រឈមនឹងលទ្ធភាពដាក់ឲ្យទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួន នៅក្នុងការសម្លាប់ប្រជាជននៃរបបខ្មែរក្រហម នួន ជា និង ខៀវ សំផន ព្យាយាមគេចចេញពីការស្តីបន្ទោសនេះ ដោយការដាក់ឲ្យទៅអ្នកនៅពីក្រោមថ្នាក់ដឹកនាំកំពូល រួមទាំងមេដឹកនាំ ដែលក្រោយមកត្រូវបានបោសសម្អាតដោយរបបនេះ។ យ៉ាងណាក៏ដោយភ័ស្តុតាងបានបង្ហាញថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ មិនបានធ្វើអ្វីសោះដើម្បីរារាំងឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តដោយអាជ្ញាធរមូលដ្ឋាន និងមិនបានផ្តន្ទាទោសនរណាម្នាក់ ចំពោះការសម្លាប់ទាំងនេះទេ។ ផ្ទុយទៅវិញ មេដឹកនាំមជ្ឈិមបានផ្តល់យ៉ាងច្បាស់ក្រឡែតដល់មេដឹកនាំភូមិភាគ និងយោធានូវសិទ្ធិសម្រេច «កម្ទេច» គឺសម្លាប់ដោយគ្មាននីតិវិធីច្បាប់។ ជាងនេះទៀត មេដឹកនាំមជ្ឈិមរួមមាន នួន ជា និង ខៀវ សំផន ដូចដែលបានរៀបរាប់ពិស្តារនៅខាងក្រោមសារណានេះ បានពន្យុះឲ្យមានការសម្លាប់ដោយការដាស់តឿនយ៉ាងខ្ជាប់ខ្ជួន ដើម្បីបំភ័យកម្មាភិបាលឲ្យដកឫស និងកម្ទេចខ្មាំង។ ការសង្ស័យណាមួយដែលដល់កម្រិតសាហាវ ត្រូវបានបំបាត់ដោយយុទ្ធនាការសម្លាប់គ្មានត្រាប្រណីរបស់មជ្ឈិមផ្ទាល់ ដោយរាប់ចាប់តាំងពីការសម្លាប់ «ពួកក្បត់ប្រាំពីរនាក់» និងមន្ត្រីលន់នល់ដែលមានឋានន្តរស័ក្តិដទៃទៀត នៅក្រោយជ័យជម្នះរបស់ខ្មែរក្រហមភ្លាមរហូតដល់ការបោសសម្អាតជាប្រចាំសូម្បីតែកម្មាភិបាលខ្ពស់បំផុតដែលធ្វើការនៅជិតមេដឹកនាំមជ្ឈិមបំផុត និងក្បាលម៉ាស៊ីនសម្លាប់ដ៏សាហាវនៅគុកស-២១របស់មជ្ឈិមផ្ទាល់។ ឧទាហរណ៍ ត្រូវបានរៀបចំឡើងអំពីភាពសាហាវដែលបានរំពឹងទុក ហើយកម្មាភិបាលមូលដ្ឋានណាមួយក៏ដោយ ដែលខកខានមិនបាន

បង្ហាញពីភាពស្រើបស្រាលឲ្យបានដូចគ្នាចំពោះយុទ្ធនាការសម្លាប់ ត្រូវបានប្រឈមនឹងការសង្ស័យថា មិនស្មោះត្រង់ និងត្រូវបានសម្លាប់ចោល។

ផ្ទុយទៅនឹងការប៉ុនប៉ងចុងក្រោយរបស់ នួន ជា និង ខៀវ សំផន ដើម្បីគេចចេញពីការស្តី បន្ទោសចំពោះការសម្លាប់ទាំងអស់ ទៅលើជនរងគ្រោះខ្លះរបស់ពួកគេផ្ទាល់ មិនមានភស្តុតាងណាមួយបញ្ជាក់ថា កម្មាភិបាលទាំងនោះ ដូចជាពួកមេដឹកនាំភូមិភាគប្រាំមួយរូប ត្រូវបានបោសសម្អាតដោយរបបនេះ (យ៉ា, កុយ ធួន, កង ចាប, ជូ ជេត, រស់ ញឹម, និង សោ ភឹម) ត្រូវបានផ្តោតគោលដៅទៅលើទេ ពីព្រោះតួនាទីរបស់ពួកគាត់នៅក្នុងការសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់។ ផ្ទុយទៅវិញ មេដឹកនាំជាន់ខ្ពស់ទាំងនេះត្រូវបានគេផ្តោតគោលដៅទៅលើ ពីព្រោះពួកគាត់ត្រូវបានមើលឃើញថា ជាការគំរាមកំហែងចំពោះអំពើផ្តាច់ការទាំងស្រុងរបស់ប៉ុល ពតនិងបរិវាររបស់ខ្លួនហើយពួកគេត្រូវបានជំនួសដោយកម្មាភិបាល ដែលកាន់តែឃោរឃៅជាងមុនទៅទៀត។ នួន ជា ខ្លួនគាត់ផ្ទាល់ បានផ្តល់មូលហេតុរបស់គាត់នៅក្នុងការសម្លាប់«មិត្ត»ទាំងនេះ មានអ្នកខ្លះគាត់បានអះអាងថា គាត់បាន«ស្រឡាញ់» ហើយមិនមានការពន្យល់ណាមួយរបស់គាត់បានពោលដល់ការលើកទឹកចិត្តឲ្យផ្តន្ទាទោស ពួកអ្នកដែលទទួលខុសត្រូវ ចំពោះការសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់ទេ។ ផ្ទុយទៅវិញ «មិត្ត»របស់ នួន ជា រួមទាំង យ៉ា លេខាភូមិភាគឦសាន (ណៃ សារ៉ាន់) មេដឹកនាំបក្សពីដើម កែវ មាស មេដឹកនាំភូមិភាគពាយ័ព្យ រស់ ញឹម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម កុយ ធួន ឧបនាយករដ្ឋមន្ត្រី វ៉ន វ៉េត មេដឹកនាំភូមិភាគបស្ចិមជូ ជេតនិងមេដឹកនាំភូមិភាគបូព៌ា សោភឹម ត្រូវបានចោទប្រកាន់រួមគំនិតក្បត់ជាមួយនឹងវៀតណាម ហើយបានធ្វើផែនការក្បត់ប្រឆាំងនឹងការគ្រប់គ្រងរបស់ ប៉ុល ពត និង នួន ជា។

ការិយាល័យសហព្រះរាជអាជ្ញា មិនដែលលើកឡើងចោទប្រកាន់ថា នួន ជា និង ខៀវ សំផន បានបញ្ជា ឬសូម្បីតែថា បានដឹងអំពីការសម្លាប់បុគ្គលនីមួយៗនោះឡើយ។ អ្វីដែលភស្តុតាងបានបង្ហាញនោះ គឺពួកគេបានដឹងឮថា ការសម្លាប់មនុស្សទ្រង់ទ្រាយធំ បានកំពុងកើតមាន និងបានបន្តញុះញង់កម្មាភិបាលឲ្យកម្ទេច«ខ្មាំង» ដែលនេះជាសញ្ញាយ៉ាងច្បាស់មួយបង្ហាញថា ចេតនារបស់ពួកគេនោះ គឺគាំទ្រយុទ្ធនាការស្វែងរក និងសម្លាប់ក្រុមមនុស្សទាំងមូលដោយមិនមាននីតិវិធីត្រឹមត្រូវ ដោយគ្រាន់តែផ្អែកលើការសង្ស័យថា ពួកគេអាចនឹងប្រឆាំងនឹងរបបនោះតែប៉ុណ្ណោះ។ ការប៉ុនប៉ងរបស់ នួន ជា ដើម្បីធ្វើយុត្តិកម្មលើការសម្លាប់នានា គ្រាន់តែបង្ហាញឲ្យឃើញភាពខុសច្បាប់នៃការសម្រេចនានា ក្នុងការសម្លាប់មនុស្សតែប៉ុណ្ណោះ។ នៅក្នុងបទសម្ភាសន៍មួយ គាត់បាននិយាយថា«យើងស្រាវតិចៗតិចៗទៅណាស់ បានយើងដឹងប្រវត្តិបាន យើងផាកមករកចាប់»។ គាត់បានអះអាងថា មិនបានដឹងពីការសម្លាប់«ប្រជាជនធម្មតា» បន្ទាប់មកក៏ទទួលដឹងឮភ្លាមៗពីចំនួនដ៏ច្រើនសម្បើម ដោយមិនបាននិយាយថា «ប៉ុល ពត ក៏មិនសូវដឹងអី ខ្ញុំក៏មិនដឹងអី អ្នកណាទៀតក៏មិនដឹងអីដែរ ក៏ប៉ុន្តែពួកនេះវាទៅច្រើនណាស់ដែលវាមកនេះខ្ញុំនិយាយទៅ...។ នៅពេលសួរថា «មានការសម្លាប់មនុស្សចាប់តាំងពីពេលណាមក?» ភាពព្រងើយកន្តើយរបស់គាត់ គឺឥតមានលាក់លៀមនោះទេ។ នួន ជា បានឆ្លើយថា «ពេលនោះ វាពិបាកនិយាយណាស់ ខ្ញុំវាភ្លេចបាត់ទៅហើយពីពេលវេលាការងារចេះតែធ្វើទៅ យើងវាមិនបានកត់មិនបានអី» បន្ទាប់មកគាត់សើច។

ខៀវ សំផន ធ្លាប់បានទទួលស្គាល់ថា នៅពាក់កណ្តាលឆ្នាំ១៩៧៨ «ខ្ញុំបានឮដោយចៃដន្យអំពីករណីមួយនៃការចាប់ចង និងអំពើឃោរឃៅនៅក្នុងខេត្តព្រះវិហារ។ ជាការឆ្លើយតប គាត់បានរៀបចំបញ្ជូនសាច់ថ្លៃផ្ទាល់របស់គាត់ចេញពីព្រះវិហារទៅកាន់សៀមរាប ប៉ុន្តែមិនបានធ្វើអ្វីសោះសម្រាប់ជនរងគ្រោះផ្សេងៗទៀត នៃការបោសសម្អាតនៅទីនោះ។

**ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្ដៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណៈជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណៈជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង មី បូរមី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthborey.m@dccam.org។





















# ដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស ការខេញសសៃអំបោះចាស់និងថ្មីបញ្ចូលគ្នា ៖ ការតភ្ជាប់ទីកន្លែង និងការចងចាំ

នៅល្ងាចថ្ងៃសុក្រទី៨ ខែមិថុនា ឆ្នាំ២០១៨ គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសលភូមិភាគ ខេត្តកំពង់ចាម និងសិស្សនៃវិទ្យាល័យអន្លង់វែងចំនួន២០រូប បានជួជុំគ្នា និងចូលរួមក្នុងដំណើរទស្សនកិច្ចស្តីពីសន្តិភាព និងសិទ្ធិមនុស្សនៅស្រុកអន្លង់វែង ដែលដឹកនាំដោយលោក លី សុខឃាង។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមួយចំនួន ព្រមទាំងឡែនី បារុន ដែលជាអ្នកសារព័ត៌មានរបស់ទស្សនាវដ្តីថាមក៏បានចូលរួមក្នុងដំណើរទស្សនកិច្ចនេះដែរ។

របាយការណ៍នេះ គ្របដណ្តប់ទៅលើព័ត៌មានលម្អិតអំពីសកម្មភាព និងបទបង្ហាញនីមួយៗនៅក្នុងដំណើរទស្សនកិច្ចទាំងមូល ដោយមានការសង្កត់ធ្ងន់ទៅលើភាពស្មុគស្មាញផ្លូវអារម្មណ៍ ពាក់ព័ន្ធនឹងស្រុកអន្លង់វែង ដែលនាំឲ្យមានការវិភាគទៅលើប្រវត្តិសាស្ត្ររបស់តំបន់នេះ។ គោលដៅនៃដំណើរទស្សនកិច្ចនេះ គឺជាការបង្ហាញពីសារសំខាន់នៃស្វែងយល់បន្ថែមអំពីការចងចាំរបស់បុគ្គលដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ដើម្បីទទួលបានរូបភាពពេញលេញនៃព្រឹត្តិការណ៍



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើបទបង្ហាញដល់និសិត្សចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស


និសិត្សចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស ថតនៅមុខការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើភ្នំដងរែក ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ប្រវត្តិសាស្ត្រ ហើយក៏ជាលទ្ធផលនៃការបំពេញបេសកកម្ម របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការលើកកម្ពស់ ការចងចាំ យុត្តិធម៌ និងការសះស្បើយ។

### ថ្ងៃទី៨ ខែមិថុនា

ក្រោយពីអ្នកចូលរួមទាំងអស់បានធ្វើដំណើរមកដល់ស្រុកអន្លង់វែងនៅថ្ងៃទី៨ ខែមិថុនា អ្នកទាំងអស់គ្នាបានដើរទៅទស្សនានៅវិទ្យាល័យអន្លង់វែង និងមន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង ដែលជាសំណង់សាងសង់ដោយ តាម៉ុក នៅដើមទសវត្សរ៍ទី៩០។ សាលា តាម៉ុក គឺជាអាគារដែលមានទំហំធំជាងគេក្នុងវិទ្យាល័យអន្លង់វែង រហូតមកដល់ឆ្នាំ២០១៧ នៅពេលដែលអគារ សិក្សាមួយទៀត ត្រូវបានសាងសង់ឡើងដោយរដ្ឋាភិបាល។ ចំណែកមន្ទីរពេទ្យ តាម៉ុក វិញ ត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យបង្អែកស្រុករហូតដល់សព្វថ្ងៃ។

អ្នកចូលរួមទាំងអស់ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកម្មវិធីសិក្សា ដែលសាលានេះប្រើប្រាស់នៅក្នុងអំឡុងពេលដែលខ្មែរក្រហម គ្រប់គ្រងស្រុក អន្លង់វែង។ មគ្គុទ្ទេសក៍ទេសចរណ៍ស្រុកអន្លង់វែងបាននិយាយថា សាលានេះបង្រៀនត្រឹមតែពីរមុខវិជ្ជាប៉ុណ្ណោះ គឺគណិតវិទ្យា និងភាសាខ្មែរ។

អគារទាំងពីរនេះ គឺជានិមិត្តសញ្ញាតំណាងឲ្យប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់អន្លង់វែង។ តាមរយៈមគ្គុទ្ទេសក៍ទេសចរណ៍ អ្នកចូលរួមបានដឹងថា ប្រជាពលរដ្ឋនៅស្រុកអន្លង់វែង ចាត់ទុក តាម៉ុក ថាជាមេដឹកនាំដ៏ល្អម្នាក់ ដោយសារ តាម៉ុក តែងតែចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាជនអន្លង់វែង។ ប្រជាជន ស្រុកអន្លង់វែងជាច្រើន មិនបានដឹងពីអំពើដ៏ឃោរឃៅរបស់ តាម៉ុក ដូចជាការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ។

បើទោះបីជាអគារទាំងពីរនេះមានភាពទ្រុឌទ្រោម ក៏វានៅតែមានភាពស្រស់ស្អាត ដោយសារតែរចនាបទរបស់អគារទាំងពីរនេះ មានភាពស្រដៀងគ្នាទៅនឹងអគារពីអំឡុងទសវត្សរ៍ទី៦០។ ទស្សនភាពនេះរួម ជាមួយនឹងវត្តមានរបស់

អ្នកចូលរួម ព្រមទាំងព័ត៌មាន ដែលទទួលបាន គឺជាការចាប់ផ្តើមនៃការវេញបញ្ចូលគ្នានូវបរិបទប្រវត្តិសាស្ត្រ និងទស្សនវិស័យរបស់យើង។

### ថ្ងៃទី៩ ខែមិថុនា

នៅថ្ងៃសៅរ៍ យើងបានចេញដំណើរទៅកាន់មជ្ឈមណ្ឌល



ក្រុមនិសិត្សចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស កំពុងសម្ភាសជាមួយប្រជាជននៅស្រុកអន្លង់វែង

សន្តិភាពអន្លង់វែង នៅលើកំពូលភ្នំដងរែក ដែលបង្កើតឡើងក្នុងគោលបំណងប្រែក្លាយ ទីតាំងប្រជុំយុទ្ធសាស្ត្ររបស់តាម៉ុក ជាកន្លែងសិក្សារបស់យុវជនជំនាន់ក្រោយ។ សកម្មភាពនៅព្រឹកនៃថ្ងៃនេះ គឺជាការធ្វើបទបង្ហាញរបស់លោក លី សុខ ឃាង។ បទបង្ហាញរបស់លោក លី សុខឃាង ចាប់ផ្តើមដោយការរំឭកពីសារសំខាន់នៃការថែរក្សា និងការមានវត្តមាននៅទីតាំងប្រវត្តិសាស្ត្រ ដោយលោកមានប្រសាសន៍ថា «នេះជាផ្ទះរបស់យើង ក្នុងទឹកដី និងក្នុងប្រទេសរបស់យើង អញ្ចឹងហើយវាជាកាតព្វកិច្ចរបស់យើងក្នុងការថែរក្សាវា»។ អ្នកចូលរួមទាំងអស់ក៏បានចូលអង្គុយនៅជុំវិញតុប្រជុំដោយយកចិត្តទុកដាក់។ បន្ទាប់មកលោក លី សុខឃាង បានធ្វើការបកស្រាយអំពីប្រវត្តិនៃការកកើតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាកម្មវត្ថុទាំងបីរបស់ដំណើរទស្សនកិច្ចនេះ៖ ដើម្បីសិក្សាអំពីប្រវត្តិសាស្ត្រតាមរយៈទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រ ជួបជាមួយ និងសម្ភាសន៍ប្រជាជនក្នុងតំបន់ ក៏ដូចជាប្រើប្រាស់ចំណេះដឹង ដែលទទួលបានទៅចែករំលែកព្រមទាំងលើកកម្ពស់ការយល់អំពីគម្រោងទាក់ទងនឹង

សន្តិភាព។

នៅពេលដែលសួរអំពីអ្វីដែលខ្លួនដឹង ពីរបបខ្មែរក្រហម អ្នកចូលរួមភាគច្រើនលើកឡើងថា ខ្លួនទទួលបានព័ត៌មានភាគច្រើន ទាក់ទងនឹងសម័យនោះតាមរយៈឪពុកម្តាយរបស់ខ្លួន។ លោក លី សុខឃាង បានធ្វើការពិនិត្យទៅលើព័ត៌មានសម្រាប់ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

ក្រោយពីបង្ហាញស្ថិតិស្តីពីខ្មែរក្រហម លោក លី សុខឃាង ក៏បានជំរុញឲ្យអ្នកចូលរួម ធ្វើការគិតតាមបែបស៊ីជម្រៅ។ លោក បានប្រើប្រាស់ការវាយលុករបស់វៀតណាម មកធ្វើជាឧទាហរណ៍ ហើយចោទសួរទៅកាន់អ្នកចូលរួមទាំងអស់ថា



ក្រុមនិសិត្សចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស កំពុងសម្ភាសជាមួយប្រជាជននៅស្រុកអន្លង់វែង

ដែលទទួលបានពីក្រុមអ្នកចូលរួម ហើយឃើញថាក្រុមនេះដឹងព័ត៌មានទាក់ទងនឹងខ្មែរក្រហម ច្រើនជាងក្រុមទស្សនកិច្ចដទៃដែលចូលរួមកាលពីឆ្នាំមុនៗ បន្ទាប់មកក្រុមអ្នកចូលរួមបានបន្តទៅស្តាប់បទបង្ហាញ អំពីប្រវត្តិសាស្ត្រខ្មែរ ក្រហមនិងប្រវត្តិសាស្ត្រស្រុកអន្លង់វែង ក៏ដូចជាធ្វើការវិភាគទៅលើផែនការ នាពេលអនាគតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស

«ប្រសិនបើប្រទេសវៀតណាមមិនបានចូលក្នុងប្រទេសកម្ពុជាទេ តើប្រទេសកម្ពុជានឹងក្លាយទៅជាយ៉ាងណា? ហើយនរណានឹងជួយកម្ពុជា?» សំណួរនេះ ជាសំណួរដ៏ពិបាកឆ្លើយមួយសម្រាប់សិស្សានុសិស្សខ្មែរ ដោយសារតែការខ្វះការយល់ដឹង និងរើសអើងចំពោះប្រទេសវៀតណាមរបស់ប្រជាជនកម្ពុជា។ វាមានតួនាទីយ៉ាងសំខាន់ក្នុងការប្រែក្លាយភាពគុំគួន

ទៅជាសន្តិភាព និងភាពផ្សះផ្សា។ តាមរយៈការចោទសួរអំពីប្រវត្តិសាស្ត្រ ដែលបង្ហាញតែពីរឿងរ៉ាវរបស់ភាគីតែម្ខាង ហើយងាកទៅពិចារណាពីបទពិសោធន៍របស់អ្នករស់រានមានជីវិតក៏ដូចជាបទពិសោធន៍របស់ចារី (បុគ្គលដែលប្រព្រឹត្តបទល្មើស) យើងអាចឃើញបានថាតួនាទីរបស់អ្នកទាំងពីរក្រុមអាចផ្លាស់ប្តូរបានយ៉ាងងាយ។

នៅពេលរសៀល អ្នកចូលរួមទាំងអស់មានឱកាសក្នុងការស្តាប់ពីបទពិសោធន៍ផ្ទាល់របស់លោកពូ ហូវ គេង លោកពូ មន ម៉ៅ និងលោកពូ សុខឃី។ លោកពូ គេង និងលោកពូ ម៉ៅ គឺជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយលោកពូ សុខឃី គឺជាអតីតយោធាខ្មែរក្រហមនៅក្នុងសម័យដែល តាម៉ុក គ្រប់គ្រង។

លោកពូ គេង បាត់បង់សមាជិកគ្រួសារចំនួន២៣នាក់នៅក្នុងរបបខ្មែរក្រហម។ លោកពូបានបកស្រាយពីបន្ទុកការងារដ៏ធ្ងន់ធ្ងរ។ អ្នកចូលរួមបានសួរពីពេលវេលានៃការធ្វើការម្តងហើយម្តងទៀត ហាក់បីដូចជាមិនអាចទទួលយកបានថា ប្រជាជនខ្មែរនៅសម័យនោះ ត្រូវបានបង្ខំឲ្យធ្វើការដោយគ្មានពេលឈប់សម្រាក។ អ្នកចូលរួមក៏បានសួរលោកពូ គេង ថា តើលោកពូធ្លាប់មានគំនិតចង់រត់ ឬក៏ធ្លាប់លួចអាហារដែរឬទេ។ លោកពូឆ្លើយថា ខ្លួនធ្លាប់គិតចង់រត់ ប៉ុន្តែមិនដឹងថារត់គេចទៅទីណា ហើយដោយរបៀបណា ព្រោះថាខ្មែរក្រហមតែតែងធ្វើការឃ្លាំមើលប្រជាជន។ មានតែពីរនាក់ក្នុងចំណោមបងប្អូនទាំងប្រាំបីនាក់របស់គាត់តែប៉ុណ្ណោះ ដែលរស់រានមានជីវិតហើយលោកពូមិនបានដឹងពីព័ត៌មាននេះទេ រហូតដល់ច្រើនឆ្នាំក្រោយរបបខ្មែរក្រហម។

លោកពូ សុខឃី បាននិយាយពីបទពិសោធន៍របស់ខ្លួនក្នុងនាមជាយោធាខ្មែរក្រហម។ នៅអាយុ១៦ឆ្នាំ លោកពូបានព្យាយាមភៀសខ្លួនទៅប្រទេសថៃ។ ដោយព្យាយាមមិនបានសម្រេចលោកពូក៏បង្ខំចិត្តចូលរួមជាមួយយោធាខ្មែរក្រហម។ នៅពេលដែលអ្នកចូលរួមសួរពីមូលហេតុ ដែលលោកពូចូលជាទាហានខ្មែរក្រហម លោកពូ សុខឃី បាននិយាយថា«យើងមិនមានជម្រើស»។ អ្នកចូលរួមមានការចាប់អារម្មណ៍អំពីការយល់ឃើញរបស់លោកពូចំពោះ តាម៉ុក យ៉ាងខ្លាំង ក្រោយពេលដែលលោកពូនិយាយថា ខ្លួនធ្លាប់ជួប តាម៉ុក ផ្ទាល់។ លោកពូបាននិយាយថា តាម៉ុក តែងតែប្រកាន់ពាក្យសម្តីរបស់ខ្លួន ហើយមិនដែលប្រើមនោគមវិជ្ជាលើនរណាម្នាក់ឡើយ ប៉ុន្តែ តាម៉ុក ជាមនុស្សឆេវឆាវម្នាក់។ លោកពូក៏បាននិយាយថា ប្រជាជនអន្លង់វែងគ្រប់រូបស្រឡាញ់ និងគាំទ្រ តាម៉ុក។

សកម្មភាពចុងក្រោយនៅក្នុងថ្ងៃនេះ គឺជាការសិក្សាអំពីវិធីសាស្ត្រនៃការសម្ភាសន៍ និងការរៀនប្រើ ប្រាស់ម៉ាស៊ីនថតដើម្បីបំពាក់ដល់អ្នកចូលរួមសម្រាប់កម្មវិធីនៅថ្ងៃស្អែក នៅក្នុងភូមិមួយក្នុងស្រុកអន្លង់វែង។ ក្នុងអំឡុងពេលណែនាំ មានការសង្កត់ធ្ងន់ទៅ លើចាប់ផ្តើមបទសម្ភាសន៍ ដោយភាពប្រុងប្រយ័ត្នព្រោះអ្នកសម្ភាសន៍នីមួយៗត្រូវយល់ថា ការសុំឲ្យបុគ្គលម្នាក់ ចែករំលែកពីបទពិសោធន៍ដ៏ជូរចត់បែបនេះ មិនមានភាពងាយស្រួលឡើយ។ អ្នកសម្ភាសន៍ត្រូវយកចិត្តទុកដាក់ទៅលើអកប្បកិរិយា អារម្មណ៍ និងរឿងរ៉ាវរបស់អ្នកផ្តល់បទសម្ភាសន៍ ដើម្បីប្រមូលព័ត៌មានពិតឲ្យច្រើនតាមដែលអាចធ្វើបាន។

### ថ្ងៃទី១០ ខែមិថុនា

ថ្ងៃអាទិត្យទី១០ គឺជាថ្ងៃដែលអ្នកចូលរួមទាំងអស់ ត្រូវចុះទៅសម្ភាសន៍និងថតវីដេអូដើម្បីធ្វើជាភាពយន្តឯកសារ។ ក្រោយពីធ្វើដំណើរមកដល់ភូមិរំចេក អ្នកចូលរួមទាំងអស់បានបែងចែកគ្នាទៅតាម ក្រុមដូចដែលបានគ្រោងទុក (ក្រុមថតភាពយន្ត៣ក្រុម និងក្រុមសម្ភាសន៍៣ក្រុម) ហើយចេញដំណើរទៅសម្ភាសន៍ប្រជាជនមូលដ្ឋាន។ ខ្ញុំបានចូលរួមជាមួយអ្នកទាំងអស់គ្នា ក្នុងការសម្ភាសន៍ចំនួន ៤សម្ភាសន៍។ បទសម្ភាសន៍ទាំងអស់មានភាពខុសប្លែកពីគ្នាយ៉ាងខ្លាំង។ អ្នកផ្តល់សម្ភាសន៍ខ្លះមានភាពភ័យខ្លាច និងស្ទាក់ស្ទើរក្នុងការចែករំលែក ហើយអ្នកខ្លះទៀតក៏សហការចូលរួមចែករំលែកដោយមិនភ័យខ្លាច។ បទសម្ភាសន៍ទាំងអស់មានភាពស្រដៀងគ្នា

ត្រង់ថា អ្នកផ្តល់សម្ភាសន៍ទាំងអស់បានចែករំលែកអំពីវិធីដែលគាត់ព្យាយាមបំភ្លេចរបបខ្មែរក្រហម។

ក្នុងចំណោមបទសម្ភាសន៍ទាំង៤ បទសម្ភាសន៍ដែលមានភាពក្បោះក្បាយជាងគេ គឺបទសម្ភាសន៍ចុងក្រោយ។ អ្នកចូលរួមបានសម្ភាសន៍ស្ត្រី ដែលជាម្តាយរបស់បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងម្នាក់។ អ៊ំស្រីបានបកស្រាយអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមទាំងស្រក់ទឹកភ្នែក។ នៅពេលនោះអ៊ំស្រីនៅជាកុមារនៅឡើយ ហើយរស់នៅជាមួយឪពុក និងបងប្អូនដទៃ។ ខ្មែរក្រហមបានយកឪពុកអ៊ំស្រីទៅអប់រំ ដោយសារគាត់មិនយល់ស្របតាមការចាត់ឲ្យរៀបការរបស់អង្គការ។

ការសម្ភាសន៍ បានផ្តល់ជាវេទិកាសម្រាប់អ្នកចូលរួមធ្វើការសាកសួរក្នុងគោលបំណងរក្សា និងកត់ត្រាសាច់រឿងរបស់បុគ្គល។ ដោយសារតែរបបខ្មែរក្រហមទើបតែកន្លងផុតថ្មីៗ ទើបប្រជាជនជាច្រើននៅក្នុងប្រទេសមានសាច់រឿងផ្ទាល់ខ្លួនដែលទាក់ទងនឹងរបបនេះ។ អ្នកចូលរួមនឹងអាចប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ដែលខ្លួនទទួលបានក្នុងដំណើរទស្សនកិច្ចសិក្សានេះ ដើម្បីបន្តថែរក្សា និងកត់ត្រាសាច់រឿងបុគ្គលនាពេលអនាគតទៀត។

សរុបសេចក្តី ដំណើរទស្សនកិច្ចសិក្សានៅស្រុកអន្លង់វែង គឺជាបទពិសោធន៍ដ៏មានតម្លៃសម្រាប់អ្នកដែលពាក់ព័ន្ធទាំងអស់។ ដំណើរទស្សនកិច្ចនេះ អនុញ្ញាតឲ្យអ្នកចូលរួមផ្សាភ្ជាប់ចំណេះដឹងដែលខ្លួនមាន និងទទួលបានអំពីអន្លង់វែង និងខ្មែរក្រហមជាមួយនឹងការអនុវត្ត ព្រមទាំងទីតាំងប្រវត្តិសាស្ត្រ។ អ្នកចូលរួមទាំងអស់យល់ស្របថា ការមកទស្សនា និងជួបពិភាក្សាផ្ទាល់ជាមួយនឹងប្រជាជនស្រុកអន្លង់វែង បានធ្វើឲ្យខ្លួនយល់កាន់តែច្បាស់អំពីរបបខ្មែរ ក្រហម។ ព័ត៌មាន និងវិធីសាស្ត្រដែលប្រើប្រាស់ក្នុងដំណើរទស្សនកិច្ច ពិតជាមានតម្លៃសម្រាប់គម្រោងអនាគតអ្នកអប់រំ។

**អៀង អេមីលីន**



និសិត្សចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស ទស្សនាវិទ្យាល័យអន្លង់វែង

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្ដុះបណ្ដាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ១មួយច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume) ។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org ។ ប្រសិនបើមានចម្ងល់ សូមទូរស័ព្ទមកលេខ៖ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុង សៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*កេ វ៉ៃ ហៅ កែវ វ៉ែន មានអាយុ ២៨ឆ្នាំ គិតត្រឹមឆ្នាំ ១៩៧៥ មានស្រុកកំណើតនៅអង្គរជ័យ ខេត្តកំពត (ក្នុងរបប ខ្មែរក្រហម ស្រុកអង្គរជ័យស្ថិតក្នុងខេត្តតាកែវ) ជាកូនរបស់ពូ គេ លាង និងមីង ផាយ ទី ជាយុទ្ធជនក្នុងកងពលនិរតី ត្រូវបាន ខ្មែរក្រហមចាប់ឃាត់ខ្លួននៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៥ នៅ ស្ទឹងមានជ័យក្នុងអង្គភាព ហើយបញ្ជូនទៅដាក់គុកនៅគុក ទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ២ បន្ទប់តូច ១។ ខ្មែរក្រហមសម្លាប់ កេ វ៉ៃ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំង នៅគុកទួលស្លែងអស់រយៈពេល ៤០៨ថ្ងៃ។*

*កេង នឿន ជាយុទ្ធជនក្នុងកងពល ២៩០ ត្រូវបាន ខ្មែរក្រហមចាបឃាត់ខ្លួននៅកងពល និងបញ្ជូនមកដល់គុក ទួលស្លែងនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៦។ បន្ទាប់ពីជាប់ ឃុំឃាំងនៅគុកទួលស្លែង អស់រយៈពេល ៤០ថ្ងៃ ខ្មែរក្រហម សម្លាប់ នឿន នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦។*

*កេត ចាគន្ធ ហៅ យិន កន មានអាយុ ២៥ឆ្នាំ គិតត្រឹម ឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសំរោងទង ខេត្តកំពង់ស្ពឺ ជា កូនរបស់ពូ យិន កេត និងមីង អ៊ុំ សាត ត្រូវបានខ្មែរក្រហម ចាប់ខ្លួនរោងចក្រតម្បាញ ត៤ ថ្ងៃទី២៨ខែវិច្ឆិកា ឆ្នាំ១៩៧៥។ យោងតាមឯកសារនៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា បានរកឃើញកាលបរិច្ឆេទនៃការបញ្ជូនមក ដល់គុកទួលស្លែងខុសៗគ្នា ដល់ទៅ៣ គឺថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឬថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦។ កេត ចាគន្ធ ជាប់ឃុំឃាំងនៅគុកទួល ស្លែងក្នុងផ្ទះ ក១ បន្ទប់ធំ៩ ហើយត្រូវបានខ្មែរក្រហមសម្លាប់ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦។*

*កេត ចៅ ហៅ សែន មានអាយុ ៣៤ឆ្នាំ គិតត្រឹម ឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសំបូរមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ស្បូវ កេត និងមីង ខោល យាន ទទួលខុសត្រូវ កងការពារអគ្គការ (មន្ទីរ ក១) មានប្រពន្ធឈ្មោះ អ៊ឹម អ៊ិន ហៅ សឿន មាន កូនប្រុស១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរ ក្រហម ចាប់ខ្លួននៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅមន្ទីរក១។ ឯកសារនៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា D06458 ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ សរសេរថា «ឈ្មោះដក ៧៦ នាក់គឺកំទេច ៧៥ និងឈឺងាប់ម្នាក់.. កេត ចៅ ហ សែម នាទីប្រធានមន្ទីរ ក១ កងការពារអគ្គកា សភាពជម្ងឺ មុនដំបូង ចុកទ្រូង ហើយហត់សោប់រសល់នៅមិនស្មៀម ពិបាកដកដង្ហើម ប្រហែលជាម៉ោង៣ជិតភ្លឺមានសភាពយ៉ាប់ ខ្លាំង។ ព្យាបាលមិនបានយូរទេ បានតែរយៈជាង ១ ម៉ោង វា ងាប់ទៅ»។*

*កេត ប៉ាន់ មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មាន ស្រុកកំណើតនៅស្រុក ១៨ តំបន់២៥ (ស្រុក កោះធំ ខេត្តកណ្ដាល) ជាកូនរបស់ពូ កេត ប៉ិល និងមីង ស សំរ៉ែង មាននាទីជាយុទ្ធជន កង១៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ស២១យ ថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ១៩៧៧។*

*កេត ស៊ឹម ហៅ វ៉េត ត្រូវបានខ្មែរក្រហមចាប់ឃាត់ ខ្លួនក្នុងឆ្នាំ១៩៧៦។ ពុំមានឯកសារបង្ហាញពីកាលបរិច្ឆេទនៃ ការមកដល់គុកទួលស្លែង និងការសម្លាប់ទេ។*

*កែ គេងស៊ី ហៅ ដន មានអាយុ ២២ឆ្នាំ គិតត្រឹម ឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសណ្ដាន់ ខេត្តកំពង់ធំ ជាកូន របស់ពូ កែ ស៊ីវ និងមីង យង់ តាន់ ជាយុទ្ធជនពេទ្យកងពល ៣១០ និងពេទ្យ ៩៨ ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅ*

ភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំ ឃាំង នៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៤ តូច ៣។ ខ្មែរក្រហម សម្លាប់ គេងស៊ី នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពី ជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល ៩៧ថ្ងៃ។

កែ ណាន ហៅ ខៀម មានអាយុ ៣១ឆ្នាំ គិតត្រឹម ឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុកកំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ជាកូនរបស់ពូ កែ ខាន់ និងមីង សោម យុត ជាយុទ្ធជនក្នុងកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ កប់ស្រូវ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦។ យោងតាមឯកសារ នៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ការិយាល័យសហ ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា បានរកឃើញកាលបរិច្ឆេទ នៃការបញ្ជូនមកដល់គុកទួល-ស្លែងខុសៗគ្នាដល់ ទៅ៤ គឺថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឬ ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ ឬថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៦ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៦។ កែ ណាន ជាប់ឃុំឃាំងនៅ គុកទួលស្លែងក្នុងបន្ទប់ធំ៦ បន្ទប់តូច ១ ហើយត្រូវបានខ្មែរ-ក្រហមសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

កែ មាស មានអាយុ៦១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ អតីត នាយកក្រសួងផ្ទៃវាំង មានស្រុកកំណើតនៅអង្គរជ័យខេត្តកំពត (ក្នុងរបបខ្មែរក្រហមស្រុកអង្គរ ជ័យស្ថិតក្នុងខេត្តតាកែវ) ជា កូនរបស់អ៊ំ កែ ម៉ក និង អ៊ំស្រី ង៉ែត មាននាទីនាយខុទ្ទកាល័យ របស់សម្តេចព្រះ នរោត្តម សីហនុ មានប្រពន្ធឈ្មោះ វ៉ា កំប៉ុង ហៅ វ៉ា មានកូនប្រុស២នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅភ្នំពេញ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ និងបញ្ជូន ចូលដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់។ កែ មាស ជាប់ឃុំឃាំង នៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ៤ តូច ៨ ហើយស្លាប់ ដោយសារជម្ងឺ។ ឯកសារនៅបណ្ណសារមជ្ឈមណ្ឌលឯកសារ កម្ពុជា D06365 ចុះថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៧ សរសេរថា «កែ មាស មកពី ប៉េកាំង ងាប់ដោយជម្ងឺក្រុំ»។

កែ សារិន មានអាយុ២៧ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មាន ស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ កែ បៃ និងមីង បា ប៊ិន មានប្រពន្ធឈ្មោះ ម៉ារី វ៉ាំងសង់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅមន្ទីរអប់រំ ខេត្តបាត់ដំបង ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦។

កែសុក ហៅ អឿន មានអាយុ២៣ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកអំបិល ស្រុក២០ (ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់ពូ ញ៉ែម កែ និងមីង អ៊ុន តែម ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅ កសិកម្មខត្តឹម (ទឹកថ្លា) ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ និងបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះ ច បន្ទប់ធំ ៥ តូច ៩។ ខ្មែរក្រហមសម្លាប់ កែ សុក នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់ រយៈពេល ៥៧ថ្ងៃ។

កែ ហុកបៀន មានអាយុ៣៣ឆ្នាំ គិតត្រឹមឆ្នាំ ១៩៧៥ មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់ពូ កែឈាងនិងមីងជាវប៊ិចជាជាងម៉ាស៊ីននៅរោងចក្រអគ្គីសនី មានប្រពន្ធ ឈ្មោះ អ៊ឹង សោនណារី ត្រូវបានខ្មែរក្រហមចាប់ ខ្លួននៅរោងចក្រអគ្គីសនី ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៥។ យោង តាមឯកសារនៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ការិ-យាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុង តុលាការកម្ពុជា បានរកឃើញកាលបរិច្ឆេទនៃការបញ្ជូនមក ដល់គុកទួលស្លែងខុសៗគ្នា ដល់ទៅ២ គឺថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦។ កែ ហុកបៀន ជាប់ឃុំឃាំងនៅគុកទួល ស្លែងក្នុងផ្ទះក បន្ទប់ធំ៧ បន្ទប់តូច ៣។ ពុំមានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់ទេ។

កែ ហុន មានអាយុ២០ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុក កំណើតនៅកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកូនរបស់ពូ កែ ហុង និងមីង កូ ដាន ជាប្រធានក្រុមធ្វើស្រែយោធាក្នុងមន្ទីរ កងពល១៤ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៤ ក្រុង ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦ ហើយជាប់ឃុំឃាំងនៅ គុកទួលស្លែង ក្នុងផ្ទះ ឆ បន្ទប់ធំ ៥ បន្ទប់តូច ២។ ខ្មែរក្រហម សម្លាប់ កែ ហុន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

កែ អ៊ិន ហៅ នឿន មានអាយុ២៦ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្ត កំពង់ធំ ជាកូនរបស់ពូ

កែ ម៉ែរ និងមីង គុំ អ៊ឹម ជា យុទ្ធនារីកងពល៣១០ មានប្តីឈ្មោះ អាន សេងហ៊ាង ហៅ អាន ដុន នៅកងពល៣១០ដូចគ្នា មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៣១០ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់ ក្នុងផ្ទះល បន្ទប់ធំ៣ បន្ទប់តូច៨។ ខ្មែរ-ក្រហមបានចាប់ប្តីរបស់មីង កែ អ៊ិន មុន គឺនៅ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៦។ កែ អ៊ិន ត្រូវបានខ្មែរក្រហមសម្លាប់មុនប្តី ៥៧ថ្ងៃ គឺនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។ ប្តីរបស់ កែ អ៊ិន ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧។

កែ អួន មានអាយុ៥៥ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាគុនរបស់អ៊ំ កែ អ៊ុន និងអ៊ំស្រី កែវ ស៊ិន ជាអ្នក លក់បន្លែ មានប្រពន្ធឈ្មោះ ឡាយ គុណ មានកូនប្រុស១នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ ខ្លួននៅបាត់ដំបង ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ កែ អួន ជាប់ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះងបន្ទប់ធំ ២បន្ទប់តូច ៨ ហើយត្រូវ បានសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧។

កែន ង៉ុ មាននាទីជាស្នងការវរៈសេនាតូចក្នុងកងពល ១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ក្នុងឆ្នាំ១៩៧៦ ហើយបញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ១៩៧៦។ បន្ទាប់ពី ជាប់ឃុំឃាំង នៅក្នុងគុកទួលស្លែងបាន ៩៦ថ្ងៃ កែន ង៉ុ ត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ១៩៧៦។

កែន ឈុំ ជាប្រធានកងវរយនៃកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅកងពល១៧០ ក្នុង ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦។ ជាប់ឃុំ ឃាំងនៅ គុកទួលស្លែងរយៈពេល ៣៥ ថ្ងៃ ទើបខ្មែរក្រហម សម្លាប់ កែន ឈុំ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦។

កែប កេតពិសោ ហៅ ញ៉ែប ណុច ជាចោរព្រៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេជនិលក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៧។

កែប ថា ហៅ ម៉ុល ជាយុទ្ធជនកាន់គេអូក្នុងកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ក្នុងឆ្នាំ១៩៧៦ ក្នុងកំឡុងខែសីហា ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី២ ខែកញ្ញា។ ខ្មែរក្រហមសម្លាប់ កែប ថា នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

កែប សារឿន មានអាយុ៣១ឆ្នាំ គិតត្រឹម ឆ្នាំ១៩៧៦ មានស្រុកកំណើតនៅគងពិសី ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូព្រាប តុប និងមីង អ៊ុយ សួង ជាកម្មកររោងចក្រអគ្គីសនីទី២ មានប្រពន្ធឈ្មោះ ឈីវ គឹមសុប (អ្នកស្រុកតាកែវ) មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ទឹងមានជ័យ ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះលេខ១០ បន្ទប់ធំ៣។ ខ្មែរក្រហមសម្លាប់ កែប សារឿន នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីឃុំឃាំង កែប សារឿន នៅក្នុងគុកទួលស្លែងអស់រយៈពេល៦៣ថ្ងៃ។

កែម កើន ហៅ សែន អាយុ៣៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្ត កំពង់ចាម ជាកូនរបស់ពូអុក កែម និងមីង ស ខាន់ ជាអនុប្រធានស្រុកព្រៃឈរ មានប្រពន្ធឈ្មោះ ស៊ុយ សារ៉ាន ហៅ ស៊ុមមានកូនប្រុស៥នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិ ភាគឧត្តរ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៧។

កែម ថាច មានអាយុ៣៥ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ អតីតគ្រូបង្រៀនមានស្រុកកំណើតនៅឈូក ខេត្តកំពត ជាកូនរបស់ពូ កែម ឌឹម និងមីង ចេង លីន មានប្តីឈ្មោះ ហោ ស៊ុនរ៉ុង (អ្នកបាត់ដំបង) មានកូនប្រុស២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៦។

កែវ កាន ហៅ ចិត្ត មាននាទីជាកងវរយនៃ កងពល១៧០ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកងពល ១៧០ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកញ្ញា។ ខ្មែរក្រហមសម្លាប់ កែវ កាន នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីឃុំឃាំងនៅក្នុងគុកទួលស្លែងអស់រយៈពេល១៨ថ្ងៃ។

កែវខុនជាមេក្រុមក្នុងកងពល១៦៨ ត្រូវបានខ្មែរក្រហម

ចាប់ឃាត់ខ្លួននៅកងពលលេខ១៦៤ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨។ ខ្មែរក្រហម សម្លាប់ កែវ ខុន នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៨បន្ទាប់ពីឃុំឃាំងនៅក្នុងគុកទួលស្លែងអស់រយៈពេល៣៨ថ្ងៃ។

កែវ គីម ជាគ្រូបង្រៀននៅបុរីកីឡា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកបារាំងក្នុងឆ្នាំ១៩៧៦។ ពុំមានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់ទេ។

កែវ យុន ហៅ អឿន ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅកងពល១៧០ក្នុងឆ្នាំ១៩៧៦ ហើយបានបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកញ្ញា។ ជាប់ឃុំឃាំងនៅគុកទួលស្លែងរហូតដល់ ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ ទើបខ្មែរក្រហមសម្លាប់ កែ យុន។ កែវ យុន ជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល១៨ថ្ងៃ។

កែង ឆឹម មានអាយុ២៥ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់ពូ កែវ ឈន និងមីង ម៉ុក យ៉ិន ជាពេទ្យកងពល១៥២ ត្រូវបានខ្មែរក្រហមចាប់ឃាត់ ខ្លួននៅកងពល១៥២ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះ ល បន្ទប់ធំ៣ បន្ទប់តូច ១៦។ ពុំមានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់ទេ។

កែវ ឆុំ ហៅ ដាន អាយុ២៣ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១០ តំបន់៣១ (សុក្របរិបូរណ៍ ខេត្តកំពង់ឆ្នាំង) ជាកូនរបស់ពូ កែវគិន និងមីង ម៉ៅ នាង ជាយុទ្ធជនក្នុងកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ជាប់ឃុំឃាំង នៅគុកទួលស្លែងបាន ២៨ថ្ងៃ កែវ ឆុំ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

កែវ ចុន ឬ ជុន មានអាយុ៣១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្បូងឃ្មុំ ខេត្តកំពង់ចាម(ឥឡូវខេត្តត្បូងឃ្មុំ) ជាកូនរបស់ពូ កែវ ញ៉ារិ និងមីង នាង សានណាន មានប្រពន្ធឈ្មោះ អាច ស៊ីផា (អ្នក ភ្នំពេញ) មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួនស្រុកភ្នំស្រុក ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ ហើយជាប់ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក១ បន្ទប់ធំ២។ ទំនងជាខ្មែរ ក្រហមបញ្ជូន កែវ ចុន ទៅនៅមន្ទីរស២១គ មុននឹងសម្លាប់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

កែវ បុល ជាអនុប្រធានក្រុមក្នុងកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅកងពល ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦។

កែវ ផាត់ មានអាយុ៥១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុកស្វាយរៀង ខេត្តស្វាយរៀង ជាកូនរបស់អ៊ុំ កែវ សោម និងអ៊ុំស្រី លាវ នាង ជាអ្នកបច្ចេកទេសខាងភូមិសាស្ត្រក្នុងកងពល៣១០មានប្រពន្ធឈ្មោះ ជា ឡាំងហ៊ាង នៅកងពល៣១០ ដូចគ្នា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ទាំងប្តីទាំងប្រពន្ធ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ៤០ថ្ងៃក្រោយមក ខ្មែរក្រហមសម្លាប់ ប្រពន្ធ កែវ ផាត់ រួចហើយសម្លាប់ កែវ ផាត់ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈ៩៦ថ្ងៃ។

**វ៉ាន់ថាន់ ពៅដារ៉ា, មជ្ឈមណ្ឌលឯកសារកម្ពុជា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួននឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខ: (៨៥៥) (១២) ៩៩៦៧៥០

ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home Page: www.d.dccam.org

# ប៊ុន អារុណ ៖ ក្រឡាបញ្ជីសាលាដំបូង

កូនស្រីរបស់ ប៊ុន អារុណ ឈ្មោះ អារុណ ដាតិប៊ុណ្ណារី បាននិយាយរៀបរាប់ប្រាប់ថា៖

ឪពុកខ្ញុំបានជាប់ចិត្តស្រឡាញ់ម្តាយខ្ញុំ នៅពេលបានជួបគ្នានៅលើកដំបូង។ ម្តាយខ្ញុំជាស្ត្រីស្រស់ស្អាតនិងជាអ្នកសម្តែងល្ខោនបាសាក់។ ឪពុករបស់ខ្ញុំជាកូនរបស់ឧកញ៉ាម្នាក់។ ទោះបីជាយ៉ាងណា ជីដូនរបស់ខ្ញុំមិនចូលចិត្តម្តាយខ្ញុំទេ គាត់បានព្យាយាមរកមធ្យោបាយបំបែកឪពុកម្តាយខ្ញុំជានិច្ច។ ថៅកែប្រុសរោងល្ខោនដែលម្តាយខ្ញុំធ្វើការឲ្យនោះ បានរៀបចំអាពាហ៍ពិពាហ៍ឲ្យគាត់ទាំងពីរនាក់តាមប្រពៃណី ដោយមិនមានសមាជិកក្រុមគ្រួសាររបស់ឪពុកខ្ញុំមកចូលរួមទេ។ បន្ទាប់ពីឪពុកម្តាយខ្ញុំរៀបការរួចមកម្តាយខ្ញុំបានមានផ្ទៃពោះ។ ទោះបីជាគាត់ពរពោះក៏ដោយ ជីដូនរបស់ខ្ញុំនៅតែព្យាយាមបំបែកពួកគាត់ទៀត និងបញ្ចុះបញ្ចូលឪពុកខ្ញុំឲ្យរៀបការជាមួយស្រីផ្សេងៗ ជីដូនរបស់ខ្ញុំ បានមកអើតមើលចៅតែម្តងគត់ បន្ទាប់ពីចៅរបស់គាត់បានចាប់កំណើតមក។



ប៊ុន អារុណ អាយុ២០ឆ្នាំ

បន្ទាប់មក ជីដូនខ្ញុំបានយកគ្រួសារខ្ញុំទៅរស់នៅក្នុងព្រះបរមរាជវាំង។ យើងបានរស់នៅយ៉ាងសមរម្យ។ ម្តាយខ្ញុំបានក្លាយជាអ្នកសម្អាងសម្រាប់អ្នករាំរបាំព្រះរាជទ្រព្យ ហើយឪពុកខ្ញុំបានក្លាយជាវេជ្ជបណ្ឌិត។ ប្រហែលបួនឆ្នាំក្រោយមកឪពុកធំរបស់ខ្ញុំបានតែងតាំងឪពុកខ្ញុំជាក្រឡាបញ្ជីសាលាដំបូង។

នៅឆ្នាំ១៩៦៦ ឪពុកខ្ញុំបានផ្លាស់ទៅធ្វើការនៅខេត្តកំពត យើងទាំងអស់គ្នាក៏ទៅតាមគាត់។ នៅទីនោះ គាត់និងឪពុកធំរបស់ខ្ញុំមានដីចំការច្រើនហិកតាមានដើមសាវម៉ាវ ដូង ធុរេនជាច្រើនដើម។ ឪពុកខ្ញុំ និងឪពុកធំខ្ញុំបានវិនិយោគដីធ្លី និងលក់ផ្លែឈើដែលប្រមូលផលបានពីចម្ការ។

នៅថ្ងៃ១៧ មេសា ១៩៧៥ ឪពុកខ្ញុំ និងក្មេងៗប្រុសស្រីបានចុះទូកមួយដែលនឹងចាក ចេញទៅប្រទេសថៃ។ ប៉ុន្តែរៀបនឹងចេញដំណើរ ឪពុកខ្ញុំបានប្តូរចិត្តត្រឡប់ក្រោយទៅរកបង ស្រីៗរបស់ខ្ញុំនិងខ្ញុំ។ បន្ទាប់មកគ្រួសារយើងត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅកាន់ទីជនបទ។

នៅយប់មួយក្នុងឆ្នាំ១៩៧៦ មានឈ្លបខ្មែរក្រហមម្នាក់បានមកផ្ទះយើង ហើយបានប្រាប់ ឪពុកខ្ញុំថា «លោកក្រឡាបញ្ជីសាលាដំបូង រៀបចំឥវ៉ាន់របស់អ្នកឯងឲ្យរួចរាល់ នឹងចេញទៅនៅភូមិថ្មី» ឈ្លបខ្មែរក្រហម បានចងដៃឪពុកខ្ញុំព័ទ្ធទៅខាងក្រោយខ្នង និងរុំមុខគាត់នឹងបន្ទះក្រណាត់ពណ៌ខ្មៅ រួចបណ្តើរចូលទៅក្នុងរថយន្តធំមួយ ដែលពេញទៅដោយមនុស្សប្រុសជាច្រើននាក់។ ម្តាយរបស់ខ្ញុំគិតថា ឪពុកខ្ញុំប្រាកដជាស្លាប់ហើយ ពីព្រោះម្តាយខ្ញុំមិនដែលឃើញប្រជាជនដែលត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅភូមិថ្មីហើយត្រឡប់មកវិញនោះទេ។ ប្រជាជនមូលដ្ឋានបានខ្សឹបប្រាប់ម្តាយខ្ញុំថាមិនចាំបាច់រង់ចាំឪពុកខ្ញុំទេ។ ក្រោយមកអ្នកមូលដ្ឋានខ្លះ បាន

និយាយប្រាប់ថាខ្មែរក្រហមបានសម្លាប់គាត់និងបោះចូលទៅក្នុងជ្រលងជ្រោះ។

មួយខែក្រោយមក បន្ទាប់ពីការស្លាប់របស់ឪពុកខ្ញុំ ប្អូនស្រីខ្ញុំ រ៉ាដា បានមកលេងម្តាយខ្ញុំ នាងបានឃើញផ្ទះទទេស្អាតនិងស្ងាត់ជ្រងំ។ បង្គោលជាច្រើនដែលម្តាយខ្ញុំបានប្រើធ្វើជាទ្រើងឃ្លោកដែលឪពុកខ្ញុំបានដាំនោះបានពុកផុយអស់ហើយ។ អ្នកភូមិជាច្រើនបានប្រាប់នាងថា ម្តាយ ខ្ញុំនិងក្មេងៗប្រុសស្រីបួននាក់ទៀត ត្រូវបានយកទៅនៅភូមិថ្មីមួយ។ ប្តីរបស់ខ្ញុំ និងខ្ញុំត្រូវបានបញ្ជូនទៅរស់នៅខេត្តកំពត ខ្ញុំរីករាយណាស់ដោយបានគិតថា នឹងបានជួបជុំសាច់ញាតិរបស់ម្តាយខ្ញុំនៅទីនោះ ប៉ុន្តែអ្នកទាំងនោះបានធ្វើជាមិនស្គាល់ខ្ញុំ។ អាក្រក់ជាងនេះទៀតនោះ ពួកគាត់បាននិយាយថា ពួកគាត់មិនមានសាច់ញាតិដែលជា«ប្រជាជន១៧មេសា» ឬ«ប្រជាជនថ្មី»ជាខ្មាំងដូចរូបខ្ញុំឡើយ។ ខ្ញុំមិនធ្លាប់ធ្វើស្រែចម្ការទេពីមុនមក។ នារីមូលដ្ឋានជាច្រើននាក់បានស្អប់ខ្ញុំ និងតាមដានខ្ញុំ នៅពេលដែលខ្ញុំធ្វើឲ្យមានកំហុសអ្វីមួយ។ គេបាននិយាយមាក់ងាយមកលើខ្ញុំថា ជាអ្នកធ្លាប់កេងប្រវ័ញ្ចញើសឈាមពីកសិករ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ប្តីខ្ញុំត្រូវបានបញ្ជាឲ្យទៅធ្វើចម្ការដាំដំឡូងឈើ និងពោតនៅម្តុំភ្នំបាក់នឹម។ ច្រើនខែកន្លងមក គាត់មិនបានត្រឡប់មកវិញទេ យើងបានគិតថា គាត់ប្រាកដជាស្លាប់ហើយ ប៉ុន្តែនៅព្រលប់មួយក្នុងខែកក្កដា ឆ្នាំ១៩៧៨ គាត់បានដិះរទេះក្របីមួយត្រឡប់មកវិញ។ ខ្ញុំបានប្រាប់ប្តីខ្ញុំថា មុននេះ អង្គការបានបញ្ជាឲ្យបុរសបួននាក់ទៅបន្ថែមកម្លាំងលើកទំនប់នៅជិតនេះ ហើយមិនបានឃើញពួកគាត់តាំងពីពេលនោះមក។ ប្តីខ្ញុំបានព្យាយាមលួង លោមខ្ញុំ និងប្រាប់ខ្ញុំកុំឲ្យនិយាយព្រពោក ឬកុំបារម្ភអី។ នៅយប់នោះ ផាត ប្រធានអង្គភាពផ្គត់ផ្គង់សេដ្ឋកិច្ចបានបញ្ជាឲ្យប្តីខ្ញុំចេញទៅបន្ថែមកម្លាំងលើកទំនប់។ ប្តីខ្ញុំមិនទាន់បានផ្លាស់សម្លៀកបំពាក់ចាស់របស់គាត់ផង គាត់បានយកចបកាប់មួយដើរតាមក្រុមឈ្លបនោះ។ បន្តិចក្រោយមក គាត់បានត្រឡប់មកវិញថើបកូនៗ និងប្រាប់ខ្ញុំថាមិនចាំបាច់រង់ចាំគាត់ទេ។ បន្ទាប់មកគាត់បានដើរចេញពីផ្ទះ រួចក្រឡេកក្រោយមើលម្តងទៀត។ នៅយប់នោះខ្ញុំ បានយល់សប្តិថា គាត់បានមករកយើង ប៉ុន្តែតួខ្លួនគាត់មិនមានក្បាលជាប់ទេ។

បន្ទាប់មកឈ្មោះ គី ជាឈ្លបម្នាក់នៅក្នុងក្រុមកងឈ្លបដែលយកប្តីខ្ញុំទៅនោះ បានព្យាយាមចាប់រំលោភខ្ញុំ។ គី ធ្វើអ្វីខ្ញុំមិនបានសម្រេច ព្រោះខ្ញុំបានកាប់ដៃ គី បណ្តាលឲ្យធ្លាក់ពីលើផ្ទះ។ ព្រឹកបន្ទាប់មកមានកម្មាភិបាលជាច្រើននាក់បានមកផ្ទះខ្ញុំ ហើយបានប្រាប់ខ្ញុំឲ្យយកកូនៗទៅផ្ញើមនុស្សចំណាស់ៗ ព្រោះកម្មាភិបាលទាំងនោះត្រូវនាំខ្ញុំទៅជាមួយ។ ខ្ញុំបានអង្វរអ្នកទាំងនោះសុំ យកកូនៗទៅជាមួយខ្ញុំដែរ។ បន្ទាប់មកកម្មាភិបាលទាំងនោះបានយល់ព្រម។ កម្មាភិបាលទាំងនោះ បាននាំខ្ញុំនិងកូនទៅជិះរទេះសេះទៅកាន់វត្តមួយ។ នៅទីនោះខ្ញុំបានឃើញ មិត្តគី អង្គុយពីក្រោយបុរសម្នាក់ឈ្មោះ សាក់ ដែលបានចោទខ្ញុំថាអ្នកស៊ើបការណ៍ និងជាប្រពន្ធរបស់ភ្នាក់ងារសេ.អ៊ី.អា។ បន្ទាប់មកក្រុមកងឈ្លបបានចងដៃខ្ញុំទៅក្រោយហើយនាំយកខ្ញុំទៅកាន់មន្ទីរសន្តិសុខ មួយជាទីកន្លែងដែលសមមិត្តនៅមន្ទីរស្រុកវាយធ្វើបាបខ្ញុំ។

មួយអាទិត្យក្រោយមក អង្គការបានបញ្ជូនខ្ញុំទៅកាន់មន្ទីរសន្តិសុខធំមួយនៅភ្នំល្អាង។ ខ្ញុំបានជាប់ខ្នោះ ប៉ុន្តែកូនៗខ្ញុំមិនបានជាប់ទេ។ អ្នកទោសជាច្រើនមានរូបរាងស្គមកំព្រឹង។ រៀងរាល់យប់អ្នកយាមបានយកអ្នកទោសបី ឬបួននាក់ចេញទៅ ខ្ញុំបានឮសម្រែកនៃការឈឺចាប់បន្ទឹតាមខ្យល់ប៉ុណ្ណោះ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ១៩៧៨ ខ្ញុំបានឮសំឡេងកាំភ្លើងល្មើយៗ។ ភ្លាមៗនោះកូនរបស់ខ្ញុំម្នាក់បានបង្ហាញខ្លួន ជាមួយនឹងកូនសោរជាច្រើន ហើយបានបើកទ្វារឲ្យយើងចេញ។ សំឡេងស្រែកហ៊ោរីករាយកងរំពង។ ខ្ញុំបានដឹកដៃកូនៗខ្ញុំរត់ចេញពីមន្ទីរសន្តិសុខ។ មានតែអ្នកទោស១៣ នាក់គត់នៅល្អាង ដែលនៅរស់រានមានជីវិត។ នៅតាមផ្លូវយើងឮកងទ័ពរណសិរ្សអំពាវនាវឲ្យប្រជាជនត្រឡប់ទៅកាន់ផ្ទះសម្បែងវិញ។

ថ្ងៃមួយនោះ ខ្ញុំបានទៅប្រមូលស្រូវពីជង្រុកនៅក្នុងភូមិដែលខ្ញុំស្នាក់នៅ និងបានឮសំឡេងហៅខ្ញុំ នៅពេលដែលខ្ញុំងាក

*រកមើលស្រាប់តែបានឃើញសង្សាររបស់ខ្ញុំ។ យើងបានភ្ជាប់ពាក្យនៅឆ្នាំ១៩៦៩ ប៉ុន្តែបន្ទាប់មកម្តាយគាត់បានឲ្យខ្ញុំទៅរស់នៅជាមួយគាត់ នៅខេត្តមួយផ្សេង ទៀត ឪពុកម្តាយខ្ញុំមិនបានអនុញ្ញាតឲ្យយើងរៀបការទេ។ ឪពុកខ្ញុំបានឲ្យខ្ញុំស្នាក់នៅជាមួយគាត់ និងបានសន្យាថានឹងជួយថែរក្សាកូនៗខ្ញុំឲ្យបានល្អ។*

**ប៉ាង ពីរ័ត្ន និង វេនី ខកហ្កៀល**



*ពីឆ្វេង៖ ជីតារបស់អារុណ ជាតិប៉ុណ្ណារី ខកញ៉ា ពេជ្រ ប៉ុន និងឪពុកមា ប៉ុន វង្ស*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ៖ (៨៥៥) ២៣ ២១០ ៣៥៨*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358
◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 222, 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.